









# “ដំណើរឆ្ពោះទៅមុខ៖ ការសិក្សាពីផលប៉ះពាល់នៃការអនុវត្តបទបញ្ជា០១ (បប) មកលើសហគមន៍ នៅតំបន់ជនបទនៃប្រទេសកម្ពុជា”

ខែមិថុនា ឆ្នាំ ២០១៣

# "នយោបាយចាស់ សកម្មភាពថ្មី លើវិស័យដីធ្លីនៅកម្ពុជា"

នៅថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០១២ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចេញបទបញ្ជាមួយដែលគេស្គាល់ថា ជាបទបញ្ជា០១(បប)។ បទបញ្ជានេះប្រកាសផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងអំពាវនាវឲ្យមានការពិនិត្យមើលឡើងវិញលើការអនុវត្តន៍នៅតំបន់សម្បទានដីសេដ្ឋកិច្ចដែលរាជរដ្ឋាភិបាលបានផ្តល់ដល់ក្រុមហ៊ុននានា។ វានៅនៅក្នុផ្នែកមួយនៃ "សកម្មភាពថ្មី" របស់រាជរដ្ឋាភិបាល ដើម្បីរកដំណោះស្រាយលើទំនាស់ដីធ្លី ដែលជាគំរោងមួយមានពាក់ព័ន្ធនឹងការបញ្ជូនក្រុមនិស្សិតស្ម័គ្រចិត្តរាប់រយនាក់ទៅតាមតំបន់ផ្សេងនៅទូទាំងប្រទេសដើម្បីវាស់វែងដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនដល់ប្រជាពលរដ្ឋ។

*"ដារួម យុទ្ធនាការដើម្បីអនុវត្តនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី គឺជាជំហានថ្មីមួយទៀតនៃការធ្វើកំណែទម្រង់ដីធ្លីយ៉ាងស៊ីជម្រៅ ដើម្បីដោះស្រាយ និងធ្វើឲ្យដីដែលត្រូវបានកាន់កាប់មិនច្បាស់លាស់កន្លងមកបានស្របច្បាប់ ដោយមានសុវត្ថិភាព តាមរយៈការផ្តល់ប្រទានកម្មនៃសិទ្ធិកម្មសិទ្ធិដីធ្លីពេញលេញ ការផ្តល់សម្បទានដីសេដ្ឋកិច្ចខ្នាតតូច ឬសម្បទានដីសង្គមកិច្ច ដើម្បីធានាដល់សន្តិសុខក្នុងការកាន់កាប់ដីធ្លី។ ដើម្បីដោះស្រាយជម្លោះដីធ្លី ដើម្បីលើកកម្ពស់សេដ្ឋកិច្ចជាតិ តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពទៅលើដីដែលត្រូវបានកាន់កាប់ក្នុងទំហំខ្នាតតូច មធ្យម និងខ្នាតធំ។ ដើម្បីថែរក្សានិរន្តរភាពបរិស្ថាន និងការពារធនធានធម្មជាតិ។"* ឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ខែកញ្ញា ឆ្នាំ២០១២។

*"ខ្ញុំមានអារម្មណ៍រំភើបញាប់ញ័រ មានអារម្មណ៍ថារឹងមាំ និងបានបំពេញកាតព្វកិច្ចជូនជាតិ។ ខ្ញុំរក្សាទុកសំលៀកបំពាក់ទាហាននៅផ្ទះជាអនុស្សាវរីយ៍។"* អតីតនិស្សិតស្ម័គ្រចិត្ត, ខែមិថុនា ឆ្នាំ២០១៣

*"គេសន្យាថា ដោះ(ស្រាយ) តែអត់ទាន់មាននរណាមកដោះឲ្យខ្ញុំទេ។ ដីខ្ញុំមានប្លង់ត្រឹមត្រូវ។ តាមពិតដីខ្ញុំមានប្រាំហិកតា តែដល់និស្សិតចុះមកវាស់ គេវាស់ឲ្យបានតែ៣ហិកតា។ ប៉ុណ្ណឹង ក៏ខ្ញុំព្រមទទួលដែរ តែដល់មកឥឡូវអត់ទាំងបានដីហ្នឹងទៀត បានតែប្លង់លើក្រដាស។ ខ្ញុំសំណូមពរឲ្យអាជ្ញាធរជួយដោះស្រាយដីឲ្យខ្ញុំផង។"* ប្រជាពលរដ្ឋខេត្តពោធិ៍សាត់, ខែឧសភា ឆ្នាំ២០១៣

*"នៅក្នុងភូមិរបស់ខ្ញុំ និស្សិតស្ម័គ្រចិត្ត បានចុះវាស់វែងដីរួចហើយ និងត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិបឋមដល់គ្រួសារ។ តែអាជ្ញាធរមូលដ្ឋានលើកឡើងថា ក្រុមនិស្សិតស្ម័គ្រចិត្តបានធ្វើការងារមានការនឿយហត់ខ្លាំង ដូច្នេះមិនចាំបាច់ចែកប័ណ្ណកម្មសិទ្ធិបឋមដល់ប្រជាជនដោយខ្លួនឯងទេ។ អាជ្ញាធរមូលដ្ឋាន អាចជួយសម្រួលបានដោយជួយចែកប័ណ្ណឲ្យទៅប្រជាជនក្នុងមូលដ្ឋានរបស់ខ្លួនដោយខ្លួនឯង។ ក្រុមនិស្សិត ក៏បានទុកប័ណ្ណទាំងនោះជាមួយនឹងអាជ្ញាធរ។ នៅពេលដែលគាត់(អាជ្ញាធរមូលដ្ឋាន) ចែកប័ណ្ណដល់ប្រជាជន គាត់បានរំលឹកថា កុំភ្លេចបោះឆ្នោតឲ្យបក្សផង នៅពេលបោះឆ្នោតខាងមុខ បើមិនដូច្នោះទេ ប្រយ័ត្នគេមិនចេញប្លង់រឹងឲ្យ។"*
ប្រជាពលរដ្ឋ ខេត្តឧត្តរមានជ័យ, ខែមិនា ឆ្នាំ ២០១៣។

# មាតិកា


សេចក្តីផ្តើម ........ 4

វិធីសាស្ត្រ និងដំណើរការនៃការចងក្រងឯកសារ ........ 5

1. គោលបំណងនៃការចងក្រងឯកសារ ........ 5
2. សំណួរសំខាន់ៗនៃការចងក្រងឯកសារ ........ 5
3. ទីតាំងតំបន់ដែលគ្របដណ្តប់ ក្នុងការចងក្រងឯកសារ ........ 6
4. ប្រជាជនដែលចូលរួមនៅក្នុងការប្រមូលព័ត៌មាន ........ 7
5. ការប្រមូលព័ត៌មាន និងដំណើរការវិភាគទិន្នន័យ ........ 7

២.១ ប្រវត្តិ ........ 10

២.២ បទដ្ឋានគតិយុត្តនៃបទបញ្ជា០១(បប) ........ 10

២.៣ ការជ្រើសរើស និងសមាសភាពនិស្សិតស្ម័គ្រចិត្ត ........ 12

២.៤ ការបណ្តុះបណ្តាលនិស្សិតស្ម័គ្រចិត្ត ........ 13

២.៥. ផែនការនៃការវាស់វែងដីនិងផលសម្រេច ........ 15

ក. ដំណាក់កាលទី១ ........ 15

ខ. ដំណាក់កាលទីពីរ ........ 16

២.៦ ការឧបត្ថម្ភគាំទ្រលើសកម្មភាពការងារអនុវត្តបទបញ្ជា ០១(បប) ........ 17

២.៧ អង្គភាពគ្រប់គ្រងនិស្សិតស្ម័គ្រចិត្ត ........ 19

២.៨ សេចក្តីសង្ខេបលើប្រវត្តិក្រុមនិស្សិតស្ម័គ្រចិត្ត ........ 21

បទពិសោធន៍នៃការចូលរួមក្នុងការវាស់វែងដីធ្លី របស់ ប្រជាជននៅខេត្ត កំពង់ឆ្នាំង, ពោធិ៍សាត់,បាត់ដំបង , និងខេត្តឧត្តរមានជ័យ ........ 23

៣.១ ឯកសារដែលត្រូវការសម្រាប់ការវាស់វែងដីធ្លី ........ 24

៣.២ ប្រភេទដីដែលត្រូវវាស់វែងក្នុងយុទ្ធនាការវាស់វែងដីធ្លី ........ 24

៣.៣ កិច្ចសហការក្នុងដំណើរការចុះវាស់វែងដីធ្លី ........ 25

៣.៤ បញ្ហាប្រឈមក្នុងការអនុវត្តការវាស់វែងដីធ្លី ........ 26

៣.៥ ក្តីសង្ឃឹមលើអត្ថប្រយោជន៍នៃការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី ........ 26

៣.៦ ក្តីកង្វល់របស់ប្រជាពលរដ្ឋលើការផ្តល់ប័ណ្ណកម្មសិទ្ធិ ........ 27

៣.៦.១ ការបែកបាក់សាមគ្គីក្នុងរង្វង់ប្រជាជនក្នុងសហគមន៍ ........ 27

៣.៦.២ ភាពមានកម្រិតនៃការប្រើប្រាស់ដី ........ 28

៣.៦.៣ ការកេងចំណេញផ្នែកនយោបាយពីការអនុវត្តបទបញ្ជា០១(បប) ........ 28

៣.៦.៤ ការឆ្លៀតឱកាសរំលោភយកដីពីប្រជាជន ក្នុងដំណើរការនៃការចុះវាស់វែងដីធ្លីរបស់និស្សិត ....29
៣.៦.៥ ការរើសអើងមកលើប្រជាជន ....29
៣.៧ ការចូលរួមរបស់និស្សិតនារីក្នុងដំណើរការវាស់វែងដីធ្លី ....30
៣.៨ ការមិនទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅតាមសហគមន៍ - លើកឡើងក្នុងសមាជប្រជាជនកម្ពុជា ....30
ករណីសិក្សាទី១៖ ប្រសិទ្ធិភាពនៃប័ណ្ណកម្មសិទ្ធិដីធ្លីថ្មី - ករណីប្រជាជន១១គ្រួសារ ....33
ក. ប្រវត្តិនៃបញ្ហា ....34
ខ. ឫសគល់នៃបញ្ហា៖ ប្លង់ត្រួតស៊ីគ្នា ....35
គ. ការគំរាមកំហែង ពីសំណាក់អាជ្ញាធរ និងមន្រ្តីជំនាញ ....38
ឃ. ផលប៉ះពាល់មកលើគ្រួសាររងគ្រោះ ....38
ករណីសិក្សាទី២៖ ការដកហូតប័ណ្ណកម្មសិទ្ធិដីថ្មីរបស់ប្រជាជន ....41
ករណីសិក្សាទី ៤ករណីសិក្សាទី៥ ....45
៤.១ ទំហំដីក្នុងប័ណ្ណមួយ និងប្រភេទដីដែលត្រូវបានវាស់វែង ....48
៤.២ ការជួលឈ្មោះមនុស្ស ដាក់លើប័ណ្ណកម្មសិទ្ធិ ....49
៤.៣ ការផ្សព្វផ្សាយពីយុទ្ធនាការចុះវាស់វែងដីធ្លីដល់សហគមន៍ នៅមានកម្រិត ....49
៤.៤ ការវិវត្តន៍ឆាប់រហ័សនៃការអនុវត្តបទបញ្ជា០១(បប) ....50
៤.៥ បញ្ហាកំហុសបច្ចេកទេសក្នុងការចុះវាស់វែងដីធ្លី ....51
៤.៦ ការរង់ចាំទទួលបានប័ណ្ណកម្មសិទ្ធិពេញលេញ មានរយៈពេលយូរពេក ....52
សន្និដ្ឋាន ....54
ឯកសារយោង ....56

# សេចក្តីផ្តើម

នៅចុងខែមិថុនា និងដើមខែកក្កដា ឆ្នាំ២០១២ និស្សិតស្ម័គ្រចិត្តដែលមានសមាជិកប្រមាណជាងមួយពាន់នាក់ រួមនឹងមន្ត្រីជំនាញរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានបញ្ជូនចាកចេញពីទីតាំងការិយាល័យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចុះទៅតាមខេត្តគោលដៅដែលបានកំណត់ដើម្បីចាប់ផ្តើមយុទ្ធនាការនៃការវាស់វែងដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធិដល់ប្រជាពលរដ្ឋ។ នេះគឺជាដំណើរការសកម្មភាពចុះអនុវត្តបទបញ្ជា០១(បប) របស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ និស្សិតស្ម័គ្រចិត្តដែលត្រូវបានជ្រើសរើស បណ្តុះបណ្តាល និងបំពាក់ឯកសណ្ឋានទាហាន ដោយមានស្លាកសញ្ញារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានដឹកជញ្ជូនដោយរថយន្តទាហានរបស់ក្រសួងការពារជាតិដើម្បីចុះទៅអនុវត្តបេសកម្មជាប្រវត្តិសាស្ត្រនេះ។ យុទ្ធនាការចុះវាស់វែងដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធិនេះ មានសភាពពាក់ពន្ធ័នឹងបញ្ហានយោបាយយ៉ាងជ្រាលជ្រៅ ហើយទទួលបានការយកចិត្តទុកដាក់ផ្ទាល់ពីសំណាក់នាយករដ្ឋមន្ត្រីនិងភរិយា និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់។ យុទ្ធនាការជាប្រវត្តិសាស្ត្រនៃការចុះវាស់វែងដីធ្លី អនុវត្តដោយមន្ត្រីជំនាញមកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោមការគាំទ្រពីសំណាក់និស្សិតស្ម័គ្រចិត្ត និងក្រសួងពាក់ព័ន្ធ និងទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុដោយថវិកាផ្ទាល់របស់នាយករដ្ឋមន្ត្រីនិងភរិយា និងមន្ត្រីសំខាន់ៗនៃគណបក្សប្រជាជនកម្ពុជា។ ខណៈដែលសារព័ត៌មានក្នុងនិងក្រៅប្រទេសចុះផ្សាយព្រោងព្រាតពីដំណើរការសកម្មភាពនៃយុទ្ធនាការនេះ ការផ្តោតជាពិសេសនៃសកម្មភាពយុទ្ធនាការគឺ ទៅលើការចូលរួមយ៉ាងផុសផុលពីសំណាក់និស្សិតស្ម័គ្រចិត្តក្នុងការងារវាស់វែងដីធ្លី ទោះបីជាមន្ត្រីជំនាញរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអ្នកទទួលខុសត្រូវខ្ពស់នៅក្នុងភារកិច្ចនេះក៏ដោយ។ ឆ្លងកាត់បទពិសោធន៍នៃការបណ្តុះបណ្តាលរយៈពេលខ្លី និងការចុះមូលដ្ឋានឆ្ងាយៗ ជាបទពិសោធន៍ថ្មីសម្រាប់និស្សិតស្ម័គ្រចិត្តមួយចំនួនធំ។

ដើម្បីស្វែងយល់អំពី ប្រសិទ្ធិភាពរបស់បទបញ្ជា០១(បប) ក្នុងការដោះស្រាយបញ្ហាជម្លោះដីធ្លីនៅក្នុងប្រទេសនេះ មូលនិធិហែនរិកបូល និងអង្គការ Focus on the Global South (ហៅកាត់ថា Focus) បានគាំទ្រអោយមានការសិក្សាមួយដើម្បីធ្វើការចងក្រងឯកសារលើការអនុវត្តបទបញ្ជានៅតំបន់គោលដៅដែលបានជ្រើសរើសមួយចំនួន។ គោលដៅសំខាន់ក្នុងការចងក្រងឯកសារនេះ គឺសំរាប់បង្ហាញនូវផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានមួយចំនួននៃការអនុវត្តបទបញ្ជានេះទៅលើសហគមន៍ជនបទមួយចំនួន។ ទោះជាការចងក្រងនេះមិនមានលក្ខណៈលំអិតក៏ដោយ ក៏ប៉ុន្តែវាផ្តោតយកចំណុចសំខាន់ៗ លើមហិច្ចតានៃការផ្តួចផ្តើមផ្តល់កម្មសិទ្ធិដីធ្លីក្នុងប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។

ការចងក្រងឯកសារនេះចែកចេញជាបួនផ្នែកសំខាន់ៗ។ ផ្នែកទីមួយបង្ហាញពីវិធីសាស្ត្រ និងដំណើរការនៃការចងក្រងឯកសារ។ ផ្នែកទីពីររៀបរាប់ពីប្រវត្តិនៃការបង្កើតក្រុមនិស្សិតស្ម័គ្រចិត្ត និងសកម្មភាពនានាជុំវិញដំណើរការសកម្មភាពចុះអនុវត្តការងារ។ ផ្នែកទីបីបង្ហាញពីព័ត៌មានដែលប្រមូលបានពីខេត្តចំនួនបួន គឺខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងខេត្តឧត្តរមានជ័យ។ ព័ត៌មានពិស្តារទាក់ទងនឹងករណីជាក់លាក់នៃការចុះវាស់វែងដីធ្លីរបស់ភូមិគោលដៅដែលក្រុមការងារបានប្រមូលក៏មានបង្ហាញនៅក្នុងផ្នែកនេះដែរ។

ផ្នែកចុងក្រោយពិភាក្សាលើទិន្នន័យដែលប្រមូលបាននៅក្នុងការចងក្រងឯកសារ និងសន្និដ្ឋានលើផលប៉ះពាល់នៃសកម្មភាពចុះអនុវត្តការងារមកលើប្រជាជននៅក្នុងមូលដ្ឋាន។

# វិធីសាស្រ្ត និងដំណើរការនៃការចងក្រងឯកសារ

ការចងក្រងឯកសារនេះ គឺជាការកត់ត្រាឯកសារបែបគុណភាព លើបទពិសោធន៍នានានៃការចូលរួមរបស់ប្រជាជននៅក្នុងដំណើរការចុះវាស់វែងដីធ្លី តាមរយៈការអនុវត្តបទបញ្ជា០១(បប) របស់នាយករដ្ឋមន្រ្តីកម្ពុជា។ នៅក្នុងផ្នែកនេះពិពណ៌នាពីវិធីសាស្រ្ត ដំណើរការ អ្នកចូលរួម ការផ្តល់ព័ត៌មានសំណួរ និងដំណើរការវិភាគលើទិន្នន័យដែលបានប្រមូល។

## 1. គោលបំណងនៃការចងក្រងឯកសារ

ការចងក្រងឯកសារនេះមានគោលបំណងធ្វើការចងក្រងពីប្រវត្តិនិងដំណើរការអនុវត្តសកម្មភាពចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត និងបទពិសោធន៍របស់ប្រជាជនតាមសហគមន៍ដែលបានចូលរួមនៅក្នុងដំណើរការនៃការចុះវាស់វែងដីធ្លីនេះ។ គោលបំណងជាក់លាក់នៃការចងក្រងឯកសារនេះគឺ៖

1. ដើម្បីធ្វើការស្វែងយល់ពីកត្តាជំរុញខាងនយោបាយដែលបណ្តាលឲ្យមានការបង្កើតក្រុមយុវនិស្សិតស្ម័គ្រចិត្តនេះឡើង
2. ដើម្បីចងក្រងពីដំណើរការជ្រើសរើស ការបណ្តុះបណ្តាល ភារកិច្ច និងការចុះអនុវត្តការងារជាក់ស្តែងរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត
3. ដើម្បីធ្វើការស្វែងយល់ពីផលប៉ះពាល់ (វិជ្ជមាន ឬអវិជ្ជមាន) នៃការចុះអនុវត្តកម្មវិធីវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត មកលើប្រជាជនក្នុងសហគមន៍
4. ដើម្បីសិក្សាស្វែងយល់ពីការយល់ឃើញរបស់ប្រជាជនក្នុងសហគមន៍ចំពោះសកម្មភាព ដំណើរការ និងលទ្ធផលការងាររបស់ក្រុមយុវនិស្សិតស្ម័គ្រចិត្តមកលើជីវភាពរស់នៅរបស់ប្រជាជន

## 2. សំណួរសំខាន់ៗនៃការចងក្រងឯកសារ

ព័ត៌មានដែលត្រូវបានប្រើប្រាស់នៅក្នុងការវិភាគទិន្នន័យក្នុងការចងក្រងឯកសារនេះ គឺត្រូវបានប្រមូលមកពីប្រភពព័ត៌មានដែលមានស្រាប់ និងព័ត៌មានបឋម។ ព័ត៌មានដែលមានស្រាប់ត្រូវបានប្រមូលក្នុងគោលបំណងធ្វើការចងក្រងពីប្រវត្តិ និងដំណើរការអនុវត្តសកម្មភាពចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត។ ចំណែកព័ត៌មានបឋមគឺ ផ្តោតលើបទពិសោធន៍របស់ប្រជាជនតាមសហគមន៍ដែលបានចូលរួមនៅក្នុងដំណើរការចុះវាស់វែងដីធ្លី។ ការប្រមូលព័ត៌មានដោយផ្អែកលើឯកសារដែលមានស្រាប់ និងព័ត៌មានដែលអាចរកបាននៅលើគេហទំព័រគឺ ជាផ្នែកសំខាន់មួយនៃការចងក្រងឯកសារនេះ។ គេហទំព័រសំខាន់ៗមួយចំនួនដូចជា៖ គេហទំព័ររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (www.mlmupc.gov.kh) គេហទំព័រ New Vision Cambodia ដែលផ្ទុកព័ត៌មានថ្មីៗពីសកម្មភាព និងសន្ទរកថារបស់នាយករដ្ឋមន្ត្រី គេហទំព័រកុលបុត្រខ្មែរ *កាសែតភ្នំពេញប៉ុស្តិ៍ កាសែតខាំបូឌាដេលី* និងព័ត៌មានដែលមាននៅលើគេហទំព័រ និងបណ្តាញសារ

ព័ត៌មានក្នុងស្រុកនានាត្រូវបានប្រមូល និងធ្វើការសិក្សាពិនិត្យយ៉ាងម៉ត់ចត់។ ការសិក្សាស្រាវជ្រាវថ្មីៗដែលផ្តោតលើការអនុវត្តបទបញ្ជា០១(បប) ក៏ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការវិភាគទិន្នន័យបន្ទាប់បន្សំទាំងនេះ។ ការប្រមូលព័ត៌មានថ្នាក់មូលដ្ឋានគឺ ផ្អែកលើការប្រមូលព័ត៌មានតាមរយៈកិច្ចសម្ភាសន៍ និងការពិភាក្សាជាមួយប្រជាជនក្នុងខេត្តគោលដៅទាំងបួនដែលបានប្រព្រឹត្តទៅក្នុងខែមិនា ខែឧសភា និងខែមិថុនា ឆ្នាំ២០១៣។

សំណួរសំខាន់ៗខាងក្រោមនេះដឹកនាំការប្រមូលព័ត៌មាននៅក្នុងការចងក្រងឯកសារៈ

1. តើក្រុមយុវជនស្ម័គ្រចិត្តចុះវាស់វែងដីធ្លីជាអ្នកណា? តើពួកគេត្រូវបានជ្រើសរើសដោយរបៀបណា? តើអ្នកណាជាអ្នកផ្តល់ថវិកាឧបត្ថម្ភដល់សកម្មភាពរបស់ពួកគេ?
2. ហេតុអ្វីបានជាក្រុមការងារពិសេសនេះត្រូវបានបង្កើតឡើង? តើមានកត្តាជំរុញផ្នែកនយោបាយអ្វីខ្លះក្នុងការបង្កើតក្រុមការងារនេះឡើង?
3. តើក្រុមការងារយុវជនស្ម័គ្រចិត្តនេះចែកចេញជាប៉ុន្មានក្រុម ហើយចុះអនុវត្តការងារនៅកន្លែងណាខ្លះនៅក្នុងប្រទេសកម្ពុជា?
4. តើការងាររបស់ក្រុមយុវជនស្ម័គ្រចិត្តមានផលប៉ះពាល់វិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះ ចាប់តាំងពីការអនុវត្តការងារកន្លងមក?
5. តើប្រជាជនក្នុងសហគមន៍មានការយល់ឃើញយ៉ាងណា លើលទ្ធផលការងាររបស់ក្រុមនិស្សិតស្ម័គ្រចិត្ត? តើការងារនេះ មានប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនយ៉ាងដូចម្តេច?

## 3. ទីតាំងតំបន់ដែលគ្របដណ្តប់ ក្នុងការចងក្រងឯកសារ

ការចងក្រងឯកសារនេះបានប្រមូលព័ត៌មានពីបណ្តាភូមិគោលដៅចំនួន ១៦ភូមិក្នុងខេត្តចំនួនបួន រួមមានៈ ខេត្តឧត្តរមានជ័យ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង។

តារាងទី ១ៈ តំបន់គ្របដណ្តប់នៃការចងក្រងឯកសារ

| ឈ្មោះខេត្ត | ចំនួនភូមិ | ចំនួនប្រជាជន |
|---|---|---|
| កំពង់ឆ្នាំង | ២ | ៦២ |
| ពោធិ៍សាត់ | ៥ | ១២៨ |
| បាត់ដំបង | ១ | ១៥ |
| ឧត្តរមានជ័យ | ៨ | ១០៨ |
| **សរុប** | **១៦** | **៣១៣** |

ការជ្រើសរើសភូមិឃុំគោលដៅសម្រាប់ការប្រមូលព័ត៌មានគឺ យោងទៅលើវត្តមាននៃប្រជាជនក្នុងមូលដ្ឋានដែលស្ម័គ្រចិត្តជួយផ្តល់ព័ត៌មានពីសកម្មភាពនៃការចុះវាស់វែងដីធ្លីក្នុងភូមិខ្លួនក៏ដូចជាភូមិជិតខាង។

## 4. ប្រជាជនដែលចូលរួមនៅក្នុងការប្រមូលព័ត៌មាន

ប្រជាជនដែលបានចូលរួមនៅក្នុងដំណើរការប្រមូលព័ត៌មានរួមមាន៖ ប្រជាជនដែលរស់នៅក្នុងភូមិដែលអ្នកស្ម័គ្រចិត្តជួយប្រមូលព័ត៌មានដែលមានដីដែលត្រូវបានក្រុមនិស្សិតស្ម័គ្រចិត្តវាស់វែង, អ្នកដែលដីរបស់ខ្លួនមិនទាន់បានទទួលការវាស់វែង, ប្រជាជនដែលបានទទួលសាលាកប័ត្រក្រោយពីការវាស់វែង, ប្រជាជនដែលទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីពេញលេញ, និងអ្នកដែលបានទទួលបានប័ណ្ណ និងមានបញ្ហានៃការប្រើប្រាស់ប័ណ្ណនៅលើដីរបស់ខ្លួន, អាជ្ញាធរមូលដ្ឋាន មេភូមិ/ក្រុមប្រឹក្សាឃុំ, មន្ត្រីជំនាញនៃមន្ទីរសុរិយោដី និងភូមិសាស្ត្រតាមខេត្តគោលដៅមួយចំនួន អតីតនិស្សិតស្ម័គ្រចិត្ត, មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលជាអតីតនិស្សិតស្ម័គ្រចិត្ត និងបច្ចុប្បន្នកំពុងបម្រើការងារចុះវាស់វែងដីធ្លី។

ការចុះប្រមូលព័ត៌មានក្នុងខែមិនា ឆ្នាំ២០១៣ គ្របដណ្តប់លើប្រជាជនសរុបចំនួនមួយរយដប់បួននាក់ (១១៤នាក់) ដែលយ៉ាងហោចណាស់មានស្ត្រីចំនួន៤៧នាក់ ដែលចូលរួមផ្តល់ព័ត៌មាន និងចែករំលែកបទពិសោធន៍នានាក្នុងការចូលរួមក្នុងដំណើរការវាស់វែងដីធ្លី។ ការចុះប្រមូលព័ត៌មានក្នុងខែឧសភា ឆ្នាំ២០១៣ មានប្រជាជនចំនួនមួយរយកៅសិបប្រាំបួននាក់ (១៩៩នាក់) បានចូលរួមផ្តល់ព័ត៌មាន។ សរុបមកមានប្រជាជនចំនួនយ៉ាងហោចណាស់ក៏ ៣១៣នាក់ ដែលត្រូវបានជួបពិភាក្សា និងបញ្ចេញមតិយោបល់លើដំណើរការនៃការវាស់វែងដីធ្លី និងបទពិសោធន៍ក្នុងការចូលរួមកម្មវិធីនេះផង។

## 5. ការប្រមូលព័ត៌មាន និងដំណើរការវិភាគទិន្នន័យ

មានដំហានបីសំខាន់ៗនៃការប្រមូលព័ត៌មាន និងដំណើរការនៃការវិភាគទិន្នន័យ ៖

*ក. សិក្ខាសាលារៀបចំស្តីពីការចងក្រងឯកសារលើកម្មវិធីនិស្សិតស្ម័គ្រចិត្ត ចុះវាស់វែងដីធ្លី៖* ប្រព្រឹត្តិទៅនៅខែកុម្ភៈ ឆ្នាំ២០១៣ ក្នុងគោលបំណងពិភាក្សាពីផែនការនៃការចងក្រងឯកសារ ការរៀបចំក្រុមសិក្សាស្រាវជ្រាវ និងបង្កើតកម្រងសំណួរសម្រាប់ការចុះប្រមូលព័ត៌មានដំណាក់កាលទីមួយ។

*ខ. សិក្ខាសាលាវិភាគទិន្នន័យដែលប្រមូលបានដំណាក់កាលទីមួយ៖* ប្រព្រឹត្តិទៅក្នុងរយៈពេលពីរថ្ងៃ នៅចុងខែមេសា ឆ្នាំ២០១៣ ដើម្បីពិនិត្យមើលទិន្នន័យដែលប្រមូលបាន៖ ទិន្នន័យបន្ទាប់បន្សំ ស្តីពីដំណើរការនៃការបង្កើតក្រុមយុវនិស្សិតស្ម័គ្រចិត្ត និងគោលបំណងនៃការអនុវត្តបទបញ្ជា០១(បប) របស់រាជរដ្ឋាភិបាល និងទិន្នន័យបឋមដែលប្រមូលបានមកពីសហគមន៍ និងធ្វើការវិភាគដោយមានការចូលរួមជាមួយក្រុមស្រាវជ្រាវ។ ជាលទ្ធផល ក្រុមស្រាវជ្រាវបានរៀបចំបញ្ជីសំណួរបន្ថែមដើម្បីចុះប្រមូលព័ត៌មានឲ្យបានស៊ីជម្រៅថែមទៀត។

*គ. សិក្ខាសាលាវិភាគទិន្នន័យដែលប្រមូលបានដំណាក់កាលទីពីរ៖* ធ្វើឡើងនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ បន្ទាប់ពីការចុះប្រមូលព័ត៌មានបន្ថែមជាលើកទីពីរនៅតាមមូលដ្ឋាន។

នៅក្នុងដំណាក់កាលនីមួយៗនៃសិក្ខាសាលាវិភាគទិន្នន័យ ការវិភាគរួមទៅលើទិន្នន័យដែលប្រមូលបានពីតាមបណ្តាលខេត្តនីមួយៗត្រូវបានធ្វើការឡើងដើម្បីពិនិត្យមើលទៅលើនិន្នាការនៃទិន្នន័យ ភាពស្រដៀង

គ្នា និងភាពខុសប្លែកគ្នានៃការចុះអនុវត្តសកម្មភាពរបស់ក្រុមយុវនិស្សិតស្ម័គ្រចិត្ត ផ្អែកលើបរិបទក្នុងខេត្តគោលដៅនីមួយៗ។

សេចក្តីពង្រាងរបាយការណ៍នៃរបកគំហើញត្រូវបានពិនិត្យ និងផ្តល់អនុសាសន៍កាលពីខែកក្កដាដោយក្រុមការងារដែលបានស្ម័គ្រចិត្តចុះជួយប្រមូលព័ត៌មានសម្រាប់ដំណើរការចងក្រងឯកសារនេះ។

## 6. ភាពមានកម្រិតនៃការចងក្រងឯកសារ

ការចងក្រងឯកសារនេះ គឺជាកិច្ចផ្តួចផ្តើមចងក្រងបទពិសោធន៍របស់ប្រជាជនក្នុងភូមិមួយចំនួន ដែលធ្លាប់បានចូលរួមក្នុងដំណើរការចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្តចុះអនុវត្តបទបញ្ជា០១(បប)។ ការចងក្រងឯកសារនេះមិនបានព្យាយាមលើកឡើងថា បញ្ហា ឬការរកឃើញសំខាន់ៗដែលលើកឡើងក្នុងរបាយ-ការណ៍នេះ តំណាងឲ្យបញ្ហាដែលកើតឡើងនៅក្នុងភូមិផ្សេងទៀតនោះទេ (ទោះបីជាភូមិដែលនៅជាប់គ្នា ឬក្នុងស្រុកតែមួយ)។ នេះគឺជាការចងក្រងនូវបទពិសោធន៍ និងការយល់ឃើញរបស់ប្រជាជនចំពោះការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីដែលផ្តល់តាមរយៈការចុះវាស់វែងដីធ្លី ក្នុងរយៈការដំបូងនៃការមានប័ណ្ណកាន់នៅក្នុងដៃ (ប្រាំមួយខែ ឬតិចជាងនេះ) ក្នុងការមានប័ណ្ណបញ្ជាក់សិទ្ធិកម្មសិទ្ធិ។ ព័ត៌មានដែលផ្តល់តាមរយៈការនិយាយប្រាប់របស់ប្រជាជនឆ្លុះបញ្ចាំងពីការយល់ឃើញ ចំណាប់អារម្មណ៍ ក្តីបារម្ភ ការភ័យខ្លាច ក្តីសង្ឃឹម ក្តីរំពឹងទុក និងបទពិសោធន៍ជាក់ស្តែងក្នុងជីវិតរបស់ប្រជាជនដែលបានឆ្លងកាត់ការរំលោភបំពានសិទ្ធិកម្មសិទ្ធិដីធ្លី។

គួរកត់សំគាល់ថា ភាពប្រទាំងប្រទើសនៃការចុះវាស់វែងដីនៅក្នុងភូមិគោលដៅ និងបញ្ហាដែលកើតឡើងជុំវិញប្រសិទ្ធិភាពនៃប័ណ្ណកម្មសិទ្ធិដីធ្លីថ្មីរបស់ប្រជាជនមួយចំនួនគឺជាកម្មវត្ថុនៃការប្រមូលព័ត៌មានពីភូមិទាំងប្រាំនៅក្នុងស្រុកក្រគរ។ ក្នុងពេលប្រមូលព័ត៌មានដំណាក់កាលទីពីរ សកម្មជនដីធ្លីមួយរូបនៅក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ ត្រូវបានចាប់ខ្លួន ដោយសារតែសកម្មជនរូបនេះបានធ្វើការតស៊ូមតិលើប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ប្រជាជនមួយក្រុមដែលប័ណ្ណរបស់ពួកគាត់មិនមានប្រសិទ្ធិភាពប្រើប្រាស់ដើម្បីការពារដីរបស់គាត់។ ការចាប់ខ្លួនសកម្មជនរូបនេះ ធ្វើឲ្យប្រជាជនក្នុងមូលដ្ឋានដែលត្រូវចុះប្រមូលទិន្នន័យបន្ថែមមានការខ្លាចរអារ ក្នុងការលើកឡើងពីបទពិសោធន៍ និងផលប៉ះពាល់នានានៃការអនុវត្តបទបញ្ជា០១(បប) មកលើសហគមន៍គាត់ ដោយសារពួកគាត់មានក្តីបារម្ភពីផលប៉ះពាល់ចំពោះខ្លួនគាត់ និងក្រុមគ្រួសារក្រោយពីការផ្តល់ព័ត៌មាន។ ការចាប់ខ្លួនសកម្មជនរូបនេះក៏ជះឥទ្ធិពលលើដំណើរការនៃការចុះប្រមូលព័ត៌មានផងដែរ ព្រោះកិច្ចខិតខំប្រឹងប្រែងក្នុងមូលដ្ឋានបានបង្វែរមកលើសកម្មភាពតស៊ូមតិអហិង្សាសកម្ម ដើម្បីទាមទារឲ្យមានការដោះលែងសកម្មជនដែលត្រូវបានអាជ្ញាធរចាប់ខ្លួននេះ។

ដោយសារតែប្រធានបទនៃការទទួលប័ណ្ណកម្មសិទ្ធិដីធ្លី គឺមានលក្ខណៈរសើបខ្លាំង និងពាក់ពន្ធ័នឹងបញ្ហានយោបាយ ឈ្មោះមនុស្ស មិនត្រូវបានបញ្ចេញឲ្យដឹង ដើម្បីការពារសុវត្ថិភាព និងអត្តសញ្ញាណរបស់អ្នកចូលរួម លើកលែងតែករណីដែលមានការផ្សព្វផ្សាយជាសាធារណៈ។

# "ក្រុមយុវជនស្ម័គ្រចិត្តសម្ដេចតេជោ" ប្រវត្តិ និងបេសកកម្ម[1]









[1] រូបភាពផ្ដល់ដោយ កាសែតភ្នំពេញប៉ុស្ដិ៍

# ២.១ ប្រវត្តិ

ជម្លោះសិទ្ធិកម្មសិទ្ធិដីធ្លីនៅកម្ពុជា ធ្វើឲ្យមានការប៉ះពាល់ដល់ប្រជាជនពីបួនទៅប្រាំពីរសែន (៤០០,០០០ ទៅ ៧០០,០០០) នាក់ និងត្រូវបានគេចាត់ទុកថាជាបញ្ហាចំបងបំផុតនាសតវត្សទី២១ (Licadho, 2012; May & Worrell cited in Vize and Hurnung 2013,p.2)។ សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ បានបង្ហាញក្នុងរបាយការណ៍ឆ្នាំ២០១៣របស់ខ្លួនថា មានដីជាងពីរលានហិកតាត្រូវបានផ្ទេរតាមរយៈកម្មវិធីដីសម្បទាន។ បញ្ហាជម្លោះដីធ្លីនៅក្នុងប្រទេសកម្ពុជា កើតមានឡើងស្ទើរតែរៀងរាល់ថ្ងៃ ហើយយន្តការដែលបានដាក់ចេញកន្លងមកក្នុងការដោះស្រាយវិវាទទាំងនោះ មិនបានកាត់បន្ថយភាពធ្ងន់ធ្ងរនៃបញ្ហា និងផលប៉ះពាល់នៃជំលោះទាំងនោះមកលើជីវភាពរស់នៅរបស់ប្រជាជនក្រីក្រដែលភាគច្រើនជាជនរងគ្រោះនោះទេ។

នៅថ្ងៃទី៧ខែឧសភា ឆ្នាំ២០១២ នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជាបានដាក់ចេញបទបញ្ជាឲ្យផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុនឯកជន និងបានអំពាវនាវឲ្យមានការត្រួតពិនិត្យឡើងវិញនូវការអនុវត្តនានាលើកិច្ចសន្យានៃសម្បទានដីដែលមានស្រាប់ (Kuch & Seiff 2012; May 2012a)។ ការដាក់ចេញបទបញ្ជាថ្មីនេះត្រូវបានវិភាគថា គឺធ្វើឡើងដើម្បីឆ្លើយតបទៅនឹងជម្លោះដីធ្លីដ៏ក្តៅគគុកនៅកម្ពុជានាពេលបច្ចុប្បន្ន។

មួយខែក្រោយការចេញបទបញ្ជានេះ នៅថ្ងៃ១៤ ខែមិថុនា ឆ្នាំ២០១២ នាយករដ្ឋមន្ត្រីបានប្រកាសជាសាធារណៈនូវផែនការនៃយុទ្ធនាការចុះអនុវត្តការវាស់វែងដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធិស្របច្បាប់ជូនប្រជាពលរដ្ឋ ដែលអនុវត្តដោយស្ថាប័នក្រសួង និងអាជ្ញាធរពាក់ព័ន្ធនៅទូទាំងប្រទេសក្នុងរយៈពេល៦ខែ (May2012a)។ ដើម្បីឲ្យការអនុវត្តសកម្មភាពថ្មីនេះសម្រេចបានឆាប់រហ័សតាមផែនការដែលបានលើកឡើង នាយករដ្ឋមន្ត្រីកម្ពុជាបានអំពាវនាវសុំកំលាំងជំនួយបន្ថែមពីនិស្សិត ប្រសិនបើអាជ្ញាធរខ្វះកម្លាំង។ ក្រោយពីប្រសាសន៍របស់នាយករដ្ឋមន្ត្រី ការជ្រើសរើសនិស្សិតស្ម័គ្រចិត្តបានចាប់ផ្តើមដំណើរការ។

សេចក្តីអធិប្បាយខាងក្រោមនេះ បង្ហាញពីបទដ្ឋានគតិយុត្តនៃបទបញ្ជា០១(បប) ប្រវត្តិ និងការជ្រើសរើសក្រុមនិស្សិតស្ម័គ្រចិត្ត សមាសភាពនិស្សិត ដំណើរការជ្រើសរើសនិស្សិត ការគាំទ្រផ្នែកហិរញ្ញវត្ថុ ការគ្រប់គ្រងផែនការ ទំហំ និងសមិទ្ធិផលការងារដែលនិស្សិតស្ម័គ្រចិត្តបានអនុវត្តតាំងពីពេលចាប់ផ្តើមរហូតដល់ខែមិថុនា ឆ្នាំ២០១៣នេះ។

# ២.២ បទដ្ឋានគតិយុត្តនៃបទបញ្ជា០១(បប)

បទបញ្ជា០១(បប) មានខ្លឹមសារសំខាន់ៗបួន៖

- ទី១៖ ផ្អាកជាបណ្តោះអាសន្នការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មីដល់ក្រុមហ៊ុន។
- ទី២៖ ក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តឲ្យមានប្រសិទ្ធិភាពខ្ពស់ នូវគោលនយោបាយ និងរាល់លក្ខខណ្ឌទាំងឡាយនៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ច និងផ្តោតការយកចិត្តទុកដាក់ លើការអនុវត្តកិច្ចសន្យាស្តីពីសម្បទានដីសេដ្ឋកិច្ច

ជាពិសេសគឺការអនុវត្តគោលនយោបាយរូបមន្តស្បែកខ្លា[2] និងធានាថា សម្បទានដីសេដ្ឋកិច្ច មិនធ្វើឲ្យប៉ះពាល់ដល់ដីធ្លីសហគមន៍ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងគោលដៅធ្វើឲ្យសម្បទានដីសេដ្ឋកិច្ចទាំងនេះបានផ្តល់ផលប្រយោជន៍ពិតប្រាកដជូនដល់ប្រទេសជាតិ និងប្រជាជនប្រកបដោយនិរន្តរភាព។

– ទី៣៖ ចំពោះក្រុមហ៊ុនដែលមិនអនុវត្តតាមនិតិវិធីជាធរមាន និងកិច្ចសន្យា រដ្ឋាភិបាលនឹងដកហូតយកដីសម្បទានវិញ។
– ទី៤៖ បទបញ្ជានេះ មិនប៉ះពាល់ដល់ក្រុមហ៊ុនដែលបានទទួលការអនុញ្ញាតជាគោលការណ៍ពីរដ្ឋាភិ-បាលមុនថ្ងៃប្រកាសចេញបទបញ្ជាទេ។ (រាជរដ្ឋាភិបាលកម្ពុជា, ៧ ឧសភា ២០១២)។

និស្សិតស្ម័គ្រចិត្ត ពេលខ្លះត្រូវបានគេហៅថា **វីរៈនិស្សិត ឬយុវជនស្ម័គ្រចិត្ត ឬក្រុមយុវជនស្ម័គ្រចិត្តសម្តេចតេជោ** គឺជាយន្តការមួយនៃការចុះបំពេញបេសកម្មវាស់វែងដីធ្លីជូនដល់ប្រជាពលរដ្ឋនៅតាមតំបន់នៃប្រទេសកម្ពុជា ដែលកំពុងតែមានបញ្ហាដីធ្លី។ ដោយធ្វើការយ៉ាងជិតស្និត ជាមួយមន្ត្រីជំនាញនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងពាក់ព័ន្ធមួយចំនួនទៀត ក្រុមនិស្សិតស្ម័គ្រចិត្ត ធ្វើការវាស់វែងដីធ្លី និងបំពេញទម្រង់បែបបទនានា ព្រមទាំងធ្វើការចេញប័ណ្ណកម្មសិទ្ធិ ដីធ្លីជូនដល់ប្រជាពលរដ្ឋ។ ដោយឡែកនិស្សិតស្ម័គ្រចិត្ត មិនអាចធ្វើការវាស់វែងលើដីដែលកំពុងតែមានជំលោះ និងមិនទាន់បានដោះស្រាយរួចរាល់នោះទេ ហើយគ្មានសិទ្ធិក្នុងការធ្វើការដោះស្រាយជម្លោះដីធ្លីណាមួយឡើយ។ ក្រុមអ្នកវិភាគមួយចំនួន ហៅកម្មវិធីនៃការអនុវត្តបទបញ្ជា០១(បប) និងបេសកម្មរបស់ក្រុមយុវនិស្សិតស្ម័គ្រចិត្តថា ជាការអនុវត្តសកម្មភាពមួយដ៏មានមហិច្ឆិតា ដោយសារតែរយៈពេលនៃការអនុវត្តការងារខ្លី តែលទ្ធផលរំពឹងទុក គឺជាទំហំធំធេង ហើយការចាប់ផ្តើមអនុវត្តការងារមានសន្ទុះឆាប់រហ័ស ជាពិសេសក្នុងរយៈពេលប្រាំមួយខែដំបូង (ពីខែមិថុនា-ធ្នូ ឆ្នាំ ២០១២)។

មានការវិវត្តន៍ជាច្រើន និងឆាប់រហ័សផ្នែកខាងបទដ្ឋានគតិយុត្ត ដើម្បីសម្របសម្រួលដំណើរការអនុវត្តបទបញ្ជា០១(បប) ចុះវាស់វែងដីធ្លី។ នៅលើគេហទំព័ររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានដាក់ផ្សាយ*កម្រងឯកសារណែនាំ ស្តីពីការអនុវត្តបទបញ្ជា០១(បប) ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច។* លើសពីនេះទៀត ចាប់តាំងពីការប្រកាសនូវបទបញ្ជា០១(បប) កាលពីខែឧសភា ឆ្នាំ២០១២ មានលិខិតបទដ្ឋានគតិយុត្ត (ក្រឹត្យ និងអនុក្រឹត្យ) ប្រមាណ២០០ ដែលត្រូវបានចេញដើម្បីគាំទ្រ និងផ្តល់ភាពស្របច្បាប់និងសម្រួលដល់ដំណើរការនៃការប្រព្រឹត្តិទៅ និងការអនុវត្តបទបញ្ជា០១(បប) ឲ្យមានប្រសិទ្ធិភាព(សន្ទរកថារបស់នាយករដ្ឋមន្ត្រី ចុះផ្សាយនៅក្នុង *Cambodia New Vision*, ខែមករា ២០១៣)។ ការប្រែប្រួលយ៉ាងឆាប់រហ័ស និងការចេញលិខិតបទដ្ឋានគតិយុត្តក្នុងចំនួនច្រើនបែបនេះមិនធ្លាប់កើតមានទេ នៅក្នុងកិច្ចការងារកំណែទម្រង់របស់រដ្ឋាភិបាល។

[2] មានន័យថា សម្បទានដីសេដ្ឋកិច្ច គឺត្រូវវាស់តាមជាយព្រៃ និងដី ដែលសំខាន់សម្រាប់សហគមន៍មូលដ្ឋាន បង្កើតនូវបំណែកនៃការកាន់កាប់ដី ដែលដូចទៅនឹងស្បែកខ្លា។

## ២.៣ ការជ្រើសរើស និងសមាសភាពនិស្សិតស្ម័គ្រចិត្ត

បន្ទាប់ពីការប្រកាសការអនុវត្តបទបញ្ជាលេខ០១(បប) របស់នាយករដ្ឋមន្ត្រីហ៊ុន សែន មានការចាប់ផ្តើមប្រកាសជ្រើសរើសនិស្សិតស្ម័គ្រចិត្ត ដើម្បីបន្ថែមកំលាំងជំនួយ និងពន្លឿនដំណើរការចុះវាស់វែងដីធ្លី (ADHOC, ២០១៣)។ ការជ្រើសរើសនេះ មានសភាពលឿន និងឆាប់រហ័ស ហើយក្នុងរយៈពេលប្រមាណមួយខែប៉ុណ្ណោះ ក្នុងខែមិថុនា ឆ្នាំ១០១២ និស្សិតស្ម័គ្រចិត្តប្រមាណជាងមួយពាន់នាក់ត្រូវបានរើសមកពីបណ្តាបណ្តាញសមាគមនិស្សិត និងសាកលវិទ្យាល័យនានា។ តាមព័ត៌មានពីនិស្សិតមួយចំនួនដែលកំពុងសិក្សានៅតាមមហាវិទ្យាល័យក្នុងក្រុងភ្នំពេញបានឲ្យដឹងថា ការជ្រើសរើសនេះប្រហែលជាត្រូវបានបិទប្រកាសនៅតាមសាកលវិទ្យាល័យ និងមហាវិទ្យាល័យនានានៅក្នុងទីក្រុងភ្នំពេញ (ប្រភព៖ ការទំនាក់ទំនងផ្ទាល់ខ្លួន)។ ការសម្ភាសន៍ជាមួយនិស្សិតដែលសិក្សានៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំការដូង ជំនាញរៀបចំដែនដីបញ្ជាក់ថា គ្រប់និស្សិតដែលសិក្សាពីឆ្នាំទីពីរ ដល់ឆ្នាំទីបួនទាំងអស់ ត្រូវបានសាកលវិទ្យាល័យតម្រូវឲ្យចូលរួមស្ម័គ្រចិត្តក្នុងការចុះវាស់វែងដីធ្លីនេះ។

> *"នៅមហាវិទ្យាល័យរបស់ខ្ញុំ តម្រូវឲ្យនិស្សិតទៅចូលរួមជាមួយនឹងការអនុវត្តបទបញ្ជា០១(បប) នេះដោយសារតែត្រូវជាមួយនឹងជំនាញដែលនិស្សិតកំពុងសិក្សា។ និស្សិតដែលសិក្សានៅសាកលវិទ្យាល័យកសិកម្មចំការដូង ចាប់ពីឆ្នាំទីពីរ ដល់ឆ្នាំទីបួន គឺសាលាតម្រូវឲ្យយើងទៅចូលរួមក្នុងសកម្មភាពនេះគ្រប់ថ្នាក់ ពិសេសគ្រប់និស្សិតទាំងអស់ដែលកំពុងរៀនជំនាញរៀបចំដែនដី..."* កិច្ចសម្ភាសន៍និស្សិតស្ម័គ្រចិត្ត, ខែមិថុនា ឆ្នាំ២០១៣។

បើយោងតាមការពិនិត្យទៅលើឈ្មោះសមាគមនិងទំនោរផ្នែកនយោបាយបង្ហាញថា និស្សិតស្ម័គ្រចិត្តដែលត្រូវបានជ្រើសរើស ភាគច្រើនលើសលុប ត្រូវបានរើសចេញពីសមាគមនិស្សិតតាមបណ្តាសកលវិទ្យាល័យនានានៅទីក្រុងភ្នំពេញដែលសមាគមទាំងនេះមានទំនោរទៅកេគណបក្សប្រជាជនកម្ពុជា។ គេអាចសន្និដ្ឋានបានថា ការប្រកាសជ្រើសរើសនិស្សិតគឺ ត្រូវបានធ្វើតាមរយៈបណ្តាញសមាគមនិស្សិតទាំងនេះ ព្រោះគ្រាន់តែសហព័ន្ធនិស្សិតបញ្ញវន្តប្រជាធិបតេយ្យកម្ពុជាមួយមានសមាជិករហូតដល់ទៅ២២សមាគមនិស្សិត (CDSIF, ២០០៩)។ បន្ថែមពីលើនេះទៀត សកម្មជនគណបក្សប្រជាជនកម្ពុជានៅតាមបណ្តាសាកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំនានាជាភ្នាក់ងារដ៏សំខាន់ដើរតួនាទីក្នុងការគៀងគរនិស្សិតឲ្យចូលរួមក្នុងចលនាវាស់វែងដីធ្លីនេះ។ តារាងខាងក្រោមសង្ខេបចំនួននិស្សិតស្ម័គ្រចិត្តដែលបានជ្រើសរើសមកពីស្ថាប័ននីមួយៗ។

*តារាងទី២៖ ចំនួននិស្សិតស្ម័គ្រចិត្ត តាមស្ថាប័ន*

| ល.រ | ឈ្មោះស្ថាបន័ | ចំនួននិស្សិត |
|---|---|---|
| ១ | សាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង | ៣៩១ នាក់ |
| ២ | សមាគមសិស្សនិស្សិតបញ្ញាវ័ន្តក្មេងវត្ត | ៣១២ នាក់ |
| ៣ | សហព័ន្ធនិស្សិតបញ្ញវន្តប្រជាធិបតេយ្យកម្ពុជា | ២១៦ នាក់ |
| ៤ | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ៨៣ នាក់ |

| | | |
|---|---|---|
| ៥ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | ៥១នាក់ |
| ៦ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ៣៥ នាក់ |
| ៧ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ | ១២ នាក់ |
| | **សរុប** | **១,១០០ នាក់** |

ប្រភព៖ គេហទំព័រ Cambodia New Vision (2012a) និង Khmerlivetv (2013)

នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា នាឱកាសបិទផែនការសកម្មភាពជំហានទីមួយ កាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០១៣ បានថ្លែងអំណរគុណ ដល់បណ្តាសមាគមនិស្សិតចំនួនប្រាំពីរ[3] ដែលបានចូលរួមយ៉ាងសកម្មក្នុងដំណើរការអនុវត្តយុទ្ធនាការចុះវាស់វែងដីធ្លី។ សមាគមនិស្សិតទាំងនេះត្រូវបានស្គាល់ថា ជាបណ្តាញសកម្មដែលមានឆន្ទៈនយោបាយគាំទ្រដល់គណបក្សប្រជាជនកម្ពុជាដូចជាសមាគមក្មេងវត្តជាដើម។ និស្សិតស្ម័គ្រចិត្ត ក៏ត្រូវបានជ្រើសរើសចេញមកពីសាកលវិទ្យាល័យ និងមហាវិទ្យាល័យឯកជននានានៅទីក្រុងភ្នំពេញ និងមានយុវជនខ្លះទៀត ជាបុគ្គលិកបម្រើការងារនៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ជាក់ស្តែង និស្សិតស្ម័គ្រចិត្តក្រុមទី១១៨ ដែលចុះទៅវាស់ដីនៅខេត្តកែប មាននិស្សិតមកពីមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច វិទ្យាស្ថានជាតិគ្រប់គ្រង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យធនធានមនុស្ស វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសច្ចៈ សាកលវិទ្យាល័យបៀលប្រាយ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម (Kolbot Khmer 2013a)។ ក្រៅពីនិស្សិតដែលមកពីសាកលវិទ្យាល័យ និងវិទ្យាស្ថានទាំងនេះ នៅមាននិស្សិតមកពីសាកលវិទ្យាល័យន័រតុន សាកលវិទ្យាល័យឯកទេសនៃកម្ពុជា សាកលវិទ្យាល័យមេគង្គកម្ពុជា និងសាកលវិទ្យាល័យអាស៊ីអឺរ៉ុប និងសាលាជាតិកសិកម្មព្រែកលៀបជាដើម។ ដោយឡែក និស្សិតដែលជ្រើសរើសចេញមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង មាននិស្សិតដែលសិក្សាជំនាញរៀបចំដែនដី និងរដ្ឋបាលដីធ្លីផងដែរ (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ២០១២)។

# ២.៤ ការបណ្តុះបណ្តាលនិស្សិតស្ម័គ្រចិត្ត

មុននឹងចុះធ្វើសកម្មភាពវាស់វែងដីធ្លី និស្សិតទាំងអស់ត្រូវបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងមុខងារ តួនាទី ជំនាញវាស់វែង និងការប្រើប្រាស់ឧបករណ៍បច្ចេកទេស (ដូចជាឧបករណ៍ជីភីអេសជាដើម) ដែលបណ្តុះបណ្តាលដោយមន្ត្រីជំនាញមកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ការបណ្តុះបណ្តាលនេះ មានគោលបំណងបង្ហាត់បង្ហាញនិស្សិតអំពីភាពជាអ្នកដឹកនាំ និងពង្រឹងគោលដៅនៃបេសកកម្មវាស់ដីធ្លី ។ ការបណ្តុះបណ្តាលមានរយៈពេលមួយសប្តាហ៍ (Muller & Zulsdorf, 2013)។

***"ខ្ញុំបានលឺថា ការបណ្តុះបណ្តាល គឺផ្តោតលើទម្រង់បែបបទក្នុងការបំពេញក្បាលដី, ច្បាប់ភូមិបាល, ការចុះវាស់វែង, វិធីក្នុងការប្រើជីភីអេស... ខ្ញុំមិនដឹងទាំងអស់ទេ ពីព្រោះខ្ញុំមិនបានចូលរៀនដូចនិស្សិតផ្សេង***

---

[3] នាយករដ្ឋមន្ត្រីបានថ្លែងអំណរគុណដល់សមាគមនិស្សិតចំនួន៧៖ កុលបុត្រខ្មែរ, សហភាពសហព័ន្ធយុវជនកម្ពុជា, សមាគមសិស្ស, សហព័ន្ធនិស្សិតបញ្ញវន្តប្រជាធិបតេយ្យកម្ពុជា(ក២២), សមាគមសិស្សនិស្សិតបញ្ញវន្តក្មេងវត្ត, សកម្មជនគណបក្សប្រជាជនកម្ពុជានៅតាមគ្រឹះស្ថានឧត្តមសិក្សានៅរាជធានីភ្នំពេញ(ក៧៧) និងសមាគមនិស្សិតមូស្លីមកម្ពុជា ចំពោះការចូលរួមយ៉ាងសកម្មនិងផុសផុលរបស់សមាគមក្នុងការអនុវត្តវាស់វែងដីធ្លី (Cambodia New Vision 2013, Khmerlivetv 2013)

*ទៀត ព្រោះក្រុមខ្ញុំជាយុវជនមកពីក្រសួង (រៀបចំដែនដី) ត្រូវបញ្ជូនទៅភ្លាម ក្រោយពេលមានការចោត់តាំង។"* អតីតប្រធានក្រុមនិស្សិតស្ម័គ្រចិត្ត, ខែមិថុនា ឆ្នាំ២០១៣

ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និស្សិតស្ម័គ្រចិត្តមានតួនាទីត្រឹមតែធ្វើការវាស់វែងដីធ្លី តាមនិតិវិធីដែលបានណែនាំ ដោយឧត្តមក្រុមប្រឹក្សាជាតិកំណែទម្រង់ដី។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសង្កត់ធ្ងន់ថា "ជម្លោះដីធ្លីមិនមែនជាតួនាទីរបស់និស្សិតស្ម័គ្រចិត្តទេ" (Khuon, 2013)។ ជាទូទៅ និស្សិតបានបដិសេធមិនវាស់វែងដីឲ្យប្រជាជនទេ បើសិនជាដីនោះស្ថិតនៅក្នុងបរិវេណដីដែលមានទំនាស់។ ព័ត៌មានដែលទទួលបានពីប្រជាជនក្នុងមូលដ្ឋានផ្តល់ការអះអាងបន្ថែមទៀត ថាដីដែលមានទំនាស់គឺមិនត្រូវបានធ្វើការវាស់វែងទេ។ ជាក់ស្តែង ប្រជាជនចំនួន៣០០គ្រួសារ នៅខេត្តពោធិ៍សាត់ បានអះអាងថា និស្សិតមិនព្រមវាស់វែងដីឲ្យពួកគាត់ ដោយពួកគេយល់ឃើញថា ដីរបស់ពួកគាត់កំពុងមានទំនាស់លើដីសម្បទានសង្គមកិច្ចរបស់រដ្ឋាភិបាល (May, 2013d)។

ការសិក្សាមួយស្តីពីផលប៉ះពាល់នៃការចុះវាស់វែងដីធ្លីក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគិរី បានធ្វើការរិះគន់ដល់ក្រុមយុវជនស្ម័គ្រចិត្តចុះវាស់វែងដីធ្លីក្នុងខេត្ត ដែលមានប្រជាជនភាគច្រើនជាជនជាតិដើមភាគតិច តែយុវជន "*...មិនបានទទួលបានការបណ្តុះបណ្តាលពីរបៀបរស់នៅ និងទំនៀមទំលាប់ប្រពៃណីរបស់បងប្អូនជនជាតិដើមភាគតិច...*" (Rabe, ២០១២, ទ.២៤)។ ភាពខ្វះចន្លោះរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត ខាងផ្នែកចំណេះដឹង ទំនៀមទម្លាប់ និងបរិបទជាក់លាក់របស់ជនជាតិដើម ត្រូវបានរិះគន់ថា បង្កអោយមានផលប៉ះពាល់ទៅលើដំណើរការនៃទំនាក់ទំនង ក្នុងការសម្រេចចិត្តរបស់គ្រួសារជនជាតិភាគតិចមួយចំនួន ដែលទទួលយកការវាស់វែងដីជាលក្ខណៈកម្មសិទ្ធិឯកជនជាជាងដីសហគមន៍ ក្រោយពីស្តាប់ការផ្តល់ព័ត៌មាន(មិនត្រឹមត្រូវ) ពីសំណាក់និស្សិតមួយចំនួនដែលចុះធ្វើការក្នុងមូលដ្ឋាន (Rabe, 2012)។

ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលនិស្សិត អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ បណ្ឌិត ស៊ូរីយ៉ា ស៊ូប៊ីឌី (Surya Subedi) ធ្លាប់ផ្ញើលិខិតទៅក្រសួងការបរទេស លើកឡើងពីក្តីកង្វល់ស្តីពីយុវជនទទួលបានការបណ្តុះបណ្តាលតិចពេកមុនចុះវាស់វែងដីធ្លី។ ក្តីបារម្ភនេះត្រូវបានរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញលិខិតឆ្លើយតប។ នៅក្នុងលិខិតឆ្លើយបំភ្លឺទៅក្រសួងការបរទេស លោករដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** បានអះអាងបញ្ជាក់ថា និស្សិតស្ម័គ្រចិត្តគ្រាន់តែជាកម្លាំងជំនួយក្រុមបច្ចេកទេសវាស់វែង ហើយពួកគេធ្វើផងរៀនផងក្រោមការណែនាំជាក់ស្តែងជាប្រចាំពីសំណាក់ក្រុមបច្ចេកទេសវាស់វែង។ លើសពីនេះ និស្សិតស្ម័គ្រចិត្តខ្លះជានិស្សិតឆ្នាំទីបី ឬទីបួន ឬបានបញ្ចប់ការសិក្សាហើយ និងខ្លះសិក្សាខាងជំនាញរៀបចំដែនដី និងរដ្ឋបាលដីធ្លីផងដែរ។ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានច្រានចោលនូវក្តីបារម្ភរបស់អ្នករាយការណ៍ពិសេសថា"*...ជាក្តីបារម្ភដែលមិនដឹងពីស្ថានភាពជាក់ស្តែងនៃការអនុវត្តការងារ...*" (MLMUPC, ២០១២)។

ទោះជាមានការបញ្ជាក់អះអាងបែបនេះក៏ដោយ នៅក្នុងពេលចុះបំពេញភារកិច្ចការងារ និស្សិតស្ម័គ្រចិត្តម្នាក់ៗមានតួនាទីរៀងៗខ្លួន។ ដូច្នេះលទ្ធភាពនៃមន្ត្រីជំនាញ និងគ្រូតំណាងពីក្រសួងក្នុងការផ្តល់ការបង្វឹកបន្ថែមបានដល់កម្រិតណានៅពេលក្រុមនិស្សិតចុះអនុវត្តការងារនៅមូលដ្ឋាននោះគឺនៅតែជាសំណួរដដែល។

ករណីប័ណ្ណកម្មសិទ្ធិដីត្រួតស៊ីគ្នារបស់ប្រជាជននៅចំណុចដំណាក់ព្រីង ក្នុងភូមិក្បាលត្រាច ខេត្តពោធិ៍សាត់ (ពិភាក្សានៅផ្នែកបន្ទាប់) និងបញ្ហាដែលកើតចេញពីកំហុសបច្ចេកទេសនៃការវាស់វែងនៅក្នុងភូមិ

មួយចំនួនទៀតបណ្តាលឲ្យមានការងឿងឆ្ងល់ពីប្រសិទ្ធិភាព និងសុក្រឹតភាពនៃការងារវាស់វែងដីធ្លី និងចំណេះដឹងរបស់និស្សិតស្ម័គ្រចិត្តដែលជាអ្នកបញ្ជាឧបករណ៍វាស់វែង។

## ២.៥. ផែនការនៃការវាស់វែងដីនិងផលសម្រេច

> ***"ក្នុងមួយថ្ងៃ វាស់យ៉ាងច្រើនណាស់បាន១០ក្បាលដីក្នុងមួយក្រុមតូច។ បើតិចបំផុត គឺពីរក្បាលដី (ជាពិសេស នៅពេលដែលទីតាំងដីនៅកាន់តែជ្រៅទៅៗ)។ ក្នុងពេលវាស់វែង ក្រុមខ្លះត្រូវដើរឆ្ងាយណាស់។ ប្រសិនបើដីទំហំមួយហិកតា គឺមិនអីទេ តែប្រសិនបើប្រាំហិកតាវិញ គឺយើងត្រូវដើរឆ្ងាយខ្លាំងមែនទែន (ធ្លាក់អណ្តាត)។"*** អតីតនិស្សិតស្ម័គ្រចិត្ត, ខែមិថុនា ឆ្នាំ២០១៣។

ក្នុងការចុះអនុវត្តការវាស់វែងដីធ្លី និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបែងចែកជា១៦៨ក្រុម (May, 2012e) ហើយនិស្សិតមួយក្រុមមានសមាជិក១២នាក់។ យុទ្ធនាការចុះវាស់វែងដីធ្លី ចែកចេញជាពីរដំណាក់កាល។

### ក. ដំណាក់កាលទី១

ដំណាក់កាលទី១ មានរយៈពេលប្រាំមួយខែ ចាប់ផ្តើមអនុវត្តចាប់ពីចុងខែមិថុនារហូតដល់ខែធ្នូ ឆ្នាំ២០១២។ ក្នុងដំណាក់កាលនេះ ក្រុមនិស្សិតស្ម័គ្រចិត្តបានចេញដំណើរបួនលើក។ លើកទីមួយ បានចេញដំណើរនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ មាននិស្សិតស្ម័គ្រចិត្តទាំងអស់៧៣៤នាក់ ចែកចេញជា៦១ក្រុម ដើម្បីជួយដល់ការងារមន្ត្រីពាក់ព័ន្ធ និងជំនាញបច្ចេកទេសវាស់វែងដីទូទាំងប្រទេស។ ការចេញដំណើរលើកទី២ បានប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ ដោយមាននិស្សិតស្ម័គ្រចិត្តច្រើនជាង៤៤៤នាក់ ហើយចែកចេញជា៣៥ក្រុម (May, 2012e)។ គោលបំណងនៃការបញ្ជូនក្រុមនិស្សិតជិត១២០០នាក់ គឺដើម្បីសំរេចផែនការវាស់វែងក្នុងដំណាក់កាលទី១ លើផ្ទៃដីទំហំសាមសិបប្រាំម៉ឺន(៣៥០,០០០) ហិកតា ដែលមានម្ចាស់កម្មសិទ្ធិប្រមាណជាងមួយសែនគ្រួសារ។

បើយោងតាមព័ត៌មានពី*កាសែតភ្នំពេញប៉ុស្តិ៍* (May, 2012f) រាយការណ៍ថា ខេត្តគោលដៅក្នុងដំណាក់កាលទីមួយនេះមាន៖ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តរតនគីរី ខេត្តមណ្ឌលគីរី និងខេត្តស្ទឹងត្រែង។ សមិទ្ធិផលរបស់ក្រុមនិស្សិតស្ម័គ្រចិត្តនិងមន្ត្រីពាក់ព័ន្ធ បានវាស់វែងផ្ទៃដីទំហំបីសែនបួនម៉ឺន (៣៤០,០០០) ក្បាលដីលើផ្ទៃដីទំហំហាសិបប្រាំបីម៉ឺន (៥៨០,០០០) ហិកតា ដោយកំណត់ទំហំជាមធ្យម ១.៧ ហិកតាក្នុងមួយគ្រួសារ។ ដោយប៉ាន់ប្រមាណថា ប្រជាជនមួយគ្រួសារមានសមាជិកប្រាំនាក់ ចំនួននេះតំណាងឲ្យប្រជាជនប្រមាណ១.៥ លាននាក់ (May, 2012f)។

ក្នុងបេសកម្មចុះវាស់វែងដីធ្លីដំណាក់កាលទីមួយ និស្សិតស្ម័គ្រចិត្តបានទទួលការឈប់សម្រាកចំនួនបីលើក។ ការឈប់សម្រាកលើកទីមួយ គឺនៅក្នុងខែកញ្ញា ដែលមានកាលបរិច្ឆេទខុសគ្នា សម្រាប់ក្រុមផ្សេងគ្នា (សូមមើលតារាងខាងក្រោម)។ ការឈប់សម្រាកលើកទីពីរ គឺសម្រាប់ទិវាបុណ្យភ្ជុំបិណ្ឌ គឺរវាងថ្ងៃទី១៣-១៧ ខែតុលា ឆ្នាំ២០១២។ ចំណែកការឈប់សម្រាកលើកទីបី មានរយៈពេលប្រាំមួយថ្ងៃ ដើម្បីចូលរួមទិវាបុណ្យអុំទូក អកអំបុក សំពះព្រះខែ ហើយពួកគេបានត្រឡប់ទៅបំពេញការងារវិញនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១២

(ឧត្តមក្រុមប្រឹក្សារដ្ឋកំណែទម្រង់ដី, ២០១២)។ ក្រុមនិស្សិតបានបញ្ចប់បេសកកម្មវាស់វែងដីដំណាក់កាលទី១ នៅថ្ងៃទី២៦ធ្នូ ឆ្នាំ២០១២ (Kolbot Khmer, 2012f)។

តារាងទី៣៖ ការឈប់សម្រាករបស់ក្រុមនិស្សិតស្ម័គ្រចិត្ត

| ខែ | កាលបរិច្ឆេទឈប់សម្រាក | សមាសភាគ |
|---|---|---|
| កញ្ញា ២០១២ | ២-៨ ខែកញ្ញា | ក្រុមចេញដំណើរជំហានទី១ និងទី២ |
| | ១៦-២២ ខែកញ្ញា | ក្រុមចេញដំណើរជំហានទី៣ និងទី៤ |
| តុលា ២០១២ | ១៣-១៨ ខែតុលា | ក្រុមយុវជនស្ម័គ្រចិត្ត ក្រុមមន្ត្រីបច្ចេកទេស គ្រូពេទ្យ និងក្រុមដឹកជញ្ជូន |
| វិច្ឆិកា ២០១២ | ២៥-៣០ ខែវិច្ឆិកា | ក្រុមយុវជនស្ម័គ្រចិត្ត ក្រុមមន្ត្រីបច្ចេកទេស គ្រូពេទ្យ និងក្រុមដឹកជញ្ជូន |
| ធ្នូ ២០១២ | ២៦-៣០ ខែធ្នូ | ក្រុមយុវជនស្ម័គ្រចិត្ត ក្រុមមន្ត្រីបច្ចេកទេស គ្រូពេទ្យ និងក្រុមដឹកជញ្ជូន |

ប្រភព៖ សេចក្តីជូនដំណឹងរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី (២៨ សីហា ២០១២)

សកម្មភាពចុះវាស់វែងដីធ្លីដំណាក់កាលទីមួយ ត្រូវបានបញ្ចប់ដោយមានពិធីជប់លៀងដល់និស្សិតស្ម័គ្រចិត្ត និងក្រុមការងារជំនាញ។ នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជានិងភរិយា បានចូលរួមនៅក្នុងពិធីជប់លៀងនេះ និងបានថ្លែងអំណរគុណដល់ការចូលរួមរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត បុគ្គលិកជំនាញ និងស្ថាប័នពាក់ព័ន្ធដែលចូលរួមគាំទ្រ និងសម្រេចការងារនៅក្នុងជំហាននេះ។

## ខ. ដំណាក់កាលទី២

ដំណាក់កាលទី២ នៃយុទ្ធនាការចុះវាស់វែងដីធ្លីចាប់ផ្តើមនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៣ និងអនុវត្តដល់ថ្ងៃទីចុងខែមិថុនា ឆ្នាំ២០១៣។ មាននិស្សិតស្ម័គ្រចិត្តសរុបចំនួន ២,០០០នាក់ (Mesa, ២០១៣)។ ក្នុងចំណោមនិស្សិតស្ម័គ្រចិត្ត ២,០០០នាក់នេះមាននិស្សិតថ្មីចំនួន ១,៣៦២នាក់ ដែលបានជ្រើសរើសបន្ថែមសម្រាប់ដំណាក់កាលទី២ ក្រៅពីនោះគឺជានិស្សិតដែលធ្លាប់បានចុះបំពេញបេសកម្មក្នុងដំណាក់កាលមុន[4] (Mesa, ២០១៣)។ ក្នុងដំណាក់កាលទី២ និស្សិតស្ម័គ្រចិត្ត ត្រូវចុះទៅធ្វើការវាស់វែងដីធ្លី នៅក្នុងខេត្តចំនួន ១៩ខេត្ត លើផ្ទៃដីទំហំប្រមាណជាមួយលានហិកតា។ ផែនការវាស់វែងដីនេះ ត្រូវបានរំពឹងថានឹងសម្រេចឲ្យបាន ៥០%នៅមុនថ្ងៃបោះឆ្នោតជាតិ និង៥០%ទៀតត្រូវបន្តអនុវត្តក្រោយពីការបោះឆ្នោតជាតិ និងធ្វើបន្តទៀតរហូតដល់ខែមិនាឆ្នាំ២០១៤ (Mesa, 2013)។ នៅដំណាក់កាលទី២នេះ និស្សិតបានឈប់សម្រាកដើម្បីចូលរួមក្នុងទិវាបុណ្យចូលឆ្នាំខ្មែរ (Khoun, 2013)។ ដំណាក់កាលទី២ នៃបេសកកម្មចុះវាស់វែងដីធ្លី ត្រូវបញ្ចប់នៅថ្ងៃ

[4] ការសម្ភាសន៍ជាមួយមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និស្សិតដែលស្ម័គ្រចិត្តក្នុងដំណាក់កាលទី១ ដែលបានប្រឡងជាប់ គឺក្លាយជាមន្ត្រីជំនាញពីក្រសួងដែលចុះបំពេញការងារជាមួយនឹងនិស្សិតថ្មីដែលត្រូវបានជ្រើសរើស។ និស្សិតចាស់ៗ ក្នុងដំណាក់កាលទី១ អាចបន្តស្ម័គ្រចិត្តក្នុងដំណាក់កាលទី២បាន ប្រសិនបើពួកគេមិនត្រូវត្រឡប់ទៅបញ្ចប់ការសិក្សាទេនោះ។

ទី២០ ខែមិថុនា ឆ្នាំ២០១៣ គឺនៅមុនពេលការបោះឆ្នោតជាតិ (ការសម្ភាសន៍ប្រធានក្រុមនិស្សិតស្ម័គ្រចិត្ត, ខែឧសភា ២០១៣)។

ក្នុងកំឡុងពេលនៃការសរសេររបាយការណ៍នេះ ការអនុវត្តសកម្មភាពចុះវាស់វែងដីធ្លីក្នុងដំណាក់កាលទី២ ត្រូវបានបញ្ចប់។ លទ្ធផលនៃការអនុវត្តបទបញ្ជា០១(បប) នៅទូទាំងប្រទេស គិតចាប់ពីថ្ងៃចាប់ផ្តើមរហូតមកទល់នឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ បានសម្រេចចែកប័ណ្ណដល់ដៃប្រជាជន ៣៦១,៧៣៤ ប័ណ្ណ ផ្ទៀងផ្ទាត់អ្នកកាន់កាប់ដីចំនួន ៤២៦,៩០៧ គ្រួសារ វាស់ក្បាលដីទំហំបាន ៩៦២,៧០៧ ហិកតា (MLMUPC, 2013)។

## ២.៦ ការឧបត្ថម្ភគាំទ្រលើសកម្មភាពការងារអនុវត្តបទបញ្ជា ០១(បប)

> ***"ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនប្រើប្រាស់ថវិកាជាតិទេ ដើម្បីគាំទ្រដល់យុវជនស្ម័គ្រចិត្តទេ។ ខ្ញុំប្តេជ្ញាចិត្ត ដើម្បីឧបត្ថម្ភដល់ពួកគេ នឹងធ្វើឲ្យបេសកម្មចុះវាស់វែងដីធ្លីរបស់ពួកគេ ដំណើរការ។"*** (នាយករដ្ឋមន្ត្រីកម្ពុជា CNV **លេខ១៧២ /ខែមិថុនា ឆ្នាំ២០១២**a.)

*"បេសកម្មវាស់វែងដីធ្លី នឹងមិនអាចកើតឡើងទេ បើគ្មានការឧបត្ថម្ភពីគណបក្សប្រជាជនកម្ពុជា។"* ជាប្រសាសន៍លើកឡើងរបស់ ឯកឧត្តម **អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** នៅក្នុងពិធីសំណេះសំណាលជាមួយយុវនិស្សិតស្ម័គ្រចិត្ត នៅសាលមហោស្រពកោះពេជ្រ កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៣ (KolbotKhmer, 2013b) ។ យោងតាមប្រភពព័ត៌មានរបស់វិទ្យុអាស៊ីសេរី និងរបាយការណ៍របស់ Vize et al. (២០១៣) នាយករដ្ឋមន្ត្រីកម្ពុជា និងសមាជិកគណបក្សប្រជាជនកម្ពុជា ជាអ្នករ៉ាប់រងលើការចំណាយប្រាក់ឧបត្ថម្ភចំពោះនិស្សិតស្ម័គ្រទាំងអស់ ដោយផ្តល់ថវិកាផ្ទាល់ខ្លួន សម្រាប់គាំទ្រកម្មវិធីនេះ (RFA, ២០១២; Vize et al., ២០១៣)។ *កាសែតភ្នំពេញប៉ុស្តិ៍* ក៏រាយការបន្ថែមថា លោកនាយករដ្ឋមន្ត្រី និងភរិយា ជាអ្នករ៉ាប់រងនូវរាល់ការចំណាយ ទាំងថវិកា និងសម្ភារៈប្រើប្រាស់ចាំបាច់ទាំងអស់សម្រាប់ក្រុមនិស្សិតស្ម័គ្រចិត្ត ដោយធ្វើការធានាថា នឹងមិនឲ្យប៉ះពាល់ដល់ថវិកាជាតិ (May, 2012a)។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានដែលអាចរកបាន មិនបានបញ្ជាក់ច្បាស់ថា តើសមាជិកណាខ្លះ នៃគណបក្សប្រជាជនកម្ពុជា ជាអ្នករ៉ាប់រងលើការចំណាយនោះទេ។

អត្ថបទដែលចុះផ្សាយនៅលើទំព័រ*កាសែតចាការតា គ្លូប* (Fitzpatrick, 2012) បានឲ្យដឹងថា និស្សិតស្ម័គ្រចិត្តម្នាក់ៗបានទទួលប្រាក់ឧបត្ថម្ភចំនួន ២២០ ដុល្លារអាមេរិកក្នុងមួយខែ។ ក្នុងសុន្ទរកថានាពិធីសំណេះសំណាលផ្តាំផ្ញើដល់ក្រុមនិស្សិតស្ម័គ្រចិត្ត នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** មានប្រសាសន៍បញ្ជាក់ថា សម្តេចឧបត្ថម្ភដល់យុវនិស្សិតស្ម័គ្រចិត្តម្នាក់ៗក្នុងទឹកប្រាក់ចំនួន ៣០,០០០រៀល (បីម៉ឺនរៀល) ក្នុងមួយថ្ងៃ ស្មើនឹង ៩០០,០០០រៀល[5] (កៅសិបម៉ឺនរៀល) ក្នុងមួយខែសម្រាប់និស្សិតម្នាក់ៗ (CNV, 2012b)។ និស្សិតស្ម័គ្រចិត្តទាំងអស់ មិនថាមានតួនាទីជាប្រធានក្រុមនិស្សិត ឬសមាជិកទេ គឺទទួលបានថវិកាឧបត្ថម្ភស្មើៗគ្នា (ប្រភព៖ កិច្ចសម្ភាសន៍អតីតប្រធានក្រុមនិស្សិតស្ម័គ្រចិត្ត, ខែមិថុនា ២០១៣)។ គួររំលឹកថា ទឹកប្រាក់ឧបត្ថម្ភដល់យុវនិស្សិតស្ម័គ្រចិត្តនេះ មានចំនួនខ្ពស់លើសពីប្រាក់បៀវត្សន៍របស់មន្ត្រីរាជការ

[5] ប្រហែលជា ២២០ដុល្លាក្នុងមួយខែ ក្នុងអត្រាប្តូរប្រាក់ ៤០០០រៀលក្នុងមួយដុល្លា

ធម្មតា។ ក្នុងពិធីជប់លៀងបញ្ចប់ការចុះវាស់វែងដីធ្លីជំណាក់កាលទី១[6] លោកនាយករដ្ឋមន្ត្រី**ហ៊ុន សែន** និងភរិយា បានផ្តល់ថវិកាផ្ទាល់ខ្លួនដើម្បីឧបត្ថម្ភដល់និស្សិតស្ម័គ្រចិត្ត មន្ត្រីជំនាញ គ្រូពេទ្យ អ្នកបើកបររថយន្ត ក្នុងម្នាក់ៗទឹកប្រាក់ចំនួន ១០០ដុល្លា។ គ្រាន់តែការផ្តល់ទឹកប្រាក់ឧបត្ថម្ភលើកទឹកចិត្តនេះ ក៏ត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន ៤៥៦,៦០០(សែសិបប្រាំម៉ឺន ប្រាំមួយពាន់ ប្រាំមួយរយ) ដុល្លារអាមេរិក (Bopha, 2013; Khmertvlive 2013)។

ជារួម ក្នុងនិស្សិតស្ម័គ្រចិត្តមួយក្រុមៗទទួលបានសម្ភារៈដូចខាងក្រោមនេះ[7]៖

- ឧបករណ៍ជីភីអេសកាន់ដោយដៃ (Garmin GPSMap 62s) សម្រាប់អង្កេត។ ឧបករណ៍នេះ ផ្តល់ភាពជាក់លាក់ក្នុងចំងាយ ១.៥ម៉ែត្រ ទៅ៣ម៉ែត្រ
- អាយភែដ (Ipad) ពីរគ្រឿង សម្រាប់ថតរូបអ្នកដែលដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីធ្លី និងឯកសារពាក់ព័ន្ធនានា
- កុំព្យូទ័រយួរដៃមួយគ្រឿង ប្រើសម្រាប់រៀបចំ និងកត់ត្រាឯកសារនានា និងធ្វើការទាញយកឯកសាររបស់ GARMI និងឯកសារនៅក្នុងអាយភែដ
- ទម្រង់ពាក្យជាផ្លូវការ និងសម្ភារៈសម្រាប់ប្រើប្រាស់ដើម្បីបំពេញទម្រង់បែបបទ និងប្រមូលព័ត៌មានពីអ្នកដាក់ពាក្យ
- វិទ្យុទាក់ទង សម្រាប់ការទំនាក់ទំនង ក្នុងករណីទូរសព្ទ័ដៃ គ្មានសេវា
- ទូរសព្ទ័ដៃពីរគ្រឿង ដែលមានលេខពិសេស សម្រាប់ក្រុមយុវជន ភ្ជាប់ដោយផ្ទាល់ជាមួយនឹងខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ម៉ាស៊ីនភ្លើងមួយគ្រឿង និងប្រព័ន្ធស្រូបយកកំដៅព្រះអាទិត្យ ជាពិសេស សម្រាប់សាកថ្ម នៃឧបករណ៍ជីភីអេសដែលប្រើប្រាស់ក្នុងពេលចុះធ្វើការវាស់វែង អាយភែដ និងកុំព្យូទ័រយួរដៃ
- សំភារៈប្រើប្រាស់ចាំបាច់ និងអាហារឧបត្ថម្ភ

ក្រៅពីការគាំទ្រផ្នែកហិរញ្ញវត្ថុ និស្សិតស្ម័គ្រចិត្តក៏បានទទួលការឧបត្ថម្ភបន្ថែមដូចជា៖ អង្ករ មីកញ្ចប់ ត្រីខកំប៉ុង ថ្នាំពេទ្យ និងសម្ភារៈប្រើប្រាស់ចាំបាច់ផ្សេងទៀត (May, 2012e) ។ មានស្ថាប័នរដ្ឋ និងក្រុមហ៊ុនឯកជនជាច្រើនដែលបានចូលរួមឧបត្ថម្ភដល់និស្សិតនិងមន្ត្រីជំនាញដែលចុះវាស់វែងដីធ្លី ដូចជាក្រុមហ៊ុនទូរស័ព្ទចល័តមិតហ្វូន (Metphone), ក្រុមហ៊ុនស៊ីភីហ្គ្រួប (CP Group), ក្រុមហ៊ុនស្រាបៀរអង្គរ (The Angkor Beer Company), ក្រុមហ៊ុនទឹកពិសាបរិសុទ្ធវីតាល់ (Vital Drinking Water), ក្រុមហ៊ុនគង់ហុងហ្គ្រួប (Kong Hong Group) និងក្រុមហ៊ុនប្រព័ន្ធថាមពលព្រះអាទិត្យ (CNV Team, 2013)។ កាកបាទក្រហមកម្ពុជា ផ្តល់ការឧបត្ថម្ភខាងផ្នែកចាន ឆ្នាំង ធុងទឹក តង់ជាដើម សម្រាប់និស្សិតស្ម័គ្រចិត្តរៀបចំស្នាក់នៅតាមមូលដ្ឋាននីមួយៗដែលខ្លួនចុះធ្វើការ។

បន្ថែមលើសម្ភារៈខាងលើ និស្សិតស្ម័គ្រចិត្តម្នាក់ៗ ទទួលបានសម្លៀកបំពាក់ឯកសណ្ឋានយោធាដែលមានស្លាកសញ្ញារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីប្រើប្រាស់ក្នុងការបំពេញបេសកកម្ម (May, 2012e)។ ក្រុមអ្នកវិភាគមួយចំនួន លើកឡើងពីក្តីកង្វល់ដែលថា រដ្ឋាភិបាលផ្តល់សំលៀកបំពាក់

[6] នៅសាលមហោស្រពកោះពេជ្រកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០១៣

[7] ប្រភពព័ត៌មានដកស្រង់ចេញពីរបាយការណ៍របស់ Muller & Zulsdorf, 2013 p.10-11

ទាហានដល់ក្រុមយុវជនស្ម័គ្រចិត្ត និងយានយន្តយោធារបស់ក្រសួងការពារជាតិ ដើម្បីដឹកជញ្ជូននិស្សិតស្ម័គ្រចិត្តចុះបំពេញបេសកកម្មវាស់វែងដីធ្លីនេះ អាចធ្វើឲ្យមានការភាន់ច្រឡំពីសំណាក់មហាជន ជាពិសេសប្រជាជនដែលរស់នៅតំបន់ជនបទ។ នៅក្នុងលិខិតទៅកាន់ក្រសួងការបរទេសកម្ពុជាកាលពីខែសីហា ឆ្នាំ២០១២ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ លោក ស៊ូរីយ៉ា ស៊ូប៊ិឌី បានលើក នូវក្តីកង្វល់ថា ការប្រើប្រាស់ឯកសណ្ឋានយោធារបស់ក្រុមយុវជនស្មគ្រចិត្ត និងការប្រើប្រាស់យានយន្តយោធាក្នុងការដឹកជញ្ជូនសម្រាប់សកម្មភាពស៊ីវិល ធ្វើឲ្យមានការយល់ច្រឡំថាជាកិច្ចការយោធា។ ប៉ុន្តែ សេចក្តីបំភ្លឺរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពន្យល់ថា ឯកសណ្ឋានរបស់ក្រុមនិស្សិតស្ម័គ្រចិត្តមានស្លាកសញ្ញាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហើយការប្រើប្រាស់ឯកសណ្ឋាននេះ មានការប្រកាសជាសាធារណៈឲ្យមហាជនបានដឹង។ ដូច្នេះមិនមានការភ្ញាក់ផ្អើលអ្វីទេ ព្រោះប្រជាជនបានដឹងពីការផ្សព្វផ្សាយរួចហើយ (ក្រសួងរៀបចំដែនដី នគរូប-នីយកម្ម និងសំណង់, ២០១២)។

ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានដែលអាចរកបាននៅតាមបណ្តាញសារព័ត៌មាននានា ហាក់ដូចជាមិនបានធ្វើសេចក្តីរាយការណ៍ណាមួយដែលលើកឡើងពីការយល់ច្រឡំរវាងក្រុមនិស្សិតស្ម័គ្រចិត្ត និងកម្លាំងប្រដាប់អាវុធរបស់ក្រសួងការពារជាតិនៅក្នុងតំបន់ណាមួយនៃការចុះវាស់វែងដីធ្លីទេ។ ផ្ទុយទៅវិញ សម្រាប់និស្សិតស្ម័គ្រចិត្តមួយចំនួន ការទទួលបានសម្លៀកបំពាក់ឯកសណ្ឋានទាហាន សម្រាប់ស្លៀកពាក់ចុះអនុវត្តការងារ គឺជាកម្លាំងជំរុញលើកទឹកចិត្តមួយដល់ពួកគេ ព្រោះពួកគេហាក់មានអារម្មណ៍ថា បានចូលបំពេញកាតព្វកិច្ចយោធាជូនប្រទេសជាតិ។

> *"តាំងពីតូចមក ខ្ញុំតែងមានបំណងចង់ស្លៀកពាក់ខោអាវទាហាន។ ពេលខ្ញុំធំឡើង ខ្ញុំខកខានមិនបានបំពេញកាតព្វកិច្ចយោធាទេ។ ដូច្នេះ នៅពេលចេញបទបញ្ជា០១(បប) ខ្ញុំលើកដៃមុនគេ។ ខ្ញុំមានអារម្មណ៍រំភើបណាស់ នៅពេលដែលមេខ្ញុំ ប្រាប់ខ្ញុំថា យុវជនដែលចុះបំពេញការងារ នឹងបានស្លៀកពាក់ខោអាវយោធា។ ចំពោះខ្ញុំ ក្នុងនាមជាមនុស្សប្រុស ត្រូវបំពេញកាតព្វកិច្ចយោធានោះ យើងនឹងក្លាយជាបុរសរឹងមាំ។"* អតីតនិស្សិតស្ម័គ្រចិត្ត, ខែមិថុនា ឆ្នាំ២០១៣។

## ២.៧ អង្គភាពគ្រប់គ្រងនិស្សិតស្ម័គ្រចិត្ត

សម្តេចនាយករដ្ឋមន្ត្រីហ៊ុន **សែន** បានតែងតាំងលោកហ៊ុន **ម៉ានិត** ដែលជាកូនប្រុស និងដែលជាវរសេនីយ៍ឯក នៃកងប្រដាប់អាវុធនាពេលនោះឲ្យគ្រប់គ្រងលើការងារវាស់វែងដីធ្លីនេះ។ សូមបញ្ជាក់ថា លោក **ហ៊ុន ម៉ានិត** បានត្រូវដំឡើងឋានន្តរសក្តិជាឧត្តមសេនីយត្រី (ពាក់ផ្កាយមួយ) នាពេលបច្ចុប្បន្ននេះ។ លោក **ហ៊ុន ម៉ានិត** មិនមានបទពិសោធន៍ក្នុងការងាររដ្ឋបាលដីធ្លីទេ (Strangio, ២០១២; May, ២០១២c)។ យោងតាម សុន្ទរកថារបស់នាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងពិធីសំណេះសំណាលផ្តាំផ្ញើដល់ក្រុមនិស្សិតស្ម័គ្រចិត្តមុនពេលចេញដំណើរ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ បញ្ជាក់ថាឯកឧត្តម ទេសរដ្ឋមន្ត្រី **អ៊ឹម ឈុន លឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានតួនាទីជាប្រធានផ្នែកបុគ្គលិកទូទៅ ហើយលោកហ៊ុន **ម៉ានិត** ជាអ្នកទទួលបន្ទុកផ្នែកសម្ភារៈនិងភស្តុភារ (Cambodia New Vision, 2012b)។

ក្នុងរបាយការណ៍ស៊ើបអង្កេតសិទ្ធិមនុស្សប្រចាំឆ្នាំ២០១២របស់អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ បានបញ្ជាក់ថា កម្មវិធីចុះវាស់វែងដីធ្លី ដោយប្រើនិស្សិតស្ម័គ្រចិត្តចុះជួយវាស់វែងនេះ ជាផែនការ "...គួរសរសើរបើនិយាយជាទ្រឹស្តី [តែវាជាការ] ធ្វើរំលងស្ថាប័នរដ្ឋាភិបាលដែលបានបង្កើតឡើងរួចហើយ ដើម្បីបំពេញការងារតែម្យ៉ាងនេះសុទ្ធសាធ។" លីកាដូ ក៏បានបន្ថែមដែរថា គំរោងផែនការនេះ "ត្រូវបានដាក់អោយអនុវត្តក្នុងលក្ខណៈបែបសំងាត់" និងគ្មានប្រព័ន្ធត្រួតពិនិត្យឯករាជ្យ ដើម្បីត្រួតពិនិត្យដំណើរការវាស់វែងដីធ្លីនេះទេ (LICADHO, *Human Rights 2012*, ទ.៤)។ របាយការណ៍របស់សមាគមសិទ្ធិមនុស្សអាដហុក បានលើកឡើងថា កម្មវិធីចុះវាស់វែងដីធ្លីនេះត្រូវបានធ្វើឡើងដោយមិនបានធ្វើការប្រឹក្សាយោបល់ជាមួយស្ថាប័នរដ្ឋដែល មានតួនាទីផ្តល់កម្មសិទ្ធិលើការប្រើប្រាស់ និងគ្រប់គ្រងដីធ្លីដែលមានស្រាប់ហើយនោះឡើយ (ADHOC, ២០១៣ ទ.៣៥)។

និស្សិត និងយុវជនស្ម័គ្រចិត្ត ដែលចូលរួមនៅក្នុងកម្មវិធីវាស់វែងដីធ្លី ទទួលបានការលើកទឹកចិត្តជាពិសេសពីរាជរដ្ឋាភិបាល ក្រោយពីការបញ្ចប់បេសកម្មដំណាក់កាលទី១។ កាលពីចុងឆ្នាំ២០១២ នាយករដ្ឋមន្រ្តីកម្ពុជា បានលើកឡើងថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងផ្តល់អាទិភាពដល់និស្សិតស្ម័គ្រចិត្តដែលបានចូលរួមក្នុងកម្មវិធីវាស់វែងដីធ្លីនេះ នៅពេលក្រសួងធ្វើការប្រលងជ្រើសរើសបុគ្គលិកក្របខណ្ឌចំនួន៦០០នាក់នាពេលអនាគត (Khmerlivetv, ២០១៣)។ ក្នុងការប្រឡងជ្រើសរើសបុគ្គលិកចូលបម្រើការងារក្របខណ្ឌក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១២ មានបេក្ខជនសរុបចំនួន១,៦០៣នាក់ បានដាក់ពាក្យប្រឡង។ នៅពេលចេញលទ្ធផល អតីតនិស្សិតស្ម័គ្រចិត្តចំនួន ៥៩៩ បានប្រលងជាប់ (សន្ទរកថារបស់នាយករដ្ឋមន្ត្រីនៅក្នុង khmerlivetv, ២០១៣; Koblot Khmer, 2013c)។ តាមរយៈការសម្ភាសន៍ជាមួយបុគ្គលិកនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានលើកឡើងថា និស្សិតស្ម័គ្រចិត្ត ដែលបានប្រឡងជាប់ជាបុគ្គលិកក្របខណ្ឌរបស់ក្រសួង បានក្លាយជាមន្រ្តីជំនាញចុះធ្វើការងារវាស់វែងដីធ្លីជាមួយនឹងក្រុមនិស្សិតស្ម័គ្រចិត្ត ក្នុងដំណាក់កាលទីពីរ (ប្រភព៖ ការសម្ភាសន៍ ខែមិថុនា ឆ្នាំ២០១៣)។

ការជ្រើសរើសបុគ្គលិកចូលបម្រើការងារក្របខណ្ឌក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានធ្វើអោយមានការចោទសួរពីមជ្ឈដ្ឋានអ្នកវិភាគ និងអ្នកស្រាវជ្រាវមួយចំនួនរួមទាំងអ្នកតាក់តែងរបាយ-ការណ៍នេះផងដែរពីហេតុផលដែលនិស្សិតស្ម័គ្រចិត្តបានទទួលអាទិភាពខ្លាំងជាងយុវជនដទៃទៀតដែលបានបញ្ចប់ការសិក្សាពីបណ្តាសកលវិទ្យាល័យនានា ក្នុងការប្រឡងយកក្របខណ្ឌជាមន្ត្រីរាជការក្នុងស្ថាប័នក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងពីហេតុផលជាក់លាក់ថា តើក្រសួងពិតជាមានតម្រូវការបុគ្គលិកក្នុងទ្រង់ទ្រាយធំ (៥៩៩នាក់) បែបនេះមែនឬយ៉ាងណា? សង្ខេបសេចក្តីទៅ គឺគេនៅតែមានចម្ងល់ថា តើការជ្រើសរើសបុគ្គលិកចូលបម្រើការងារក្របខណ្ឌនេះគឺ ធ្វើឡើងដើម្បីឆ្លើយតបនឹងតម្រូវការធនធានមនុស្សពិតប្រាកដ ឬមួយក៏ក្រសួងធ្វើការជ្រើសរើសមន្ត្រីថ្មីដើម្បីបំពេញតាមពាក្យសន្យាដែលនាយករដ្ឋមន្ត្រីលើកឡើងដើម្បីជាការលើកទឹកចិត្តដល់យុវជនស្ម័គ្រចិត្តសម្តេចតេជោនៅក្នុងខណៈប្រទេសទាំងមូលកំពុងមានតម្រូវការធនធានមនុស្សទាបបំផុត?

## ២.៨ សេចក្តីសង្ខេបលើប្រវត្តិក្រុមនិស្សិតស្ម័គ្រចិត្ត

ការវិភាគផ្នែកនយោបាយ លើហេតុផលដែលជម្រុញឲ្យមានការបង្កើតក្រុមនិស្សិតស្ម័គ្រចិត្ត ដើម្បីចុះជួយធ្វើការវាស់វែងដីធ្លី បង្ហាញពីសភាពលំអៀងផ្នែកនយោបាយ។ ការសម្ភាសផ្ទាល់ជាមួយនិស្សិតស្ម័គ្រចិត្ត (Rabe ២០១២, ទ.៥) បានបញ្ជាក់ថាទង្វើនេះ ជាចលនានយោបាយដ៏ឈ្លាសវៃរបស់លោកនាយករដ្ឋមន្ត្រី ក្នុងការទាក់ទាញសន្លឹកឆ្នោតក្នុងចំណោមនិស្សិតនៅតាមសាកលវិទ្យាល័យនានា និងពីសំណាក់ប្រជាជនរស់នៅតាមតំបន់ជនបទនៃប្រទេសកម្ពុជា។ អ្នកជំនាញផ្នែកដីធ្លី និងសកម្មជនសិទ្ធិមនុស្ស បានអះអាងថា បេសកកម្មវាស់វែងដីធ្លីនេះ ហោចណាស់ក៏មានមួយផ្នែកជាសកម្មភាពទាក់ទាញសន្លឹកឆ្នោត សម្រាប់គណបក្សប្រជាជនកម្ពុជានាកំឡុងពេលឃោសនារកសន្លឹកឆ្នោតមុនការបោះឆ្នោតនាខែកក្កដា ឆ្នាំ២០១៣ (Muller & Zulsdorf 2013; Naly Pilorge cited in LICADHO, 2013; Strangio, 2012; Vize et al., 2013)។ លោកស្រី ណាលី ភីឡូច នាយកប្រតិបត្តិនៃអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ ត្រូវបានគេដកស្រង់សម្តីថា សកម្មភាពនៃការចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្តនេះ មានការពាក់ព័ន្ធនឹងការបោះឆ្នោតក្នុងខែកក្កដាឆ្នាំ ២០១៣ ដោយគ្មានការសង្ស័យឡើយ។

មតិផ្សេងទៀតបានលើកឡើងថា កម្មវិធីនៃការចុះវាស់វែងដីធ្លីនេះ អាចបណ្តាលមកពីរដ្ឋាភិបាលកំពុងរងការគាបសង្កត់ពីសំណាក់ម្ចាស់ជំនួយ និងការខិតជិតចូលមកដល់នូវការបោះឆ្នោតជាតិ (RFA, 2012) និងការរកឃើញរបស់អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិលោកបណ្ឌិត ស៊ូរីយ៉ា ស៊ូប៊ីឌី ស្តីអំពីវិវាទដីធ្លី និងសម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា (De Certo et al, ២០១២)។ ការស្លាប់របស់សកម្មជនដីធ្លីលោក***ឈុត វុទ្ធី*** និងការបណ្តេញចេញដោយប្រើអំពើហិង្សានិងជម្លោះដីធ្លីក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក៏ជាអំណះអំណាងរបស់អ្នកវិភាគដីធ្លីថា វាជាដើមចមនៃការប្រកាសការអនុវត្តសកម្មភាពចុះវាស់វែងដីធ្លីរបស់នាយករដ្ឋមន្ត្រីកម្ពុជា (De Certo et al., ២០១២)។

ទោះជាយ៉ាងណាក៏ដោយ នាយករដ្ឋមន្ត្រីកម្ពុជា និងមន្ត្រីរាជរដ្ឋាភិបាលដទៃទៀតបានបដិសេធលើការយល់ឃើញខាងលើ ហើយបានអះអាងថា យុទ្ធនាការចុះវាស់វែងដីធ្លីនេះត្រូវធ្វើឡើងដើម្បីធ្វើជាសុច្ចនាករដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលក្នុងការតាមដានអំពីកំណែទម្រង់ដីធ្លី ហើយមិនពាក់ព័ន្ធនឹងនយោបាយ និងការទទួលគំនាបពីម្ចាស់ជំនួយឡើយ(May, 2012b; Kuch et al., 2012)។ មតិរិះគន់នៅតែចោទឡើងថា ប្រសិនបើសកម្មភាពនៃការចុះវាស់វែងដីធ្លី ជាផ្នែកមួយនៃកម្រែទម្រង់ដីធ្លីរបស់រដ្ឋាភិបាល កម្ពុជា ហេតុអ្វីបាជាសកម្មភាពភាពដែលមានទ្រង់ទ្រាយធំបែបនេះ មិនត្រូវបានលើកឡើងនៅក្នុងផែនការកំណែទម្រង់ដីធ្លីជាតិ ហើយបែរជាប្រើប្រាស់ថវិកាផ្ទាល់ខ្លួនរបស់នាយករដ្ឋមន្ត្រី និងមន្ត្រីនៅក្នុងជួរគណបក្សប្រជាជនទៅវិញ?

# បទពិសោធន៍នៃការចូលរួមក្នុងដំណើរការវាស់វែងដីធ្លីរបស់ប្រជាជននៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងខេត្តឧត្តរមានជ័យ

---




បណ្តាញសហគមន៍ធ្វើបាតុកម្មអហិង្សាសទាមទារឲ្យមានការដោះលែងសកម្មជន គុជ វេង នៅមុខសាលាដំបូងខេត្តពោធិ៍សាត់នាថ្ងៃទី ២១, ២៣ ខែមិថុនា ឆ្នាំ២០១៣។ រូបថតផ្តល់ឲ្យកញ្ញាស៊ឹម សុជាតា ខែមិថុនា ឆ្នាំ២០១៣។

# បទពិសោធន៍នៃការចូលរួមក្នុងការវាស់វែងដីធ្លី របស់ប្រជាជននៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងខេត្តឧត្តរមានជ័យ

ចាប់តាំងពីយុទ្ធនាការចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត និងមន្ត្រីជំនាញសុរិយោដីបានចាប់ផ្តើម មានការចុះផ្សាយព័ត៌មានជាច្រើនពីជម្លោះដីធ្លីនៅតាមបណ្តាខេត្តនានានៅក្នុងប្រទេសកម្ពុជា។ អត្ថបទសារព័ត៌មានដែលទាក់ទងនឹងជម្លោះដីធ្លីក្នុងខេត្តពោធិ៍សាត់ហាក់មានសភាពក្តៅគគុកជាងបណ្តាខេត្តផ្សេងៗទៀត និងទទួលបានការចុះផ្សាយជាញឹកញាប់។ បញ្ហាចម្បងដែលត្រូវបានចុះផ្សាយនៅក្នុងអត្ថបទកាសែតពីរ[8] ដែលត្រូវបានពិនិត្យមើលមានដូចជាករណីក្រុមនិស្សិតស្ម័គ្រចិត្តបដិសេធមិនវាស់វែងដីអោយប្រជាជន(May, ២០១៣h), ក្រុមហ៊ុនឈូសឆាយផ្ទះរបស់ប្រជាជននៅពេលដែលក្រុមនិស្សិតចាប់ផ្តើមចុះវាស់វែងដី (Aun, ២០១២), មន្ត្រីអាជ្ញាធរមូលដ្ឋានដកហូតយកប័ណ្ណកម្មសិទ្ធិដីធ្លីពីប្រជាជន និងការដាក់ពាក្យបណ្តឹងរបស់ប្រជាជនម្ចាស់ដីដល់អង្គការសិទ្ធិមនុស្សក្នុងស្រុក(May, ២០១២d) និងឧទ្ទកាល័យនាយករដ្ឋមន្ត្រី ហ៊ុន សែន (Kuch, ២០១៣) រួមទាំងការសន្យាក្នុងការដោះស្រាយបញ្ហាដីធ្លីអោយប្រជាជន (May, ២០១៣g)។

មានអត្ថបទមួយចំនួនទៀតបានចុះផ្សាយទាក់ទងនឹងការវាស់វែងដីរបស់ក្រុមនិស្សិតស្ម័គ្រចិត្តនៅខេត្តបាត់ដំបង។ ការចែកប័ណ្ណកម្មសិទ្ធិដីធ្លីនៅក្នុងឃុំមួយក្នុងស្រុកគាស់ក្រឡរបស់នាយករដ្ឋមន្ត្រី (Phorn, ២០១២) លើកឡើងជាថ្មីពីគោលដៅនៃកម្មវិធីនេះថា វាជាការដោះស្រាយបញ្ហាវិវាទដីធ្លីរវាងប្រជាជន និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចតាមរយៈការវាស់វែង និងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាជន។ អត្ថបទមួយទៀតចុះផ្សាយពីការទាមទាររបស់ប្រជាជន១៣៧គ្រួសារ នៅមុខសាលាខេត្តបាត់ដំបង ទាមទារឲ្យអាជ្ញាធរផ្តល់ដីមកដល់ប្រជាជនវិញពីព្រោះក្រុមនិស្សិតស្ម័គ្រចិត្តរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន បានវាស់វែង និងប្រគល់ប័ណ្ណកម្មសិទ្ធិដីទាំងនោះដល់អ្នកដ៏ទៃក្រៅពីពួកគាត់ដែលជាម្ចាស់ (Phak, ២០១៣)។

ផ្នែកខាងក្រោមនេះ រៀបរាប់លើព័ត៌មានដែលប្រមូលមកពីបណ្តាលភូមិចំនួន១៦ ក្នុងខេត្តកំពង់ឆ្នាំង, ពោធិ៍សាត់, បាត់ដំបង, និងខេត្តឧត្តរមានជ័យ និងវិភាគពីសកម្មភាពនៃការចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត បញ្ហាប្រឈមដែលប្រជាជនតាមសហគមន៍ជួបប្រទះនៅក្នុងពេលវាស់វែង និងក្រោយពីបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ចេញដោយក្រុមនិស្សិតស្ម័គ្រចិត្តសម្តេចតេជោ។

[8] *កាសែតភ្នំពេញប៉ុស្តិ៍* និង *កាសែតខេមបូឌា ដេលី* សម្រាប់អត្ថបទដែលចុះផ្សាយទាក់ទងនឹងការវាស់វែងដីធ្លី ចាប់ពីខែមិថុនា ២០១២ ដល់ខែមិថុនា ២០១៣។

## ៣.១ ឯកសារដែលត្រូវការសម្រាប់ការវាស់វែងដីធ្លី

តាមការឆ្លើយតបរបស់ប្រជាជននៅតាមភូមិនានាដែលបានផ្តល់ព័ត៌មាន និងបានចូលរួមនៅក្នុងការវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្តបានចែករំលែកឲ្យដឹងថា ឯកសារសំខាន់ៗដូចជា សៀវភៅគ្រួសារ, សៀវភៅអត្រានុកូលដ្ឋាន, សំបុត្រកំណើត, អត្តសញ្ញាណប័ណ្ណ, រូបថត៤x៦ចំនួនពីរសន្លឹក, លិខិតផ្ទេរអំណាចពីឪពុកម្តាយ[9] (ក្នុងករណីម្ចាស់ដីជាស្ត្រីមេម៉ាយ, ពោះម៉ាយ ឬនៅលីវ) គឺជាឯកសារដែលត្រូវការនៅពេលដែលក្រុមនិស្សិតស្ម័គ្រចិត្តចុះមកវាស់វែងដីធ្លីប្រជាជន។

ការត្រៀមរៀបចំឯកសារអត្រានុកូលដ្ឋានដែលត្រូវការសម្រាប់ការវាស់វែងដីធ្លី គឺជាបញ្ហាប្រឈមរបស់គ្រួសារមួយចំនួននៅតាមជនបទ។ អតីតនិស្សិតស្ម័គ្រចិត្តដែលបានសម្ភាសន៍ថ្លែងថា ការរកបានលិខិតបទដ្ឋានគ្រប់គ្រាន់សម្រាប់ការវាស់វែង គឺជាបញ្ហាប្រឈម នឹងអាចធ្វើឲ្យដំណើរការនៃការវាស់វែងមានការយឺតយ៉ាវ ជាពិសេសនៅក្នុងដំណាក់កាលទីមួយ (កក្កដា-ធ្នូ ២០១២) នៃយុទ្ធនាការ។ មន្ត្រីជំនាញ និងនិស្សិតនៅក្នុងក្រុមខ្លះ ត្រូវសម្រេចព្រមទទួលយកនូវលិខិតបញ្ជាក់ដែលចេញដោយអាជ្ញាធរឃុំ ជំនួសលិខិតអត្រានុកូលដ្ឋានជាក់លាក់ ដោយសារតែប្រជាជនគ្មានឯកសារគ្រប់គ្រាន់ ហើយក្រុមការងារមិនចង់អូសបន្លាយពេលវេលាកាន់តែយូរថែមទៀត។

## ៣.២ ប្រភេទដីដែលត្រូវវាស់វែងក្នុងយុទ្ធនាការវាស់វែងដីធ្លី

ក្នុងលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី *លេខ៦៦៦សជណ* បានបញ្ជាក់ច្បាស់ពីប្រភេទដីដែលត្រូវធ្វើការវាស់វែងនៅក្រោមការចុះអនុវត្តបទបញ្ជា០១(បប)។ ដីតំបន់ដែលត្រូវធ្ងៀលចេញស្របតាមនិតិវិធី រួមមានដីព្រៃសម្បទាន ដីសម្បទានសេដ្ឋកិច្ច ដីតំបន់ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន និងដីរដ្ឋដែលមានដីកាដកហូតដោយអាជ្ញាធររាជធានីខេត្ត (ទីស្តីការគណៈរដ្ឋមន្ត្រី, ២០១២) គឺជាប្រភេទដីដែលក្រុមនិស្សិតត្រូវធ្វើការវាស់វែង និងចេញប័ណ្ណកម្មសិទ្ធិដល់ប្រជាជន។

តាមបទពិសោធន៍របស់ប្រជាជន ប្រភេទដីដែលត្រូវបានវាស់វែង ហាក់ដូចជាមានភាពខុសៗគ្នាអាស្រ័យតាមការអនុវត្តក្នុងខេត្តនិមួយៗ។ តាមការផ្តល់ព័ត៌មានរបស់ប្រជាជន ប្រភេទដីដែលត្រូវបានវាស់វែងរួមមានដីដែលកំពុងតែអាស្រ័យផល ឬបង្កបង្កើនផល ដីចំការដែលដាំដំណាំ ដីដែលមានជើងជ្រាំង (ជើងជ្រាំងស្រូវដែលច្រូតហើយ) ដីស្រែ ដីភូមិ ដីលំនៅស្ថាន ដីព្រៃដែលមាននៅលើផែនទីសម្បទានដីសេដ្ឋកិច្ច។ នៅតាមភូមិគោលដៅដែលបានប្រមូលព័ត៌មានក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ និងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ដីដែលវាស់វែងភាគច្រើនគឺស្ថិតក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច និងក្រុមហ៊ុនរតនៈវិសាលអភិវឌ្ឍន៍ក្នុងស្រុកក្រគរ។

ប្រជាពលរដ្ឋក្នុងភូមិមួយចំនួននៅខេត្តពោធិ៍សាត់បានចែករំលែកថា ក្រុមនិស្សិតស្ម័គ្រចិត្តបានវាស់វែងតែដីដែលបានអាស្រ័យផលរួចហើយដូចជា៖ ដីស្រែ ដីដែលកំពុងបង្កបង្កើនផល ដីដែលមានដំណាំដាំដុះនៅលើនោះ ដីដែលមានជើងជ្រាំង (ជ្រាំងស្រូវក្រោយពេលច្រូត) ដីចំការ និងដីលំនៅឋាន។ ចំពោះដីព្រៃដែល

[9] លិខិតផ្ទេរអំណាច គឺជាលិខិតដែលបញ្ជាក់ថា ឪពុកម្តាយ បានចែកដីឲ្យទៅកូន (ទោះបីជាកូនមានគ្រួសារ ឬនៅលីវ ឬលែងលះគ្នី)។ ការបែងចែកនេះ គឺកំណត់ផ្តល់ដល់កូនដែលមានអាយុ១៨ឆ្នាំឡើងទៅ។ លិខិតនេះ ត្រូវចេញដោយក្រុមប្រឹក្សាឃុំ និងមិនយកប្រាក់ទេ។

កាប់ឆ្ការតិចតួច ឬដីដែលទើបនឹងកាប់ព្រៃហើយថ្មីៗ គឺនិស្សិតមិនវាស់វែងឲ្យទេ ទោះបីជាវាជាដីស្រែដែលនៅក្បាលដីមានព្រៃបន្តិចបន្តួចក៏ដោយ។ ដីដែលមានទំនាស់ គឺមិនត្រូវបានវាស់វែងទេ។ ចំណែកប្រជាជនដែលរស់នៅក្នុងភូមិមួយចំនួននៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង បានផ្តល់ព័ត៌មានថា ដីរបស់ប្រជាជនដែលស្ថិតនៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនភាពីម៉ិចត្រូវបានក្រុមនិស្សិតវាស់វែង និងផ្តល់ប័ណ្ណកម្មសិទ្ធិឲ្យដល់ប្រជាជន ដោយរាប់បញ្ចូលទាំងដីព្រៃផងដែរ។ ប្រជាជននៅភូមិអញ្ចាញរូង ក្នុងស្រុកបរិបូណ៌បានរៀបរាប់ថា ដីដែលត្រូវបានលើកលែងចេញពីការវាស់វែងរួមមានដីជំនឿ, ដីជម្រកសត្វព្រៃ, ដីដែលត្រួតស៊ីគ្នា, ដីក្នុងតំបន់សមយុទ្ធរបស់យោធា, ដីភ្នំ, ដីត្រពាំង, អូរ, ស្ទឹង, សាលាបុណ្យ, សាលាឃុំ, និងផ្លូវរថភ្លើងជាដើម។ ក្រៅពីនោះក្រុមនិស្សិតវាស់វែងឲ្យទាំងអស់ គឺតាមចំនួនដីដែលប្រជាពលរដ្ឋមានជាក់ស្តែង។

# ៣.៣ កិច្ចសហការក្នុងដំណើរការចុះវាស់វែងដីធ្លី

ក្រុមយុវនិស្សិតស្ម័គ្រចិត្ត ចុះអនុវត្តការងារដោយមានកិច្ចសហការខ្ពស់ជាមួយ មន្ត្រីជំនាញមកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ត្រីសុរិយោដីមកពីថ្នាក់ក្រសួង ថ្នាក់ខេត្ត និងថ្នាក់ស្រុក, អាជ្ញាធរភូមិ ឃុំ ស្រុក និងប្រជាពលរដ្ឋ។

> *"ក្នុងមូលដ្ឋាននីមួយៗ មានក្រុមការងារបច្ចេកទេស ដែលមានសមាជិកចំនួន១២រូប មកពីមន្ទីរជំនាញដូចជាៈ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី, មន្ទីរបរិស្ថាន, មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, និងខណ្ឌរដ្ឋបាលព្រៃឈើ។ ក្រុមនិស្សិតស្ម័គ្រចិត្តត្រូវសហការជាមួយក្រុមការងារបច្ចេកទេស ប៉ុន្តែមិនមែនស្ថិតនៅក្រោមបង្គាប់របស់ក្រុមនេះទាំងស្រុងនោះទេ។"* អតីតប្រធានក្រុមនិស្សិតស្មគ្រ័ចិត្ត, ខែមិថុនា ឆ្នាំ២០១៣។

ប្រជាជនដែលបានជួបប្រមូលព័ត៌មាននៅក្នុងភូមិទំនប់តាគួន ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង លើកឡើងថា អាជ្ញាធរខេត្តបានផ្តួចផ្តើមឲ្យមានការបង្កើតគណៈកម្មការប្រជាជនដែលមានតំណាងប្រជាជនចំនួនពី ៥-៧រូប ដើម្បីចូលរួមជាមួយក្រុមនិស្សិតស្ម័គ្រចិត្ត ក្នុងគោលបំណងធ្វើការអង្កេតមើលពីដំណើរការនៃការអនុវត្តការងារ និងទាមទារឲ្យមានដំណោះស្រាយជូនប្រជាពលរដ្ឋឲ្យបានដីស្រែមកវិញ។ ក្រោយពេលបេសកកម្មត្រូវបានបញ្ចប់ គណៈកម្មាធិការប្រជាជននេះ ក៏ត្រូវបានរំសាយទៅវិញដែរ។ មិនមានប្រជាជន នៅស្រុក ឬខេត្តផ្សេងទៀត ដែលបានចូលរួមក្នុងការផ្តល់ព័ត៌មាននេះ លើកឡើងពីការចូលរួមរបស់តំណាងប្រជាជនក្នុងសកម្មភាពចុះវាស់វែងរបស់ក្រុមនិស្សិតស្ម័គ្រចិត្តដូចក្នុងករណីភូមិទំនប់តាគួន ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបងនេះឡើយ។

## ៣.៤ បញ្ហាប្រឈមក្នុងការអនុវត្តការវាស់វែងដីធ្លី

បញ្ហាខាងក្រោមនេះ ត្រូវបានលើកឡើងដោយប្រជាជនដែលបានផ្តល់ព័ត៌មាន និងអតីតនិស្សិតស្ម័គ្រចិត្តមួយចំនួន ដែលឆ្លងកាត់បទពិសោធន៍ចុះបំពេញការងារ ថាជាឧបសគ្គដែលរាំង ឬធ្វើឲ្យដំណើរការវាស់វែងមានភាពយឺតយ៉ាវ។

- ប្រជាជនជាម្ចាស់ដីខ្លះ មិនស្គាល់ចំណុចព្រំប្រទល់ដីរបស់ខ្លួន។
- ប្រជាជនជាម្ចាស់ដីខ្លះ មិនស្គាល់ឈ្មោះរបស់ម្ចាស់ដីជាប់ព្រំប្រទល់ដីរបស់ខ្លួន។ នៅក្នុងការចុះវាស់វែង គឺតម្រូវឲ្យម្ចាស់ដីជាប់ព្រំប្រទល់ផ្តិតមេដៃធ្វើជាសាក្សី។
- មិនបានជួបជាមួយនឹងម្ចាស់ដី ដោយសារតែចំណាកស្រុកទៅធ្វើការងារនៅខេត្តផ្សេង ឬប្រទេសផ្សេងទៀត ឬមិនបានដឹងថាថ្ងៃណាមួយពិតប្រាកដដែលក្រុមនិស្សិតចុះមកធ្វើការវាស់វែងដីធ្លី។
- ការវាស់វែងរបស់ក្រុមនិស្សិតមានផែនការ និងមានរយៈពេលខ្លី និងមានកំណត់។ ប្រជាជនដែលបានធ្វើចំណាកស្រុកទៅរកការងារនៅស្រុកឆ្ងាយ មិនបានទទួលដំណឹងទាន់ពេលវេលាជាពិសេស ប្រសិនបើការផ្សព្វផ្សាយនៅក្នុងមូលដ្ឋាន មិនបានទូលំទូលាយ និងមិនបានកំណត់ថ្ងៃចុះវាស់វែងច្បាស់លាស់។ បញ្ហានៃការផ្សព្វផ្សាយនេះ ត្រូវបានលើកជាបញ្ហានៅក្នុងភូមិជាច្រើនស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ ដែលមានព្រំប្រទល់ជាប់នឹងប្រទេសថៃ ហើយអត្រាចំណាកស្រុកទៅរកការងារធ្វើនៅថៃមានកម្រិតខ្ពស់។

## ៣.៥ ក្តីសង្ឃឹមលើអត្ថប្រយោជន៍នៃការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី

ប្រជាជនដែលចូលរួមនៅក្នុងការប្រមូលព័ត៌មាននេះ សង្ឃឹមយ៉ាងមុតមាំលើការការពារស្របច្បាប់ដែលផ្តល់ឲ្យដោយប័ណ្ណសិទ្ធិកម្មសិទ្ធិដីធ្លីដែលពួកគាត់បានទទួល។ ក្នុងចំណោមនោះ ផលប្រយោជន៍ចម្បងៗ ដែលប្រជាជនសង្ឃឹមថា នឹងបានទទួលតាមរយៈការទទួលបានប័ណ្ណសិទ្ធិកម្មសិទ្ធិដីធ្លីស្របច្បាប់មានដូចជា៖

- កាត់បន្ថយបញ្ហាជំលោះព្រំប្រទល់រវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ កាត់បន្ថយការប្រឈមមុខរវាងក្រុមហ៊ុន អាជ្ញាធរ និងប្រជាពលរដ្ឋដែលមានព្រំប្រទល់ដីនៅជិតគ្នា។
- សម្រាប់ប្រជាជនដែលមានដីនៅជិត ឬក្នុងបរិវេណដីដែលស្ថិតក្រោមតំបន់សម្បទានដីសេដ្ឋកិច្ច ប័ណ្ណកម្មសិទ្ធិស្របច្បាប់ នឹងផ្តល់ការការពារស្របច្បាប់ដល់ពួកគាត់ និងដីរបស់គាត់ពីការរំលោភបំពាន ឬការរឹបអូសយកដីខុសច្បាប់ពីសំណាក់ក្រុមហ៊ុន និងអាចតវ៉ាជាមួយក្រុមហ៊ុនក្នុងករណីមានការរំលោភបំពានកើតឡើង។

- ទទួលបានការសងជម្ងឺចិត្តពីសំណាក់ក្រុមហ៊ុន ឬរដ្ឋាភិបាល ក្នុងករណីមានការរំលោភបំពានឬការរឹបអូសដីធ្លី ហើយត្រូវដោះស្រាយតាមផ្លូវច្បាប់។
- ប័ណ្ណសិទ្ធិកម្មសិទ្ធិដីធ្លី អាចត្រូវបានយកទៅប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាបន្ទាន់នៅក្នុងគ្រួសារ ដូចជាប្រើជាវត្ថុបញ្ចាំសំរាប់ខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬធនាគារក្នុងស្រុក (ខេត្តបាត់ដំបង)។
- ក្រុមគ្រួសារ ឬឪពុកម្តាយ ដែលមានប័ណ្ណសិទ្ធិកម្មសិទ្ធិស្របច្បាប់ អាចផ្ទេរដី ចែកកេរមរតកដល់កូនចៅរបស់គាត់។
- សម្រាប់ស្ត្រី ការមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ដែលដាក់ឈ្មោះទាំងប្តី និងប្រពន្ធ ផ្តល់ការការពារស្របច្បាប់ដល់ស្ត្រីដែលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ដែលអាចទទួលបានដីដែលជាចំណែករបស់ខ្លួនក្នុងករណីមានការលែងលះគ្នា។
- អ្វីដែលសំខាន់ជាងគេ គឺប័ណ្ណកម្មសិទ្ធិស្របច្បាប់ធ្វើឲ្យអ្នកដែលជាម្ចាស់ដីមានភាពកក់ក្តៅក្នុងការរស់នៅ និងប្រើប្រាស់ដីសម្រាប់ប្រកបរបរ ឬដាំដុះផ្សេងៗ និងជៀសផុតពីភាពភ័យខ្លាចក្នុងការរងការរំលោភបំពាន ឬរឹបអូសយកដី ។ ប្រជាជនមួយចំនួនសង្ឃឹមថា ការទទួលបានប័ណ្ណកម្មសិទ្ធិដី នឹងអាចធ្វើឲ្យគាត់មានស្ថេរភាព សុវត្ថិភាព និងសន្តិសុខក្នុងការរស់នៅក្នុងសហគមន៍។

ជាការពិតណាស់ ក្តីសង្ឃឹមទៅលើអត្ថប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិដីធ្លីដែលប្រជាជនបានចែករំលែកជាមួយនឹងក្រុមប្រមូលព័ត៌មាន បានឆ្លុះបញ្ចាំងពីសារដ៏សំខាន់ដែលត្រូវបានឃោសនាផ្សព្វផ្សាយតាមប្រព័ន្ធសារព័ត៌មាននានានៅក្នុងពេលអនុវត្តយុទ្ធនាការចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត។ សារនេះហាក់ត្រូវបានប្រជាជនដែលរស់នៅតាមតំបន់ជនបទនៃប្រទេសកម្ពុជា ទទួលយកនឹងជឿជាក់ថា តាមរយៈការទទួលបានប័ណ្ណកម្មសិទ្ធិស្របច្បាប់ កិច្ចការពារផ្នែកច្បាប់ចំពោះសិទ្ធិកម្មសិទ្ធិដី ការគ្រប់គ្រង និងការប្រើប្រាស់ដីរបស់ពួកគាត់នឹងត្រូវបានការពារ។ ការសន្និដ្ឋាន លើប្រសិទ្ធិភាព និងកិច្ចការពារដែលផ្តល់ដោយប័ណ្ណកម្មសិទ្ធិដីធ្លីថ្មីគួរត្រូវលើកយកមកពិចារណាអាស្រ័យលើរយៈពេលដែលប្រជាជនទទួលបានបណ្ណ័នេះមកកាន់កាប់ បទ-ពិសោធន៍ជាក់ស្តែងនៃការប្រើប្រាស់ប័ណ្ណ និងបញ្ហាប្រឈមដែលប្រជាជនតាមបណ្តាសហគមន៍មួយចំនួនជួបប្រទះ។ នៅក្នុងពេលដែលយុទ្ធនាការចុះវាស់វែងដីធ្លីកំពុងតែដំណើរការ វាមានការលំបាកក្នុងការសន្និដ្ឋានពីប្រសិទ្ធិភាពវិជ្ជមាន និងជាក់លាក់របស់ប័ណ្ណកម្មសិទ្ធិនេះ។

# ៣.៦ ក្តីកង្វល់របស់ប្រជាពលរដ្ឋលើការផ្តល់ប័ណ្ណកម្មសិទ្ធិ

## ៣.៦.១ ការបែកបាក់សាមគ្គីក្នុងរង្វង់ប្រជាជនក្នុងសហគមន៍

ប្រជាជនមួយចំនួន ដែលរស់នៅក្នុងសហគមន៍មួយចំនួន ក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ បានលើកឡើងពីក្តីកង្វល់របស់គាត់ថា ដំណើរការនៃការអនុវត្តកម្មវិធីចុះវាស់វែងដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធិដល់ប្រជាជនបានបង្ករឲ្យមានការបែកបាក់សាមគ្គីក្នុងរង្វង់ប្រជាជនក្នុងសហគមន៍ ជាពិសេសចំពោះសហគមន៍ដែលធ្លាប់មានបញ្ហាជំលោះដីធ្លីជាមួយនឹងក្រុមហ៊ុនដីសម្បទាន។ នេះគឺដោយសារតែក្នុងដំណើរការនៃការចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្តអនុវត្តមិនដូចគ្នាគ្រប់កន្លែង៖ នៅកន្លែងខ្លះ និស្សិតវាស់ដីព្រៃ និងចេញប័ណ្ណឲ្យប្រជាជនខ្លះ ឯកន្លែងខ្លះទៀតមិនវាស់វែងឲ្យ (ដូចជាករណីនៃការវាស់ដីសម្បទានដីសេដ្ឋកិច្ចក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ និងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង (ពិភាក្សានៅផ្នែកខាងក្រោម) ដែលការវាស់វែងមានភាពខុស

គ្នាព្រោះក្រុមនិស្សិតផ្សេងគ្នា)។ បន្ថែមពីលើនេះទៀត ដោយសារមានការគំរាមកំហែងតាមរយៈពាក្យសំដីពីសំណាក់អាជ្ញាធរមូលដ្ឋាន និងមន្ត្រីជំនាញមួយចំនួនដែលពាក់ព័ន្ធនៅក្នុងការវាស់វែងដីធ្លីហាមឃាត់មិនឲ្យប្រជាជន(ដែលមានដីត្រូវបានក្រុមនិស្សិតវាស់វែង និងបានទទួលសាលាកបត្រហើយ) ចូលរួមតវ៉ាជួយដល់ប្រជាជនផ្សេងទៀតក្នុងសហគមន៍ ដែលកំពុងមានបញ្ហាដីដែលបានវាស់វែងរួចហើយ តែនៅមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិ។ ការហាមឃាត់នេះ ធ្វើឲ្យប្រជាជនដែលមានដីដែលត្រូវបានគេវាស់វែងហើយ បារម្ភខ្លាចអាជ្ញាធរមិនផ្តល់ប័ណ្ណកម្មសិទ្ធិឲ្យខ្លួន (ប្រសិនបើចូលរួមជួយតវ៉ាឲ្យគេ)។

### ៣.៦.២ ភាពមានកម្រិតនៃការប្រើប្រាស់ដី

យុទ្ធនាការអនុវត្តបទបញ្ជា០១(បប) របស់រាជរដ្ឋាភិបាលកម្ពុជា គឺអនុវត្តកម្មវិធីគ្រប់គ្រងដីធ្លី ដើម្បីផ្តល់សិទ្ធិស្របច្បាប់ទៅលើដីកម្មសិទ្ធិរបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា។ ខណៈដែលកម្មវិធីនេះទទួលការស្វាគមន៍ថាជាជំហានវិជ្ជមានក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាជននៅក្នុងប្រទេសកម្ពុជា ប្រជាជនមួយចំនួននៅតាមបណ្តាភូមិគោលដៅនៃការចុះប្រមូលព័ត៌មានសម្រាប់ការចងក្រងឯកសារនេះ បានសំដែងនូវក្តីព្រួយបារម្ភចំពោះការទទួលបាន និងការប្រើប្រាស់ដីនៅពេលអនាគត។ ក្នុងប័ណ្ណកម្មសិទ្ធិដីមួយមានទំហំមិនឲ្យលើសពីប្រាំហិកតាក្នុងមួយក្បាលដី (យោងតាមច្បាប់ភូមិបាលប្រទេសកម្ពុជា ឆ្នាំ២០០១)។ ប្រជាជនដែលមានដីតិច ឬគ្មានដីសោះកំពុងតែមានការព្រួយបារម្ភជាខ្លាំងពីលទ្ធភាពនៃការទទួលបានដីអាស្រ័យផលក្នុងពេលបច្ចុប្បន្ន និងសម្រាប់កូនចៅជំនាន់ក្រោយរបស់ពួកគាត់នៅថ្ងៃអនាគត ពីព្រោះដីដែលបានវាស់ និងផ្តល់ប័ណ្ណកម្មសិទ្ធិ គឺផ្អែកលើទំហំដីជាក់ស្តែងដែលពួកគាត់មាននៅពេលបច្ចុប្បន្នតែប៉ុណ្ណោះ។ ជាក់ស្តែង ប្រជាជនដែលរស់នៅក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ ដែលស្ថិតនៅតំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនភាពីម៉ិចសំដែងក្តីបារម្ភខ្លាំងចំពោះស្ថានភាពនេះ។ ពួកគាត់លើកឡើងថា កាលពីមុន ទោះបីជាប្រជាជនគ្មានដីដែលជាកម្មសិទ្ធិផ្ទាល់ខ្លួន ក៏ពួកគាត់អាចចូលទៅក្នុងព្រៃសហគមន៍ដើម្បីស្វែងរកអនុផលព្រៃឈើសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងគ្រួសារបាន។ ប៉ុន្តែមកដល់ពេលនេះ ដីទាំងអស់ស្ថិតនៅក្នុងតំបន់សម្បទានសេដ្ឋកិច្ច ហើយក្រោយពីកម្មវិធីវាស់វែងដីធ្លីរបស់យុវជនស្មគ្រ័ចិត្តត្រូវបានបញ្ចប់ ដីមួយដុំៗ មួយប្លង់ៗ សុទ្ធតែមានម្ចាស់កម្មសិទ្ធិ ក្រៅពីនោះ ជាដីសម្បទានរបស់ក្រុមហ៊ុន។ ដូច្នេះប្រជាជនក្រីក្រដែលគ្មានដីគឺ គ្មានអ្វីសោះ ក្រៅពីកំលាំងពលកម្មរបស់គាត់។ ស្ថានភាពនេះ នឹងធ្វើឲ្យជីវភាពរបស់ប្រជាជនកាន់តែលំបាកទៅៗ ព្រោះប្រជាជននឹងគ្មានដីព្រៃប្រើប្រាស់។ នៅថ្ងៃអនាគត ពួកគាត់នឹងគ្មានដីសម្រាប់ទុកចែកឲ្យកូនចៅសម្រាប់ប្រកបរបរចិញ្ចឹមជីវិតទេ។

### ៣.៦.៣ ការកេងចំណេញផ្នែកនយោបាយពីការអនុវត្តបទបញ្ជា០១(បប)

ប្រជាជនមួយចំនួននៅក្នុងសហគមន៍មានក្តីបារម្ភថា ដំណើរការនៃការវាស់វែងដីធ្លីនេះ មិនត្រឹមតែធ្វើឲ្យប្រជាពលរដ្ឋគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួនជាងមុនជាជាងផលប្រយោជន៍សហគមន៍ប៉ុណ្ណោះទេ តែប្រជាជនក្នុងភូមិខ្លះ ក៏ទទួលការគំរាមកំហែងពីសំណាក់អាជ្ញាធរនៅក្នុងដំណើរការវាស់វែងដីធ្លីផងដែរ។ ជាបទពិសោធន៍ ប្រជាជនដែលរស់នៅក្នុងភូមិគោលដៅនៃការប្រមូលព័ត៌មានក្នុងខេត្តពោធិ៍សាត់ និងខេត្តឧត្តរមានជ័យ ត្រូវបានអាជ្ញាធរមូលដ្ឋានរំលឹកឲ្យបោះឆ្នោតឲ្យគណបក្សកាន់អំណាចបច្ចុប្បន្ន បើមិនដូច្នោះទេ អាជ្ញាធរនឹងមិនចេញប័ណ្ណកម្មសិទ្ធិអចិន្ត្រៃយ៍ឲ្យទេ។

> *"នៅក្នុងភូមិរបស់ខ្ញុំ និស្សិតស្ម័គ្រចិត្ត បានចុះវាស់វែងដីរួចហើយ និងត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិបឋមដល់គ្រួសារ។ តែអាជ្ញាធរមូលដ្ឋាន លើកឡើងថាក្រុមនិស្សិតស្ម័គ្រចិត្តបានធ្វើការងារមានភាពនឿយហត់ខ្លាំងណាស់ ដូច្នេះមិនចាំបាច់ចែកប័ណ្ណកម្មសិទ្ធិបឋមដល់ប្រជាជនដោយខ្លួនឯងទេ។ អាជ្ញាធរមូលដ្ឋានអាចជួយសម្រួល ដោយជួយចែកប័ណ្ណឲ្យទៅប្រជាជនក្នុងមូលដ្ឋានរបស់ខ្លួនដោយខ្លួនឯង។ ក្រុមនិស្សិត ក៏បានទុកប័ណ្ណទាំងនោះជាមួយនឹងអាជ្ញាធរ។ នៅពេលដែលគាត់(អាជ្ញាធរមូលដ្ឋាន) ចែកប័ណ្ណដល់ក្រុមគ្រួសារនីមួយៗ គាត់បានរំលឹកថា កុំភ្លេចបោះឆ្នោតឲ្យបក្សផង នៅពេលបោះឆ្នោតខាងមុខ បើមិនដូច្នោះទេ ប្រយ័ត្នគេមិនចេញប្លង់រឹងឲ្យ។"* ប្រជាជនមកពីភូមិមួយនៅក្នុងខេត្តឧត្តរមានជ័យ, ខែមិនា ឆ្នាំ ២០១៣។

ទោះបីជាអាជ្ញាធរមូលដ្ឋានមិនស្ថិតក្នុងដែនសមត្ថកិច្ចចេញប័ណ្ណកម្មសិទ្ធិដីអចិន្ត្រៃយ៍ដល់ប្រជាជនក៏ដោយ ការគំរាមកំហែងបែបនេះ មានផលប៉ះពាល់អវិជ្ជមានដល់ប្រជាជនក្នុងមូលដ្ឋានក្នុងការប្រើសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសអ្នកដឹកនាំដោយឆន្ទៈឯករាជ្យនៅក្នុងពេលបោះឆ្នោតថ្នាក់ជាតិនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៣។ ប្រជាជនដែលរស់នៅក្នុងភូមិនេះ បានលើកឡើងថា ក្រុមមន្ត្រីជំនាញ និងនិស្សិតស្ម័គ្រចិត្ត គួរតែមានការទទួលខុសត្រូវខ្ពស់លើភារកិច្ចរបស់ខ្លួន នឹងមិនគួរទុកការងារចែកចាយប័ណ្ណកម្មសិទ្ធិដីបឋមដល់មន្ត្រីអាជ្ញាធរតាមមូលដ្ឋានអនុវត្តទេ ដើម្បីជៀសវាងអាជ្ញាធរមូលដ្ឋានឆ្លៀតឱកាសយកការផ្តល់ប័ណ្ណកម្មសិទ្ធិដីរបស់ប្រជាជន កេងយកចំណេញខាងនយោបាយ និងបម្រើឲ្យផលប្រយោជន៍របស់គណៈបក្សនយោបាយខ្លួន។

### ៣.៦.៤ ការឆ្លៀតឱកាសរំលោភយកដីពីប្រជាជនក្នុងដំណើរការនៃការចុះវាស់វែងដីធ្លីរបស់និស្សិត

នៅក្នុងភូមិខ្លះនៅខេត្តឧត្តរមានជ័យ អ្នកដែលមានដីច្រើនប្រើឱកាសដែលក្រុមនិស្សិតស្ម័គ្រចិត្តចុះវាស់វែងដីធ្លី រំលោភយកដីរបស់ប្រជាជនដែលមានព្រំប្រទល់ជាប់នឹងខ្លួន នៅពេលដែលការវាស់វែងដីធ្លីកំពុងដំណើរការ។ បញ្ហាដែលប្រជាជនជួបប្រទះដូចដែលបានលើកឡើងខាងក្រោមនេះ មិនបានទទួលបទអន្តរាគមន៍ពីសំណាក់អាជ្ញាធរមូលដ្ឋានទេ និងមិនបានផ្តល់ជម្រើសផ្សេងទៀតដល់ប្រជាជនតូចតាចឡើយ។

> *"អ្នកមានអំណាចមួយចំនួនដែលមានដីជាប់នឹងព្រំប្រទល់ដីរបស់ប្រជាពលរដ្ឋ ឆ្លៀតយកឱកាសដែលក្រុមនិស្សិតស្ម័គ្រចិត្តចុះមកធ្វើការវាស់វែង គាបសង្កត់យកដីរបស់ប្រជាជនបន្ថែម។ ប្រសិនបើប្រជាជនមិនព្រមផ្តិតមេដៃប្រគល់ដីដែលគេគាបយកនោះទេ គេក៏នឹងមិនផ្តិតមេដៃធ្វើជាសាក្សីវិញដែរ។ កត្តានេះធ្វើឲ្យប្រជាជនតូចតាច គ្មានជម្រើស ត្រូវតែយល់ព្រមតាមការទាមទារ។"* (ករណីសិក្សាពីខេត្ត ឧត្តរមានជ័យ)

### ៣.៦.៥ ការរើសអើងមកលើប្រជាជន

ប្រជាជនមួយចំនួនក្នុងសហគមន៍ដែលបានចូលរួមនៅក្នុងដំណើរការនៃការចុះវាស់វែងដីធ្លី មានអារម្មណ៍ថា ក្រុមនិស្សិតមួយចំនួនហាក់ដូចជាមានការរើសអើងចំពោះប្រជាជន ដោយសារតែការស្លៀកពាក់របស់ប្រជាជននៅជនបទ។ និស្សិតស្ម័គ្រចិត្តខ្លះប្រើពាក្យសម្តីមិនសមរម្យមកលើប្រជាជន។ ប្រជាជននៅក្នុងភូមិមួយនៅខេត្តឧត្តរមានជ័យលើកឡើងថា ការឆ្លើយតបរបស់និស្សិតស្ម័គ្រចិត្ត ទៅលើសំណើររបស់ប្រជាជន សុំឲ្យពួក

គាត់ចុះមកធ្វើការវាស់វែងគឺ មិនធាប់ហើសដូចនៅពេលដែលអ្នកមានលុយមកស្នើឲ្យពួកគេទៅវាស់វែងដីធ្លីនោះទេ។

> *"បើប្រជាពលរដ្ឋទៅអញ្ជើញក្រុមនិស្សិតឲ្យមកធ្វើការវាស់វែងដីរបស់ពួកខ្ញុំ គឺមិនសូវហើសហួនទេ ស្ទើរចង់ទៅ ស្ទើរមិនចង់ទៅ។ តែបើអ្នកមានលុយវិញ គ្រាន់តែចេញផុតពីឡាន មកសុំឲ្យក្រុមនិស្សិតទៅវាស់ដី ពួកគេក៏ទៅភ្លាម។ ឯចំណែកប្រជាពលរដ្ឋវិញ "អង្គុយចាំមួយព្រឹកហើយ អត់មកវាស់ឲ្យ"។* ប្រជាជននៅខេត្តឧត្តរមានជ័យ ខែឧសភា ឆ្នាំ២០១៣

# ៣.៧ ការចូលរួមរបស់និស្សិតនារីក្នុងដំណើរការវាស់វែងដីធ្លី

ព័ត៌មានដែលមានស្រាប់ដែលអាចរកបាន និងការប្រមូលទិន្នន័យពីប្រជាជនក្នុងមូលដ្ឋាន បង្ហាញថា ការចូលរួមរបស់និស្សិតនារី នៅក្នុងបេសកម្មចុះវាស់វែងដីធ្លីនេះ គឺមានកម្រិតទាប។ ប្រជាជនក្នុងមូលដ្ឋានលើកឡើងថា និស្សិតនារីភាគច្រើនដើរតួនាទីជាអ្នកធ្វើការនៅកន្លែងស្នាក់ការ គឺទទួលខុសត្រូវក្នុងការកត់ត្រា និងបំពេញទម្រង់បែបបទនានា និងចុះបញ្ជីស្នាម។ ពួកគាត់មិនសូវបានគេលើកទឹកចិត្តឲ្យចុះវាស់វែងដីធ្លីទេ។ ប្រជាជនរស់នៅក្នុងភូមិមួយក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់លើកឡើងថា ***"បើសិនជាមាននិស្សិតស្រីជាអ្នកចុះវាស់វែង អាចនឹងមានស្ថានភាពល្អប្រសើរជាងនេះ ព្រោះយើងប្រហែលជាអាចងាយស្រួលនិយាយគ្នា និងយល់ចិត្តរបស់ប្រជាជន ជាងនិស្សិតប្រុសៗ"***

ទោះជាយ៉ាងណាក៏ដោយ តាមការសម្ភាសន៍ព័ត៌មានពីអតីតនិស្សិតស្ម័គ្រចិត្ត មិនមានការបែងចែកដាក់កំហិតតួនាទីថា និស្សិតស្ម័គ្រចិត្តនារីត្រូវតែនៅធ្វើការនៅស្នាក់ការ ដើម្បីបំពេញបែបបទនោះទេ។ ទោះជាយ៉ាងនេះក្តី អត្រានៃការចូលរួមរបស់និស្សិតនារីនៅក្នុងបេសកម្មគឺមានកម្រិតទាបខ្លាំង ហើយពិតណាស់ថា កត្តាប្រពៃណី ទំនៀមទម្លាប់ដែលដាក់កំហិតមកលើការធ្វើការបំលាស់ទី និងសុវត្ថិភាព និងសន្តិសុខនៅពេលចុះបេសកកម្មក្នុងភូមិស្រុកនានា ជាកត្តាមួយចូលរួមចំណែកដល់អត្រានៃការចូលរួមទាបរបស់និស្សិតនារី។ មូលហេតុសំខាន់មួយទៀតអាចបណ្តាលមកពីទស្សនៈទានដែលយល់ថា ការងារបំពេញបេសកកម្មពិសេសដែលមានលក្ខណៈដូចជាការងាររបស់កងកម្លាំងទាហាន (ទាំងឯកសណ្ឋាន បំលាស់ទី ការបោះជំរុំស្នាក់នៅ) ក្នុងការចុះវាស់វែងដីធ្លី ត្រូវបានយល់ថា ជាការងារដែលបុរសត្រូវធ្វើ។ ដូច្នេះ កត្តាទាំងអស់នេះ ក៏ដើរតួនាទីសំខាន់ ដាក់កំហិតការចូលរួមរបស់និស្សិតនារីនៅក្នុងយុទ្ធនាការចុះវាស់វែងដីធ្លីនេះដែរ។

# ៣.៨ ការមិនទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅតាមសហគមន៍ - លើកឡើងក្នុងសមាជប្រជាជនកម្ពុជា

បណ្តាញពហុវិស័យរបស់ប្រជាជនមូលដ្ឋាន មានសមាជិកជាកសិករ អ្នកនេសាទ សកម្មជនព្រៃឈើ សកម្មជនដីធ្លី ជនជាតិដើមភាគតិច សកម្មជនស្ត្រី សកម្មជនការងារ អ្នកប្រកបរបររកស៊ីផ្លូវភេទ សកម្មជនយុវជន សកម្មជនប្រឆាំងនឹងការបណ្តេញចេញ សកម្មជនប្រឆាំងនឹងមូលធននិយម សកម្មជនអ្នកស្រឡាញ់ភេទដូចគ្នា សកម្មជនរងគ្រោះដោយគម្រោងទំនប់វារីអគ្គិសនី និងអ្នកសិល្បៈជាដើម។

ក្នុងខែមិថុនា ឆ្នាំ២០១៣ ពួកគេបានរៀបចំសមាជប្រជាជនកម្ពុជា ដើម្បីផ្ដល់ឱកាសដល់ប្រជាជនក្នុងមូលដ្ឋាន លើកឡើងពីបញ្ហាដែលពួកគេជួបប្រទះនៅក្នុងជីវភាពរស់នៅ មុខរបរ ការងារ និងចងក្រងបញ្ហាទាំងនោះជាសេចក្ដីថ្លែងការណ៍ ដាក់ទៅដល់បេក្ខជនតំណាងរាស្ត្ររបស់គណបក្សនយោបាយ៖ គណបក្សប្រជាជន គណបក្សសង្គ្រោះជាតិ និងគណបក្សហ្វ៊ុនស៊ិនប៉ិច។ គេបានទាមទារអោយបេក្ខជនទាំងនោះសន្យា និងប្ដេជ្ញាចិត្ត ក្នុងការដោះស្រាយបញ្ហាទាំងនោះនៅពេលគេជាប់ឆ្នោតជាតំណាងរាស្ត្រ។ សមាជនេះត្រូវបានរៀបចំឡើងក្នុងភូមិភាគទាំងបី៖ ភូមិភាគពាយ័ព្យ (ប្រព្រឹត្តនៅខេត្តកំពង់ឆ្នាំង) ភូមិភាគឧត្តរ (ប្រព្រឹត្តទៅនៅខេត្តសៀមរាប) និងនៅភូមិភាគនិរតី (ប្រព្រឹត្តទៅទីក្រុងព្រះសីហនុ)។ បញ្ហានៃការបាត់បង់ដីធ្លី និងការមិនទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី កើតឡើងក្នុងកំឡុងពេល និងក្រោយដែលក្រុមនិស្សិតស្ម័គ្រចិត្តចុះទៅវាស់វែង ត្រូវបានលើកឡើងយ៉ាងផុសផុលដោយតំណាងសហគមន៍ដែលចូលរួម។

> *"និស្សិតមួយក្រុម បានចុះមកវាស់ដីនៅក្នុងភូមិរបស់ខ្ញុំ តែពួកគេវាស់ដីឲ្យតែឈ្មួញទេ ដីរបស់ប្រជាជន គឺមិនវាស់ឲ្យទេ។ មុនដំបូង នៅពេលដែលខ្ញុំឮថា មានការចុះមកវាស់វែងដី ខ្ញុំអរណាស់ តែនៅព្រឹកដែលពួកគេចុះមក ខ្ញុំសួរនិស្សិត គេថា គេមិនវាស់ឲ្យទេ ព្រោះដីមានរឿង។ លុះដល់ពេលថ្ងៃ និស្សិតដដែលមកសុំខ្ញុំចូលវាស់ដីរបស់ខ្ញុំ ថាសុំតែចូលចុចដីកីអេសទេ។ ខ្ញុំមិនឲ្យចូល ពីព្រោះបើមិនវាស់ដីខ្ញុំ ឲ្យខ្ញុំផងចូលមកចុចធ្វើអី។"* ប្រជាជន មកពីបណ្ដាញភូមិស្ដន់ ខេត្តសៀមរាប ក្នុងវេទិកាប្រជាជនភូមិភាគឧត្តរ, ២៤ ខែមិថុនា ២០១៣។

តារាងខាងក្រោមបង្ហាញពីទំហំដី និងគ្រួសារសរុបចំនួន ១,៩១៤គ្រួសារ នៅក្នុងខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តក្រចេះ ដែលរងគ្រោះដោយការមិនទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅពេលដែលក្រុមនិស្សិតស្ម័គ្រចិត្តចុះវាស់វែងដីធ្លី។

**តារាងទី៥៖ ឈ្មោះតំបន់ដែលទាមទារ ការផ្ដល់ដីធ្លី និងប័ណ្ណកម្មសិទ្ធិស្របច្បាប់ដល់ប្រជាជន សមាជប្រជាជនកម្ពុជា ១៣-២៤ ខែមិថុនា ឆ្នាំ២០១៣**

| ភូមិ | ឃុំ/ស្រុក | ខេត្ត | គ្រួសារប៉ះពាល់ | ទំហំដី |
|---|---|---|---|---|
| ភូមិភាគនិរតី ខេត្តព្រះសីហនុ ១៩ ខែមិថុនា ២០១៣ | | | | |
| សហគមន៍សេអ៊ីប្រាំ | | ព្រះសីហនុ | ១២៦គ្រួសារ | |
| អន្លង់ត្រី | | ព្រះសីហនុ | ១៥៧គ្រួសារ | ៤០០ហិកតា (ដីផ្ទះ និងដីស្រែ) |
| ព្រែកត្រែង | | | ៩២គ្រួសារ | ១៣៥ហិកតា |
| វាលចន្ទីរ/រាម | រាម/រាម | ព្រះសីហនុ | ៧០គ្រួសារ | ១២៥ហិកតា |
| ស្ពានធេះ | | ព្រះសីហនុ | ១០៧គ្រួសារ | |
| កំពេញចាស់ | | ព្រះសីហនុ | ២៤គ្រួសារ | |
| កំពេញថ្មី | | ព្រះសីហនុ | ១៣៧គ្រួសារ | |
| កោះខ្ចង | អូរជ្រៅ/ព្រៃនប់ | ព្រះសីហនុ | ១៥២គ្រួសារ | |
| ស្ពអំពៅ | | កោះកុង | ២០០គ្រួសារ | ១,៣៦៥ហិកតា |

| ឧត្តរ (ខេត្តសៀមរាប) ២៤ ខែមិថុនា ២០១៣ | | | | |
|---|---|---|---|---|
| តានី | រុនតាឯក/ បន្ទាយស្រី | សៀមរាប | ៣៨គ្រួសារ | ១៥៨ហិកតា |
| តាពេន | | សៀមរាប | ៩០គ្រួសារ | ១៨៣ហិកតា |
| ស្ពន់ | បន្ទាយស្រី | សៀមរាប | ១១៧គ្រួសារ | |
| វើល | វើល/ពួក | សៀមរាប | ១២ គ្រួសារ | |
| ត្បែងលិច | | សៀមរាប | ១០៥គ្រួសារ | ៤២៧ហិកតា |
| ជីក្រែង | ជីក្រែង | សៀមរាប | | ៤៧៥ហិកតា |
| ស្នាសង្គ្រាម | បល្ល័ង្គ/ប្រាសាទ បាគង | សៀមរាប | ៨៧គ្រួសារ | ២៥៤ហិកតា |
| | ស្នួល | ក្រចេះ | ៤០០គ្រួសារ[10] | |
| **សរុប** | | | | **១,៩១៤ គ្រួសារ** |

ប្រភព៖ សេចក្តីថ្លែងការណ៍សមាជប្រជាជនកម្ពុជា ភូមិភាគនិរតី និងភូមិភាគឧត្តរ ការទាមទារឲ្យមានដំណោះស្រាយ ក្នុង រយៈពេលខ្លី របស់បណ្តាញដែលបានចូលរួម ដាក់ជូនតំណាងរាស្ត្រ បេក្ខជនតំណាងរាស្ត្ររបស់គណបក្សប្រជាជន កម្ពុជា គណបក្សសង្គ្រោះជាតិ និងគណបក្សហ៊ុនស៊ិនប៉ិច។

[10] ដីក្រុមហ៊ុនប៊ិនភឿក ១ និងប៊ិនភឿក២ រំលោភយកក្នុងស្រុកស្នួល ខេត្តក្រចេះ

# ករណីសិក្សាផ្ដោតលើតំបន់ជាក់លាក់

ផ្នែកនេះ បង្ហាញពីករណីសិក្សាចំនួនប្រាំមួយមកពីខេត្តកំពង់ឆ្នាំង, ពោធិ៍សាត់, បាត់ដំបង, និងខេត្តឧត្តរមានជ័យ។ ករណីសិក្សាទី១ បង្ហាញពីបញ្ហាប្រសិទ្ធិភាពនៃប័ណ្ណកម្មសិទ្ធិរបស់ប្រជាជន១១គ្រួសារ ដែលទទួលបានប័ណ្ណ ប៉ុន្តែមិនអាចចូលទៅប្រើប្រាស់ផ្ទៃដីទាំងអស់របស់ខ្លួនដែលមានចែងនៅក្នុងប័ណ្ណ ដោយសារក្រុមហ៊ុនក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចភាពីម៉ិច រំលោភយកទៅប្រើប្រាស់ដាំដំណាំកសិឧស្សាហកម្ម។ ករណីសិក្សាទី២ លើកឡើងពីប្រជាជនក្នុងភូមិមួយចំនួនក្នុងស្រុកក្រគរដែលត្រូវបានអាជ្ញាធរមូលដ្ឋានដកហូតយកប័ណ្ណកម្មសិទ្ធិដីធ្លី ដោយសំអាងថាដីទាំងនោះស្ថិតក្នុងតំបន់ដីព្រៃសហគមន៍។

ករណីសិក្សាទី៣ សង្កត់ធ្ងន់ទៅលើភូមិរំចេក ក្នុងខេត្តឧត្តរមានជ័យ ដែលមានការគាបសង្កត់យកដីពីប្រជាជនក្រីក្រតូចតាច ពីសំណាក់អ្នកមាននៅក្នុងដំណើរការវាស់វែងដីធ្លី និងបញ្ហាជម្លោះដីព្រំប្រទល់ជាមួយភូមិជិតខាងដែលធ្វើឲ្យដីច្រើនហិកតាមិនទាន់ត្រូវបានវាស់វែង។ ករណីសិក្សាចំនួនបីផ្សេងទៀត ឆ្លុះបញ្ចាំងពីមូលហេតុនៃការខកខានមិនបានវាស់វែងដីធ្លី ដោយសារតែអត្រាចំណាកស្រុកខ្ពស់ទៅធ្វើការនៅប្រទេសថៃ, ការរង់ចាំប័ណ្ណកម្មសិទ្ធិរយៈពេលយូររបស់ប្រជាជនក្នុងខេត្តឧត្តរមានជ័យ ក្តីបារម្ភរបស់ប្រជាជនពីប្រសិទ្ធិភាពនៃប័ណ្ណកម្មសិទ្ធិ (ប្រសិនបើនាយករដ្ឋមន្រ្តីហ៊ុន សែនមិនកាន់អំណាច) និងការហាមប្រាមដល់ប្រជាជន ក្នុងភូមិអញ្ចាញរូង ក្នុងខេត្តកំពង់ឆ្នាំង ក្នុងការចូលទៅឈូសឆាយដីប្រើប្រាស់និងធ្វើស្រែចំការទោះបីជាពួកគាត់បានទទួលប័ណ្ណកម្មសិទ្ធិស្របច្បាប់ហើយក៏ដោយ។

## ករណីសិក្សាទី១៖ ប្រសិទ្ធិភាពនៃប័ណ្ណកម្មសិទ្ធិដីធ្លីថ្មី-ករណីប្រជាជន១១[11]គ្រួសារ

ភាពមិនប្រក្រតីមួយចំនួន បានកើតឡើងទាក់ទងនឹងប្រសិទ្ធិភាពនៃប័ណ្ណកម្មសិទ្ធិដីធ្លី និងការប្រើប្រាស់ដី ក្រោយពីប្រជាពលរដ្ឋម្ចាស់ដីទទួលបានប័ណ្ណពីក្រុមនិស្សិតស្ម័គ្រចិត្ត និងមន្ត្រីជំនាញ។ ករណីជាក់ស្តែង ប្រជាជនចំនួន១១គ្រួសារ ដែលមានដីលំនៅស្ថានក្នុងភូមិទទឹង និងភូមិដូង ក្នុងឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់ បានទទួលប័ណ្ណកម្មសិទ្ធិដីធ្លី កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ ដែលចេញដោយលោកវិស្វករចេង ឡៃ, ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់។ ភាពចម្រូងចម្រាស់បានកើតឡើង រវាងប្រជាជនម្ចាស់ដីនិងក្រុមហ៊ុន ដែលស្ថិតនៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនភាពីម៉ិច រារាំងមិនឲ្យប្រជាជនម្ចាស់ដីចូលទៅធ្វើអាជីវកម្មលើដីកសិកម្មរបស់ពួកគាត់ទោះបីជាមានប័ណ្ណកម្មសិទ្ធិដីស្របច្បាប់ក៏ដោយ។

មានប្រជាជនដប់មួយគ្រួសារ ប្រកបចិញ្ចឹមជីវិតដោយការធ្វើស្រែចំការ និងដាំដំណាំហូបផ្លែផ្លែដូចជា៖ ស្វាយចន្ទី សណ្ដែក ស្វាយ និងខ្នុរក្នុងដីចំការរបស់ខ្លួនក្នុងចំនុចដំណាក់ព្រីង នៅមិនឆ្ងាយពីភូមិក្រឡាញ់ ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់ប៉ុន្មានទេ។ ប្រជាជនដប់គ្រួសារធ្វើចំការនៅជាប់ៗគ្នា ហើយដីចំការរបស់ពួកគាត់សន្ធឹងពីមាត់ផ្លូវរហូតដល់ព្រំដីអ្នកខាងក្រោយមានចំងាយរាប់រយម៉ែត្រ។ (គ្រួសារទី១១មានដីចំការចំការប្រមាណ២-៣ រយម៉ែត្រពីអ្នក១០គ្រួសារទៀត)។ ដីកសិកម្ម និងដីលំនៅដ្ឋាននៅក្នុងឃុំនេះ និងឃុំ

[11] ប្រភពសារព័ត៌មាននានា រាយការណ៍ពីករណីរបស់ប្រជាជន ១០គ្រួសារ តែការពិត គឺមានប្រជាជនចំនួន១១គ្រួសារ។ គ្រួសារមួយដែលជារឿយៗ ត្រូវបានគេដកចេញ គឺដោយសារតែទីតាំងដីរបស់គាត់ នៅឆ្ងាយពីដីរបស់ប្រជាជន១០គ្រួសារ (មានដីនៅជាប់ៗគ្នា)។

ដទៃទៀតនៅក្នុងស្រុកក្រគរទាំងមូលធ្លាក់ចូលជាចំណីដីសម្បទានសេដ្ឋកិច្ចដ៏ធំធេងរបស់ក្រុមហ៊ុនភាពីម៉ិច ដែលមានទំហំសរុបចំនួនជាងបីសែន (៣០០,០០០)ហិកតា ហើយដែលរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាផ្តល់អោយក្រុមហ៊ុននេះនៅឆ្នាំ២០០០។ វិវាទរវាងក្រុមហ៊ុនភាពីម៉ិច និងអ្នកភូមិបានបន្តកើតឡើងជារៀងរហូតមក។

## ក. ប្រវត្តិនៃបញ្ហា

ប្រជាជន១១ គ្រួសារនេះ មានដីកសិកម្មសម្រាប់ប្រកបរបរចិញ្ចឹមជីវិតដោយការធ្វើស្រែចំការ និងដំណាំហូបផ្លែដូចជាស្វាយចន្ទី សណ្តែក ស្វាយ និងខ្នុរ ជាដើម នៅត្រង់ចំណុចដំណាក់ព្រីង ក្នុងភូមិក្រឡាញ់ ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់។ ដីរបស់ប្រជាជនចំនួន១០គ្រួសារ ស្ថិតនៅជាប់ៗគ្នា ចំណែកមួយគ្រួសារទៀតនៅដាច់ពីគេ។ គួររំលឹកថា ដីលំនៅស្ថាន និងដីប្រកបរបរកសិកម្មរបស់ប្រជាជនក្នុងឃុំនេះ នឹងឃុំជិតខាងក្នុងស្រុកក្រគ គឺស្ថិតនៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនភាពីម៉ិច ទំហំសាមសិបម៉ឺន (៣០០,០០០)ហិកតា ដែលរដ្ឋាភិបាលកម្ពុជា បានសម្បទានដីឲ្យក្រុមហ៊ុននេះនៅឆ្នាំ២០០០[12]។ បញ្ហាចម្រូងចម្រះ និងជម្លោះជាច្រើនរវាងប្រជាជនម្ចាស់ដី និងក្រុមហ៊ុនភាពីម៉ិចកើតមានជាហូរហែ រាប់ឆ្នាំមកហើយ។ ប្រជាពលរដ្ឋរស់នៅទីនោះបានប្រាប់ក្រុមយើងថា មុនការចាប់ផ្តើមអនុវត្តបទបញ្ជា០១(បប) "នយោបាយចាស់ សកម្មភាពថ្មី លើវិស័យដីធ្លី" របស់នាយករដ្ឋមន្ត្រីហ៊ុន សែន ក្រុមហ៊ុនបានធ្វើការឈូសឆាយបំផ្លាញដំណាំក្នុងចំការរបស់គាត់ ហើយឈូសអស់ដីមួយឆ្នូតទំហំជាងមួយរយម៉ែត្រតាមបណ្តោយផ្លូវ។ ប្រជាពលរដ្ឋម្ចាស់ដីបានប្តឹងទៅអាជ្ញាធរមូលដ្ឋាន ឲ្យជួយរកយុត្តិធម៌ ប៉ុន្តែមិនមានដំណោះស្រាយជាក់លាក់ណាមួយដល់ពួកគាត់ទេ។

តំណាងប្រជាពលរដ្ឋប្រាំពីរគ្រួសារបានប្រាប់ថា នៅពេលដែលក្រុមនិស្សិតស្ម័គ្រចិត្ត និងក្រុមមន្ត្រីជំនាញចុះមកវាស់វែងដីរបស់ពួកគាត់នៅខែកក្កដា ឆ្នាំ២០១២ ក្រុមហ៊ុនបានដាំដំឡូងមីលើដីនេះអស់ជាងមួយឆ្នាំហើយ។ តំណាងក្រុមហ៊ុន អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋម្ចាស់ដីបានព្រមគ្នាថា ក្រោយក្រុមហ៊ុនប្រមូលផលដំឡូងអស់ហើយ គេនឹងបង្វិលដីនោះមកអោយប្រជាពលរដ្ឋម្ចាស់ដើមវិញ។ ក្រោមការព្រមព្រៀងបែបនេះ ប្រជាជនម្ចាស់ដីទាំងដប់មួយគ្រួសារបានយល់ព្រមឲ្យមានការវាស់វែងដីដោយក្រុមនិស្សិតស្មគ្រចិត្ត ហើយក្រុមនិស្សិត ក៏បានវាស់វែងចាប់ពីចិញ្ចើមផ្លូវរហូតមកទល់នឹងព្រំដីអ្នកខាងក្រោយ ត្រឹមត្រូវតាមទំហំដីដែលពួកគាត់មាន មុននឹងចេញសាលាកប័ត្របណ្តោះអាសន្នអោយពួកគាត់។ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ ប្រជាជនម្ចាស់ដីទាំង ១១គ្រួសារ បានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីរបស់គាត់ដែលចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ ចុះហត្ថលេខាដោយលោក **វិស្វករ ចេង ឡៃ**។ ប៉ុន្តែ ពួកគាត់សំគាល់ឃើញថា ប្លង់កម្មសិទ្ធិរបស់ពួកគាត់មានក្បាលដីមិនជាប់នឹងចិញ្ចើមផ្លូវដូចការវាស់វែងរបស់ក្រុមនិស្សិតទេ។ នៅពេលពួកគាត់ចាប់ផ្តើមទៅប្រើប្រាស់ដីរបស់គាត់ដើម្បីដាំដំណាំផ្សេងៗ តំណាងក្រុមហ៊ុនមិនអនុញ្ញាតឲ្យធ្វើទេ ដោយខាងក្រុមហ៊ុនប្រាប់ទៅប្រជាជនថា ដីនេះជាដីរបស់ក្រុមហ៊ុន។

[12] ប្រជាជនក្នុងសហគមន៍ដែលចុះធ្វើការប្រមូលទិន្នន័យចងចាំថា ក្រុមហ៊ុនភាពីម៉ិច ចូលមកអនុវត្តសកម្មភាពការងាររបស់ខ្លួនតាំងពីឆ្នាំ១៩៩៧មកម្ល៉េះ។




គំរូប័ណ្ណកម្មសិទ្ធិរបស់គ្រួសាររងគ្រោះម្នាក់ក្នុងចំណោមប្រជាជន ១១គ្រួសារ ដែលចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដែលបង្ហាញពីទំហំដីប្រមាណបីហិកតា ឬធំជាងនេះ។
រូបថត៖ ក្រុមស្រាវជ្រាវ/១៩ ខែឧសភា ឆ្នាំ២០១៣

ប្រជាពលរដ្ឋម្ចាស់ដីម្នាក់ ក្នុងចំណោមម្ចាស់ដីទាំង១១[13]គ្រួសារ លើកឡើងថា៖ ដីចម្ការរបស់គាត់ មានទំហំប្រមាណជាងប្រាំហិកតា តែតាមរយៈការវាស់វែងរបស់ក្រុមនិស្សិត គឺវាស់ឲ្យគ្រួសារគាត់តែក្នុងទំហំបីហិកតា។ ដីសល់ប៉ុន្មាន អាជ្ញាធរសំរាំងទុកអោយក្រុមហ៊ុន។ តំណាងក្រុមហ៊ុនបានប្រាប់ប្រជាពលរដ្ឋម្ចាស់ដីទាំងនោះថា ដីសេសសល់ទាំងប៉ុន្មានជាដីរបស់ក្រុមហ៊ុន។ ពេលវិទ្យុអាស៊ីសេរី សម្ភាសតំណាងក្រុមហ៊ុននៅការដ្ឋាន១.៧ ក្នុងខែឧសភា ២០១៣ តំណាងនោះបានអះអាងថា អាជ្ញាធរឃុំបានព្រមព្រៀងអោយក្រុមហ៊ុនប្រើប្រាស់ដីនេះ ម្លោះហើយក្រុមហ៊ុនមិនប្រគល់ដីនេះមកអោយប្រជាពលរដ្ឋវិញទេ លើកលែងតែអាជ្ញាធរឃុំប្រាប់ថាអោយបង្វិលដីនេះទៅប្រជាពលរដ្ឋវិញ។ តំណាងក្រុមហ៊ុនបានផ្តល់ហេតុផលថាក្រុមហ៊ុនបានដាំដំណាំនៅទីនេះជាងបីឆ្នាំហើយ។ ពេលវិទ្យុអាស៊ីសេរីសួរទៅសមាជិកក្រុមប្រឹក្សាឃុំក្បាលត្រាច គាត់ថាដីនេះជាដីរបស់គ្រួសារប្រជាពលរដ្ឋ មិនមែនជាដីរបស់ក្រុមហ៊ុនទេ។ (វិទ្យុអាស៊ីសេរី, ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣)។

## ខ. ឫសគល់នៃបញ្ហា៖ ប្លង់ដីត្រួតគ្នា

នៅពេលដែលក្រុមនិស្សិតស្ម័គ្រចិត្ត និងមន្ត្រីជំនាញចុះមកវាស់វែងដីដល់ប្រជាពលរដ្ឋម្ចាស់ដីកាលពីខែសីហា ឆ្នាំ២០១៣ គឺវាស់ចាប់ពីចំណុចដីជាប់ថ្នល់ទៅខាងស្តាំដៃ (សូមមើលរូបភាព) រហូតមកទល់នឹងចំណុចព្រំប្រទល់ជាប់នឹងដីរបស់ប្រជាពលរដ្ឋផ្សេងទៀត ហើយក៏បានចេញសាលាកប័ត្រអោយពួកគាត់។ តាមការព្រមព្រៀងរវាងតំណាងក្រុមហ៊ុន ប្រជាពលរដ្ឋម្ចាស់ដី និងអាជ្ញាធរមូលដ្ឋាន ទំហំដីបានវាស់វែងអោយពួកគាត់រាប់បញ្ចូលទាំងដីដែលក្រុមហ៊ុនដាំដំឡូងមីផង គឺចាប់ពីចិញ្ចើមផ្លូវទៅក្នុងមានជំរៅប្រមាណ១០០ម៉ែត្រ។ តែពេលពលរដ្ឋម្ចាស់ដីបានទទួលប្លង់រឹង ពួកគាត់សង្កេតឃើញថាចំណែកដីដែលក្រុមហ៊ុនបានដាំដំឡូងមីមិនត្រូវបានវាស់បញ្ចូលក្នុងប្លង់ទេ។ ពួកគាត់បានទទួលទំហំដីតូចជាងពេលក្រុមនិស្សិតវាស់វែងអោយពួកគាត់ គឺបានត្រឹមតែមួយ ឬពីរហិកតាសំរាប់មួយគ្រួសារប៉ុណ្ណោះ។ ពួកគាត់ខ្លះបានប្រាប់ថា ក្រុមហ៊ុនថែមទាំងរារាំងពួកគាត់មិនអោយប្រើប្រាស់ដីរបស់ពួកគាត់ទៀតផង។

[13] វិទ្យុអាស៊ីសេរីរាយការថា ១០គ្រួសារ។



ពលរដ្ឋម្ចាស់ដីបានអះអាងថាដីពួកគាត់គឺចាប់ពីចិញ្ចើមផ្លូវ (ត្រង់ចុងព្រួញក្រហម)។ តែនៅពេលបានទទួលប្លង់រឹង ទំហំដីរួញអស់១០០ ម៉ែត្រ គឺចាប់ពីចិញ្ចើមផ្លូវទៅក្នុង ចំកន្លែងដែលក្រុមហ៊ុនបានឈូសឆាយដាំដំឡូងមី។ ចុងព្រួញបៃតងចង្អុលប្រាប់ពីចំនុចព្រំប្រទល់ ដែលដីពួកគាត់បានទទួលក្នុងប្លង់រឹង នេះបើមើលតាមចំណារក្នុងប្លង់រឹងរបស់ពួកគាត់។ ព្រួញលឿងចង្អុលបង្ហាញពីប្រឡាយទឹកដែលក្រុមហ៊ុនបានជីកលើដីរបស់ពួកគាត់។ រូបថតដោយក្រុមស្រាវជ្រាវ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៣។

ក្រោយពេលដែលប្រជាជនម្ចាស់ដីទាំង១០មួយគ្រួសារបដិសេធមិនទទួលយកដី អាជ្ញាធរមូលដ្ឋាន មន្ត្រីមន្ទីសុរិយោដីខេត្ត អាជ្ញាធរស្រុកក្រគរ ក្រុមប្រឹក្សាឃុំក្បាលត្រាចចុះធ្វើអន្តរាគមន៍ គឺចុះមកធ្វើការវាស់វែងដីប្រជាពលរដ្ឋម្តងទៀត។ ប្រជាពលរដ្ឋម្ចាស់ដីនៅតែមិនស្កប់ចិត្ត ហើយពួកគាត់បានបដិសេធលទ្ធផលនៃការវាស់វែងថ្មីនោះទៀត។ អាជ្ញាធរមូលដ្ឋាន និងបុគ្គលិកជំនាញអះអាងថា លទ្ធផលខុសគ្នានេះគឺដោយសារកំហុសបច្ចេកទេសក្នុងឧបករណ៍ចុចដីភីអេស។ ចំឡើយបុគ្គលិកជំនាញយ៉ាងនេះបានធ្វើអោយពលរដ្ឋម្ចាស់ដីម្នាក់កើតក្តីសង្ស័យថា តើវាពិតជាកំហុសបច្ចេកទេសឧបករណ៍ជីភីអេសមែន ឬយ៉ាងណា៖

> ***"បង តើអា ជី.ភី.អេស. និងអាទាញខ្សែម៉ែត្រខ្មែរហ្នឹង មួយណាត្រឹមត្រូវជាង? ខ្ញុំគិតថា ជីភីអេស វាត្រឹមត្រូវហើយ តែខ្លាចតែមនុស្សវាមិនត្រឹមត្រូវ!!!"*** ប្រជាជនរងគ្រោះម្ចាស់ដី ១០គ្រួសារ, ខែឧសភា ២០១៣

តាមការបញ្ជាក់ពីមន្ត្រីមួយរូបនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឧបករណ៍ជីភីអេសកាន់ដៃនេះ មិនជាក់លាក់ទាំងស្រុងទេ ប៉ុន្តែតែកម្រិតលំអៀងរបស់វា អាចទទួលយកបាន។ កម្រិតលំអៀងច្រើនបំផុត គឺប្រមាណជាបីម៉ែត្រប៉ុណ្ណោះ។ តែអ្វីដែលត្រូវការ គឺអាកាសធាតុល្អ ទើបសញ្ញាសំគាល់បានច្បាស់ល្អ (អតីតប្រធានក្រុមនិស្សិតស្ម័គ្រចិត្ត និងជាមន្ត្រីក្រសួងរៀបចំដែនដី ខែឧសភា ២០១៣)។ ដូច្នេះ ករណីដែលមន្ត្រីជំនាញខេត្តពោធិ៍សាត់លើកឡើងថា បញ្ហាដីខុសទំហំដែលមាននៅក្នុងប័ណ្ណកម្មសិទ្ធិក្បាលដីរបស់ប្រជាជន១១គ្រួសារ បណ្តាលមកពីបញ្ហាបច្ចេកទេសនោះ មិនមែនជាមូលហេតុពិតប្រាកដទេ។

បើតាមលោក **វិស្វករ ចេង ឡៃ** ប្រធានមន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់៖ *"ប្រជាពលរដ្ឋបានទៅចង្អុលដីខុសកន្លែងពីដីដែលមន្ទីរសុរិយោដី និងភូមិសាស្ត្រខេត្តបានចេញប្លង់ឲ្យពួកគាត់។ ប័ណ្ណសិទ្ធិកម្មសិទ្ធិដែលប្រជាជនទាំងដប់គ្រួសារនោះមាន គឺស្ថិតនៅលើដីប្រមាណ១០០ម៉ែត្រ ពីកន្លែងដីដែលក្រុមហ៊ុនចិនកំពុងដាំដំឡូងបច្ចុប្បន្ន។"* វិទ្យុអាស៊ីសេរី (៧ ឧសភា ២០១៣)។

ក៏ប៉ុន្តែលោក **វិស្វករ ចេង ឡៃ** មិនបានបញ្ជាក់ពីចំណុចដែលប្រជាជនបានព្រមព្រៀងគ្នាវាស់វែងជាមួយនឹងអាជ្ញាធរ ក្រុមហ៊ុន និងក្រុមនិស្សិតស្មគ្រចិត្តក្នុងពេលវាស់វែងដីកាលពីពាក់កណ្តាលឆ្នាំ២០១២ នោះទេ។ ប្រជាជនម្ចាស់ដីបញ្ជាក់ថា នៅពេលវាស់វែងជាមួយនឹងក្រុមនិស្សិតស្មគ្រចិត្ត គឺវាស់ចាប់ពីចំណុចដើមផ្លូវទៅ។ ចំណុចព្រំប្រទល់ដែលមន្ត្រីសុរិយោដីខេត្ត និងអាជ្ញាធរមូលដ្ឋានព្យាយាមវាស់វែងដោយប្រើដីកីអេសពេលក្រោយមកទៀតនោះ គឺឃ្លាតចំងាយ១០០ម៉ែត្រពីមាត់ផ្លូវថ្នល់ទៅ (ចំណុចដែលក្រុមហ៊ុនកំពុងប្រើប្រាស់ដីប្រជាជនដាំដំឡូង)។ ទំហំដីដែលប្រជាពលរដ្ឋទទួលបានវាតិចជាងទំហំបីហិកតាម្ភៃអា ដែលលោកបានចុះហត្ថលេខានៅលើប័ណ្ណកម្មសិទ្ធិ និងត្រួតលើដីរបស់គ្រួសារប្រជាជនផ្សេងទៀតដែលមានប័ណ្ណកម្មសិទ្ធិ និងចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់។

> *"កាលពីឆ្នាំកន្លងទៅមិញ ចិនឈូសដីនេះ តែខាងមេឃុំ-មេភូមិ ចុះមកដោះស្រាយឲ្យ ព្រោះពួកខ្ញុំបានទៅប្តឹងតវ៉ាដល់ការដ្ឋានក្រុមហ៊ុនចិន។ ដីខ្ញុំនេះ បានប្លង់ហើយកាលពីពេលដែលក្រុមនិស្សិតចុះមកវាស់ដី។ ប៉ុន្តែ ដីរបស់ប្រជាជន១០គ្រួសារទៀត ក៏បានប្លង់ដែរ ប៉ុន្តែគេរុញប្លង់ដី១០គ្រួសារនោះ ចូលមកលើដីរបស់ខ្ញុំ មកត្រឹមរបង តែគេកាត់ឲ្យពួកប្រជាជន១០គ្រួសារ។ ខ្ញុំបានសួរទៅមន្ត្រីដែលចុះមកវាស់ដីថាហេតុអ្វី ក៏វាស់ដីរុញចូលមកលើដីខ្ញុំ?" មន្ត្រីនោះអះអាងថា មកពីអ្នកថតខុសបច្ចេកទេស។ ប៉ុន្តែ ខ្ញុំដឹងថា ក្រុមនិស្សិតគឺមិនស្គាល់ដីថាកន្លែងណាជាកន្លែងណាទេ ទាល់តែយើង(ប្រជាជន)មកចង្អុលប្រាប់ទើបគាត់ហ៊ានវាស់ឲ្យ។ ចុះឥឡូវហេតុអ្វីបានជាមកថា ខុសបច្ចេកទេស ហើយប្លង់ត្រួតគ្នាទៀត។ ទាល់តែប្លង់ត្រូវគ្នា ទើបខ្ញុំយក បើមិនត្រូវ ខ្ញុំមិនព្រមទទួលទេ។ តែមន្ត្រីម្នាក់នោះ បែរជាសំឡុតខ្ញុំថា កុំឲ្យនិយាយច្រើនព្រោះ "យើង(ប្រជាជន) មិនដឹងពីដីកីអេសទេ។" ប៉ុន្តែខ្ញុំជឿជាក់ថា ខ្ញុំ និងប្រជាជនផ្សេងទៀត ស្គាល់ដីខ្ញុំច្បាស់ណាស់..."* ម្ចាស់ដីដែលជាប់ព្រំប្រទល់នឹងដីរបស់ប្រជាជនដប់មួយគ្រួសារ ក្នុងចំណុចដំណាក់ព្រីង, ខែឧសភា ឆ្នាំ២០១៣។

> *"គេចុះមកវាស់ កាលពីម្សិលម៉ិ (១៧ ឧសភា ២០១៣)។ គេ(អាជ្ញាធរ) ចុះមកបួន-ប្រាំលើកហើយ តែអត់បានលទ្ធផលអ្វីទាំងអស់។ គេចុះមកចុច ថាមកកំណត់ព្រំ តែមិនបានកំណត់ព្រំអីទេ។ ព្រោះដីមានតែបន្តិចនេះ... បើមានតែប៉ុណ្ណេះ ធ្វើម្តេចចែកគ្នាគ្រប់បានម្នាក់បីហិកតា។ បើដើរពីនេះទៅ គឺប្រហែលជាសាមសិបម៉ែត្រប៉ុណ្ណោះ តើទៅរកឯណាគ្រប់? ដី-សៗនោះ ចិនឈូសដាំដំឡូងអស់ហើយ។ ដីនោះជាដីរបស់ប្រជាជនដប់គ្រួសារ តាំងពីនេះទៅហួតដល់ថ្នល់មុខ។"* ប្រជាជនដែលមានព្រំប្រទល់ជាប់នឹងដីរបស់ប្រជាជនដប់មួយគ្រួសារ ខែឧសភា ឆ្នាំ២០១៣។

ក្នុងពេលចែករំលែកព័ត៌មានជាមួយនឹងក្រុមចងក្រងឯកសារកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ប្រជាជនដែលជាម្ចាស់ដីក្នុងចំណោម១១គ្រួសារ មូលមតិគ្នាមិនទទួលយកដីដែលវាស់វែងជាថ្មីដោយមន្ត្រីជំនាញនោះទេ ដោយសារតែដីនេះជាន់ទៅលើដីរបស់ប្រជាជនក្នុងមូលដ្ឋានដែលមានប័ណ្ណកម្មសិទ្ធិរួចហើយ។ ប្រសិនបើពួកគាត់ទទួលយក នឹងបណ្តាលឲ្យមានជម្លោះដីធ្លីរវាងប្រជាជននឹងប្រជាជនគ្នាឯង ខណៈដែលអ្នករំលោភយកដីពិតប្រាកដ គឺជាក្រុមហ៊ុន និងអាជ្ញាធរមន្ត្រីជំនាញដែលពាក់ព័ន្ធ។

### គ. ការគំរាមកំហែង ពីសំណាក់អាជ្ញាធរ និងមន្រ្តីជំនាញ

ការតវ៉ាជាច្រើនលើក ច្រើនសាររបស់ប្រជាជនរងគ្រោះទាំង១១គ្រួសារ ទាមទារសិទ្ធិក្នុងការចូលទៅប្រើប្រាស់ដីរបស់ខ្លួនតាមទំហំដីដែលមានចែងនៅក្នុងប័ណ្ណកម្មសិទ្ធិដីធ្លី ធ្វើឲ្យពួកគេទទួលរងនូវការសំឡុងគំរាមកំហែងជាច្រើនលើកច្រើនសារតាមរយៈពាក្យសំដីពីសំណាក់អាជ្ញាធរ។ ជាក់ស្តែងលោក **វិស្វករ ចេង ឡៃ** ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់ខ្លួនឯងធ្លាប់បានធ្វើការគំរាមកំហែងដល់គ្រួសាររងគ្រោះថា *"ប័ណ្ណ(កម្មសិទ្ធិដីធ្លី)ហ្នឹង ខ្ញុំចង់ដកវិញពេលណាក៏បានដែរ,"* នៅពេលដែលគ្រួសារទាំងនោះបដិសេធ មិនទទួលយកដីដែលមានទំហំមិនត្រឹមត្រូវតាមប្លង់។ សម្រង់ពាក្យសំដីខាងក្រោមនេះ គឺជាពាក្យពេចន៍ដែលអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធនឹងធ្លាប់ចុះវាស់វែងដីរបស់ប្រជាជនធ្លាប់បានប្រើ ដើម្បីសម្លុតគំរាមកំហែងមកលើប្រជាជនទាំង១១គ្រួសារដែលរងគ្រោះ។

- *"គេវាស់ឲ្យដដែលៗ តែមិនដែលត្រឹមត្រូវទេ"*
- *"វាស់ឲ្យហើយ នៅតែមិនសុខចិត្តទៀត មិនស្តាប់ពួកខ្ញុំសោះ។"* អាជ្ញាធរសំឡុតប្រជាជនម្ចាស់ដី
- *"ផ្តិតមេដៃមក ព្រមព្រៀងទៅ។ បន្ទាប់មក ចង់ដាំអីក៏ដាំទៅ ដាំដំឡូង ដាំស្រូវក៏ដាំទៅ។"* អាជ្ញាធរមូលដ្ឋាន
- *"មេឃុំផ្តិតមេដៃចុះកុងត្រាជាមួយចិនហើយ បើសិនបងប្អូនចង់ដោះស្រាយ ទៅដោះស្រាយជាមួយឃុំទៅ។"* តំណាងក្រុមហ៊ុនចិន
- *"កុំធ្វើខ្លាំងពេក ប្រយ័ត្នពេលក្រោយមកសំពះអង្វរគេវិញ"* លោក អុក ញ៉ន មេឃុំក្បាលត្រាច
- *"ប្រជាជនពូកែតវ៉ាប្រឆាំងណាស់ ខ្លាំងៗចាប់ដាក់ឡានអស់ឥឡូវហ្នឹងហើយ"* អាជ្ញាធរ និងមន្រ្តីជំនាញតែងតែប្រមាថប្រជាជននៅពេលចុះមកវាស់ដោយការចុចដីកីអេស

ការគំរាមកំហែងទាំងនេះ គឺបណ្តាលមកពីប្រជាជនទាំង១១គ្រួសារ បដិសេធមិនទទួលយកដីខុសពីទំហំក្នុងប្លង់។ ការពន្យាពេលក្នុងការដោះស្រាយបញ្ហាដីធ្លីរបស់ពួកគាត់ឲ្យបានជ្រះស្រឡះ ហើយនៅតែបន្តអូសបន្លាយ ធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន ព្រោះដល់រដូវដែលគាត់ត្រូវប្រើប្រាស់ដីដើម្បីដាំដំណាំ/ស្រូវសម្រាប់ផ្គត់ផ្គង់គ្រួសារ។

### ឃ. ផលប៉ះពាល់មកលើគ្រួសាររងគ្រោះ

***"គេប្រាប់ថា ឲ្យអ៊ំព្រមទៅ ចាំគេដោះស្រាយឲ្យ។ តើឲ្យអ៊ំព្រមយ៉ាងម៉េចកើត បើដីវាស់ឲ្យអ៊ំមិនគ្រប់ផង។ គេសន្យាថា ចាំមកដោះស្រាយឲ្យ មិនដឹងដោះស្រាយពេលណាទៀតទេ បើពេលនេះជារដូវដែលត្រូវចាប់ផ្តើមធ្វើការ(ដាំដុះ)នៅលើដីហើយ។"*** ស្រ្តីមេម៉ាយជាគ្រួសាររងគ្រោះ ខែឧសភា ២០១៣

ប្រជាជនទាំង១១គ្រួសារដែលមានបញ្ហាការប្រើប្រាស់ដីដែលខ្លួនមានកម្មសិទ្ធិជាម្ចាស់ស្របច្បាប់បញ្ជាក់ថា ក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ ពួកគាត់បាត់បង់ជីវភាពគ្រួសារដោយសារតែជាប់រវល់នឹងបញ្ហាដីដែលមិនគ្រប់តាមទំហំដូចមានក្នុងប្លង់។ កត្តានេះ បណ្តាលឲ្យគ្រួសារនីមួយៗ ជាពិសេសគ្រួសារដែលមាន

ស្ត្រីមេម៉ាយជាមេគ្រួសារ វល់តែនឹងរឿងដោះស្រាយទំហំដីថ្លីដែលធ្វើឡើងម្តងហើយម្តងទៀត ពីសំណាក់មន្ត្រីជំនាញ និងអាជ្ញាធរមូលដ្ឋាន និងខកខានមិនបានប្រើប្រាស់ដីរបស់ខ្លួនក្នុងការដាំដុះ។

> *"វល់តែនឹងរឿងដីធ្លីហ្នឹង ដើរហូតមិនបានទៅប្រកបការងាររកស៊ីអ្វីទេ ដាច់បាយដាច់ទឹកកូនចៅអស់ហើយ។ បន្តិចលឺថា គេទៅមើលដី វាស់វែងដី ដូច្នេះយើងជាម្ចាស់ដីត្រូវទៅមើលដែរ។ វល់ហូតតែនឹងរឿងដី គឺប្រមាណជិតមួយឆ្នាំហើយ។"* ម្ចាស់ដីម្នាក់ក្នុងចំណោម១១គ្រួសារ ខែឧសភា ឆ្នាំ២០១៣។

គ្រួសារខ្លះ ត្រូវបង្ខំចិត្ត ចងការប្រាក់របស់ឈ្មួញ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ ដើម្បីយកមកផ្គត់ផ្គង់ការហូបចុករាល់ថ្ងៃសិន។ គ្រួសារខ្លះទៀត ក្លាយខ្លួនជាកម្មករ[14]ធ្វើការងារដកដំឡូងមីឲ្យក្រុមហ៊ុននៅលើដីចំការរបស់ខ្លួនឯងដែលក្រុមហ៊ុនបានរំលោភយកដើម្បីដាំដំឡូងមី។

> *"ខ្ញុំនៅទីនេះ អត់មានការងារអ្វីធ្វើតាំងពីមានបញ្ហាដីដែលត្រូវក្រុមហ៊ុនរឹបអូសយក ដូច្នេះខ្ញុំក៏ស៊ីឈ្នួលបេះដំឡូងឲ្យចិនទៅ គ្រាន់បានអង្ករ និងលុយខ្លះៗចិញ្ចឹមកូននិងចៅ។ បើមិនធ្វើការងារឲ្យវា ចៅអត់មានអីហូប។ ខ្ញុំមានកូនច្រើន ចៅក៏ច្រើន ហើយបានដីតែបន្តិច ឥឡូវមិនគ្រប់ទំហំដីទៀត។ ពីមុនគឺយើងជាម្ចាស់ដី តែឥឡូវយើងទៅធ្វើខ្ញុំបំរើលើដីរបស់យើងទៀត បើយើងមិនធ្វើគឺយើងគ្មានការងារធ្វើ។ អ្នកខ្លះគេមិនធ្វើទេ ព្រោះគឺនៅភូមិគេមានដីស្រែសម្រាប់ធ្វើ។ ខ្ញុំគ្មានដីស្រែទេ គឺពឹងតែដីចំការព្រៃនេះ..."* ម្ចាស់ដីម្នាក់ក្នុងចំណោម១១គ្រួសារ, ខែឧសភា ឆ្នាំ២០១៣។

> *"ការចេញប័ណ្ណប្រើមិនបាននេះ គឺមានផលប៉ះពាល់ខ្លាំងដល់ប្រជាជនយើង ព្រោះយើងរស់នៅមិនសុខស្រួលក្នុងចិត្ត។ ប្រសិនបើខាងរដ្ឋាភិបាល នៅតែមិនគិតគូរដោះស្រាយបញ្ហានេះដល់ប្រជាជន គឺវាប៉ះពាល់ខ្លាំងដល់ទំនាក់ទំនងរវាងប្រជាពលរដ្ឋក្នុងមូលដ្ឋានខ្លួនឯង ព្រោះនឹងត្រូវឈ្លោះគ្នា មើលមុខគ្នាមិនត្រង់ដោយសារតែការវាស់ដីជាន់លើដីអ្នកផ្សេងទៀតដែលសុទ្ធតែមានប្លង់ដូចគ្នា។"* តំណាង១១គ្រួសារ, ខែឧសភា ឆ្នាំ២០១៣។

ប្រជាជនរងគ្រោះទាំង១១គ្រួសារ សំណូមពរឲ្យរដ្ឋាភិបាល គិតគូរដោះស្រាយបញ្ហាដែលពួកគាត់ជួបប្រទះ។ សំណូមពរតែម៉្យាងគត់របស់គាត់ គឺសុំផ្តល់ដីឲ្យប្រជាជនតាមទំហំដែលមានក្នុងប័ណ្ណកម្មសិទ្ធិស្របច្បាប់ ដើម្បីឲ្យគាត់អាចយកមកទៅប្រើប្រាស់ប្រកបរបរចិញ្ចឹមជីវិតបាន។ ធ្វើបែបនេះ នឹងបញ្ចប់នូវភាពងឿងឆ្ងល់លើប្រសិទ្ធិភាពនៃប័ណ្ណកម្មសិទ្ធិថ្មី ដែលចេញដោយក្រុមនិស្សិតស្ម័គ្រចិត្តសម្តេចតេជោ។

ប៉ុន្តែ មកដល់ពាក់កណ្តាលខែមិថុនា ឆ្នាំ២០១៣នេះ តាមការផ្តល់ព័ត៌មានរបស់ប្រជាជនដែលរស់នៅក្នុងភូមិជាមួយនឹងប្រជាជន១១គ្រួសារ មានការគំរាមកំហែងជាបន្តបន្ទាប់ពីសំណាក់អាជ្ញាធរ និងមន្ត្រីដែលពាក់ព័ន្ធមកលើពួកគាត់។ បន្ថែមពីលើនេះទៀត ការចាប់ខ្លួនសកម្មជនដីធ្លី និងសិទ្ធិមនុស្ស លោក **គុជ វេង** (សូមអានព័ត៌មានបន្ថែមក្នុងករណីសិក្សាខាងក្រោម) គឺជាការគំរាមកំហែងដ៏ខ្លាំងក្លា ដើម្បីរារាំងការតវ៉ារបស់

---

[14] ការសម្ភាសន៍កម្មករធ្វើការលើចំការដំឡូងរបស់ចិន ក្នុងមួយថ្ងៃគឺបានកម្រៃ ២០០០០រៀល និងអង្ករមួយគីឡូ។ ប្រាក់ខែ គឺបើកម្តងក្នុងមួយខែ។

ប្រជាជនរងគ្រោះទាំង១១គ្រួសារនោះ។ មុនការចាប់ខ្លួនសកម្មជនគុជ វេង មានសេចក្តីរាយការព័ត៌មានបន្តបន្ទាប់ចេញផ្សាយដោយវិទ្យុអាស៊ីសេរីដែលចោទសួរពីប្រសិទ្ធិភាពនៃប័ណ្ណកម្មសិទ្ធិដីធ្លីថ្មី៖ ***"ការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ហើយ តែមិនអាចធ្វើការប្រើប្រាស់ដីរបស់ខ្លួន បានធ្វើឲ្យប្រជាជនរងគ្រោះទាំងដប់គ្រួសារនេះមានការខកចិត្ត និងចាប់ផ្តើមអស់ជំនឿទៅលើប្រសិទ្ធិភាពរបស់ប័ណ្ណកម្មសិទ្ធិដីធ្លីដែលកំពុងតែដំណើរការនេះ។"*** (វិទ្យុអាស៊ីសេរី, ០៧ ខែឧសភា ឆ្នាំ២០១៣)។

មកដល់ខែមិថុនា ឆ្នាំ២០១៣ ក្នុងចំណោមប្រជាពលរដ្ឋទាំង១១គ្រួសារ មានប្រាំពីរគ្រួសារបានបញ្ឈប់ការទាមទារ និងរង់ចាំការដោះស្រាយតាមការសន្យាដោយសមាជិកគណៈបក្សប្រជាជនកម្ពុជា។ ចំណែកប្រជាពលរដ្ឋសល់ប៉ុន្មានគ្រួសារទៀតកំពុងតែអស់សង្ឃឹមថា នឹងមានវិធានការសមស្របពីសំណាក់មន្ត្រីរដ្ឋាភិបាលក្នុងការផ្តល់ដំណោះស្រាយ និងការពារដោយស្របច្បាប់នូវដីអាស្រ័យផលរបស់ពួកគាត់ដែលមានចែងនៅក្នុងប័ណ្ណកម្មសិទ្ធិថ្មី។

**ការចាប់ខ្លួនសកម្មជនសិទ្ធិមនុស្ស និងដីធ្លី និងធនធនធម្មជាតិ គុជ វេង**

លោកគុជ វេង សកម្មជនការពារសិទ្ធិមនុស្ស សិទ្ធិដីធ្លី និងធនជានធម្មជាតិ ត្រូវបានសមត្ថកិច្ចចាប់ខ្លួនកាលពីថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៣ នៅវេលាម៉ោង ៩:២០នាទីព្រឹក នៅចំណុចដំណាក់ព្រីង ក្នុងភូមិក្រឡាញ់ ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់។ គាត់ជាអ្នកគាំទ្រប្រជាពលរដ្ឋទាំង១០គ្រួសារដែលជាប្រធានបទក្នុងករណីសិក្សាទីមួយនៃរបាយការណ៍នេះ។

សាក្សីបានប្រាប់ថា អាជ្ញាធរមិនបានបង្ហាញដីកាតុលាទេមុនពេលចាប់ខ្លួនរបស់លោកគុជ វេង ហើយក៏គ្មានដីការពីតុលាក្នុងការឃុំខ្លួនគាត់ដែរ។ ពីដំបូងលោក គុជ វេង បដិសេធន៍មិនទៅតាមការនាំខ្លួន តែត្រូវសមត្ថកិច្ចម្នាក់ក្នុងចំណោមបួននាក់នោះប្រាប់ថា មានដីកាតុលាការនៅក្នុងឡាន៕

លោកគុជ វេង ត្រូវកាត់ទោសអោយជាប់ឃុំឃាំងមួយឆ្នាំ ដោយបីភាគបួននៃការឃុំខ្លួនត្រូវបានតុលាព្យួរក្រោមការចោទប្រកាន់ពីបទឆបោក៤៥០០ដុល្លាអាមេរិពីអ្នកភូមិម្នាក់កាលពីប៉ុន្មានឆ្នាំកន្លងទៅ។ ករណីចោទប្រកាន់នេះ ត្រូវបានគេយល់ឃើញថាជការសងសឹក ព្រោះលោកគុជ វេង ហ៊ានចេញតទល់នឹងមហាក្រុមហ៊ុនភាពីម៉ិច ដែលជាក្រុមរបស់លោកស្រីធឹង សូភាព ដែលជាភរិយារបស់សមាជិកព្រឹទ្ធសភា ឯកឧត្តម ឡៅ ម៉េងឃិន។

ការចាប់ខ្លួនរបស់លោកគុជ វេងកើតឡើងក្រោយពីការចេញផ្សាយអត្ថបទសារព័ត៌មានស្តីពីទំនាស់ដីធ្លីរបស់ប្រជាជន១០គ្រួសារជាមួយនឹងក្រុមហ៊ុនភាពីម៉ិច និងអាជ្ញាធរមូលដ្ឋាដោយកាសែតក្នុងស្រុកមួយ។

សាវនាការលើកទីមួយពាក់ព័ន្ធនិងករណីលោកគុជ វេង ត្រូវបានពន្យាដោយសារមានប្រជាពលរដ្ឋរាប់រយនាក់បានចេញមកធ្វើការទាមទារអោយអាជ្ញាធរដោះលែងលោកគុជ វេង។ មានប្រជាពរលរដ្ឋតែមួយចំនួនតូចប៉ុណ្ណោះបានចូលរួមស្តាប់សាវនាការចុងក្រោយដោយសាលាដំបូងខេត្តពោធិ៍សាត់បើតាមការរាយការណ៍របស់កាសែតក្នុងស្រុក ភ្នំពេញប៉ូស្ត ដោយសារតែប្រជាពលរដ្ឋខ្លាចក្រែងមានការពន្យាការដោះលែងលោកគុជ វេង ទៀត។

ពេលជិតដល់ការបោះឆ្នោត សមាជិកគណបក្សប្រជាជន លោក ទី រ៉ាវុឌ្ឍ បានបដិសេធថាករណីចាប់ខ្លួនលោកគុជ វេងមានការពាក់ព័ន្ធនឹងការងារជាសកម្មជន ហើយបានសន្យាថានឹងដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋទាំង១០គ្រួសារនោះ។

*(ករណីសិក្សាចងក្រងតាមរយៈការប្រមូលព័ត៌មានក្នុងខែមិនា ខែឧសភា និងខែមិថុនា ២០១៣)*

## ករណីសិក្សាទី២៖ ការដកហូតប័ណ្ណកម្មសិទ្ធិដីថ្មីរបស់ប្រជាជន

ប្រជាជនដែលរស់នៅក្នុងភូមិមួយចំនួន ដែលមានព្រំប្រទល់ជាប់នឹងតំបន់ព្រៃសហគមន៍ទំហំចាប់ពី ៣០០ ទៅ៥០០ហិកតា ក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ កំពុងតែមានបញ្ហា ដោយសារតែពួកគាត់មិនបាន ទទួលប័ណ្ណកម្មសិទ្ធិដីរបស់ខ្លួន ក្រោយពេលដែលក្រុមនិស្សិតស្ម័គ្រសម្តេចតេជោ ចុះវាស់វែងដីរួច។ ទិន្នន័យនៃ ចំនួន គ្រួសាររងគ្រោះ ដោយមិនបានទទួលប័ណ្ណកម្មសិទ្ធិសរុប គឺមិនទាន់អាចកំណត់បានជាក់លាក់ទេ។ ប៉ុន្តែ តាមរយៈការស្រង់ព័ត៌មានត្រួសៗ យ៉ាងហោចណាស់មានប្រជាជនចំនួនប៉ែតសិបប្រាំបី (៨៨)គ្រួសារ ដែល រស់នៅក្នុងភូមិក្រឡាញ់ ឃុំក្បាលត្រាច ភូមិត្រពាំងរំដេញ ឃុំក្បាលត្រាច និងភូមិខ្លាក្រពើ ឃុំអន្លង់ត្នោតដែល មិនទាន់បានទទួលប័ណ្ណកម្មសិទ្ធិដីរបស់ខ្លួននៅឡើយទេ ចាប់តាំងពីការវាស់វែងរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត កាលពីខែសីហា ឆ្នាំ២០១២។

**តារាងទី៤៖ ឈ្មោះភូមិ និងចំនួនគ្រួសាររងគ្រោះ**

| ភូមិ | ឃុំ | ចំនួនគ្រួសារ |
|---|---|---|
| ក្រឡាញ់ | ក្បាលត្រាច | ៤៦ |
| ត្រពាំងរំដេញ | ក្បាលត្រាច | ១៣ |
| ខ្លាក្រពើ | អន្លង់ត្នោត | ២៩[15] |
| **សរុប** | | **៨៨ គ្រួសារ** |

(ប្រភព៖ ព័ត៌មានស្រង់ពីប្រជាជនតាមរយៈការចុះជួបផ្ទាល់ នៅខែមិនា និងខែមិថុនា ២០១៣)

យោងតាមការផ្តល់ព័ត៌មានរបស់ប្រជាជនដែលរស់នៅភូមិក្រឡាញ់ ក៏ដូចជាប្រជាជនដែលរស់នៅក្នុង ភូមិខ្លាក្រពើ ដីស្រែរបស់គាត់ គឺត្រូវបានប្រជាជនម្ចាស់ដីទាំងនេះ កាន់កាប់តាំងពីអំឡុងឆ្នាំ១៩៩២-១៩៩៣ មកម្ល៉េះ។ (សូមបញ្ជាក់ថា៖ ក្រុមស្រាវជ្រាវមិនបានជួបផ្ទាល់ជាមួយនឹងអ្នកភូមិពីត្រពាំងរំដេញទេ។)

កាលពីឆ្នាំ២០១០ មានកិច្ចផ្តួចផ្តើមរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍មួយចំនួនដូចជាប្រជាជននៅ ក្នុងឃុំក្បាលត្រាចជាដើម ក្នុងការដាក់ពាក្យសុំបង្កើតព្រៃសហគមន៍។ ទោះយ៉ាងណាក៏ដោយ សំណើរបស់ប្រជា ពលរដ្ឋកន្លងមក មិនបានទទួលការឆ្លើយតបពីស្ថាប័នជំនាញនៅឡើយទេ។ កាលពីថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ ២០១១ ទីស្តីការគណៈរដ្ឋមន្ត្រី បានចេញសេចក្តីជូនដំណឹង(ស.ជ.ណ.) ផ្ញើជូនមកគ្រប់អង្គភាពដែលពាក់ព័ន្ធ នៅគ្រប់ជាន់ថ្នាក់ក្នុងខេត្តពោធិ៍សាត់ ដើម្បីឲ្យធ្វើការកាត់ដីព្រៃសម្បទានដីសេដ្ឋកិច្ចរបស់ ក្រុមហ៊ុនភាពីម៉ិច ទំហំប្រាំរយ(៥០០)ហិកតា ដើម្បីបង្កើតជាដីព្រៃសហគមន៍សម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ និងអាស្រ័យផល។ ផ្ទៃដីព្រៃសហគមន៍នេះ ស្ថិតនៅក្នុងស្រុកចំនួនពីរ គឺស្រុកក្រគរ និងស្រុកភ្នំក្រវាញ ក្នុងខេត្តពោធិ៍សាត់ និងមាន ព្រំប្រទល់ជាប់នឹងឃុំមួយចំនួនដូចជាឃុំអន្លង់ត្នោត ឃុំស្វាយស ឃុំអូរសណ្តាន់ ឃុំត្នោតជុំ ឃុំស្នាអន្សា ឃុំឈើ

[15] ប្រជាជនក្នុងភូមិខ្លាក្រពើអះអាងថា មានប្រជាជនច្រើនជាង៥០គ្រួសារដែលមិនបានទទួលប្លង់រឹង ពីការវាស់វែងរបស់ក្រុមនិស្សិត ស្ម័គ្រចិត្តកាលពីខែតុលា ឆ្នាំ២០១២កន្លងមកនេះ។

តុំ ឃុំអន្សារចំបក់ ក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់។ មានប្រជាពលរដ្ឋ ជាច្រើនពាន់គ្រួសារដែលរស់នៅពឹងអាស្រ័យលើដីព្រៃសហគមន៍នេះ។

នៅពេលដែលក្រុមនិស្សិតស្ម័គ្រចិត្តសម្តេចតេជោ ចុះមកធ្វើការវាស់វែងដី ក្នុងដំណាក់កាលទីមួយកាលពីពាក់កណ្តាលឆ្នាំ២០១២ នៅពេលដំបូង ក្រុមនិស្សិតបដិសេធមិនវាស់វែងដីស្រែរបស់ប្រជាពលរដ្ឋដែលដីទាំងនោះ មានទីតាំងនៅជាប់នឹងជាយព្រៃសហគមន៍កំណត់ដោយអាជ្ញាធរក្រោយការចេញស.ជ.ណ.នោះទេ។ ក៏ប៉ុន្តែប្រជាពលរដ្ឋដែលជាម្ចាស់ដីស្រែមិនយល់ព្រម ព្រោះដីនោះជាក្បាលដីស្រែដែលពួកគាត់បង្កបង្កើនផល ហើយពួកគាត់បានប្រើប្រាស់ដីនោះតាំងពីឆ្នាំ១៩៩២-១៩៩៣មកម្ល៉េះ។ ប្រជាជនមិនព្រមទទួលស្គាល់ដីនោះជាដីព្រៃសហគមន៍ទេ។ ដូច្នេះ ក្រុមនិស្សិតស្ម័គ្រចិត្ត ក៏បានយល់ព្រមវាស់ដីអាស្រ័យផលនោះដល់ប្រជាពលរដ្ឋ។ ក្រោយពីការវាស់វែង ក្រុមនិស្សិតស្ម័គ្រចិត្តបានផ្តល់ចុងសន្លឹកប័ណ្ណមកដល់ប្រជាជន និងរង់ចាំការទទួលបានប័ណ្ណកម្មសិទ្ធិពេញលេញ។

នៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១២ នៅពេលដែលប្រជាជនម្ចាស់ដីយកចុងសន្លឹកទៅប្តូរយកប័ណ្ណកម្មសិទ្ធិពេញលេញ មន្ត្រីអាជ្ញាធរ បានដកហូតយកចុងសន្លឹក និងមិនប្រគល់ប័ណ្ណកម្មសិទ្ធិដល់ប្រជាជនដោយសំអាងថា ក្រុមនិស្សិតស្ម័គ្រចិត្តវាស់ដីខុសបច្ចេកទេស និងចូលទៅក្នុងដីព្រៃសហគមន៍ (Kuch., ២០១៣)។ ភាពប្រទាំងប្រទើសនៃការដកហូតយកប័ណ្ណសិទ្ធិកម្មសិទ្ធិដីរបស់ប្រជាជនដែលមានដីស្ថិតនៅជាប់នឹងព្រំប្រទល់ក្នុងតំបន់ដីព្រៃសហគមន៍ក្រោយការចេញស.ជ.ណ.របស់ទីស្តីការគណៈរដ្ឋមន្ត្រីនេះ មិនទាន់មានដំណោះស្រាយណាមួយពីសំណាក់អាជ្ញាធរមូលដ្ឋាន ឬខេត្តទេ។

កាលពីថ្ងៃទី៨ ខែមិនា ឆ្នាំ២០១៣ ប្រជាជនចំនួន១០គ្រួសារ ដែលតំណាងឲ្យប្រជាជន៤៦គ្រួសារក្នុងឃុំក្បាលត្រាច បានដាក់ពាក្យបណ្តឹងទៅខុទ្ទកាល័យនាយករដ្ឋមន្ត្រី ហ៊ុន សែន និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីទាមទារយកប័ណ្ណកម្មសិទ្ធិដីស្របច្បាប់របស់ខ្លួន (May, ២០១៣)។ រហូតមកទល់នឹងខែមិថុនា ឆ្នាំ២០១៣ មិនទាន់មានដំណោះស្រាយជាក់លាក់ណាមួយដល់ប្រជាជនរងគ្រោះនៅឡើយទេ។

តាមការចែករំលែកព័ត៌មានរបស់ប្រជាជនម្ចាស់ដីដែលរងគ្រោះដែលធ្លាប់បានទូរស័ព្ទទៅសាកសួរប្រធានក្រុមនិស្សិតស្ម័គ្រចិត្តដែលបានចុះមកវាស់វែងដីរបស់គាត់ ប្រធានក្រុមនិស្សិតរូបនេះបានជម្រាបគាត់វិញថា ខាងក្រសួងបានចេញប័ណ្ណកម្មសិទ្ធិដល់ប្រជាជនរួចហើយ និងបានផ្តល់មកដល់អាជ្ញាធររួចហើយ។ ប្រជាជនដែលរស់នៅក្នុងភូមិក្រឡាញ់ ក្នុងឃុំក្បាលត្រាច បានឲ្យដឹងថា *"អាជ្ញាធរមូលដ្ឋាន បានដកហូតយកសាលាកប័ត្រពីពួកគាត់ កាលពីខែធ្នូ ឆ្នាំ២០១២ ដោយលើកឡើងថា ដីរបស់ប្រជាជនទាំងនេះមានជាប់ពាក់ព័ន្ធជាមួយនឹងដីព្រៃសហគមន៍។"* (ខែមិនា ឆ្នាំ២០១៣)។ បច្ចុប្បន្ននេះ ប្រជាពលរដ្ឋរងគ្រោះ កំពុងតែធ្វើការតវ៉ាទាមទារយកប័ណ្ណកម្មសិទ្ធិស្របច្បាប់របស់ខ្លួន។

> ***"នៅក្នុងកិច្ចពិគ្រោះយោបល់កាលពីថ្ងៃទី១៤ ខែមិថុនា ២០១៣ ខ្ញុំបានលើកសំណួរសួរទៅអភិបាលស្រុក(ក្រគរ) ពីបញ្ហាព្រៃសហគមន៍ នៅឃុំអន្លង់ត្នោត ដែលក្រុមនិស្សិតស្ម័គ្រចិត្ត បានចុះមកវាស់វែងកាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២។ តើមូលហេតុអ្វីបានជាវាស់ដីឲ្យប្រជាជនហើយ មិនចេញប័ណ្ណកម្មសិទ្ធិឲ្យដល់ប្រជាជន ហើយបែរជាលើកឡើងថា ជាដីព្រៃសហគមន៍។ អភិបាលស្រុក បានសន្យាថានឹងបញ្ជូនអភិបាលស្រុករង ឲ្យទៅត្រួតពិនិត្យ ប្រសិនបើត្រឹមត្រូវ និងឲ្យក្រុមនិស្សិតស្ម័គ្រចិត្ត[16] ចុះវាស់***

[16] ក្រុមនិស្សិតស្ម័គ្រចិត្ត កំពុងតែធ្វើការវាស់វែងដី នៅឃុំស្វាយស ក្នុងស្រុកក្រគរ ក្នុងខែមិថុនា ឆ្នាំ២០១៣។

***វែងដីម្តងទៀត។ ចំណែក លោកទឹម សារិន អភិបាលស្រុកក្រគរ បានប្រាប់ដល់ប្រជាជននៅក្នុងវេទិកាពិគ្រោះយោបល់នេះថា៖ "បានប្លង់ ឬមិនបាន មិនចាំបាច់ខ្វល់ទេ។ សូមឲ្យប្រជាជនគិតតែពីធ្វើស្រែនៅលើដីនោះទៅ។"*** ប្រជាជនក្នុងភូមិខ្លាក្រពើ, ១៩ ខែមិថុនា ឆ្នាំ២០១៣។

ការផ្តល់ព័ត៌មានរបស់ប្រជាជនដែលរស់នៅភូមិខ្លាក្រពើ ដែលអាស្រ័យផលពីដីព្រៃសហគមន៍នេះ បានឲ្យដឹងថា៖ ***"អង្គការស្តារកម្ពុជា កំពុងតែជួយសម្របសម្រួលនៅក្នុងគម្រោងរៀបចំសហគមន៍ព្រៃឈើ[17] និងកំពុងស្វែងរកការគាំទ្រពីប្រជាពលរដ្ឋ ឲ្យចូលរួមជាសមាជិក។ រហូតមកទល់នឹងពេលនេះ មានប្រជាជនប្រមាណម្ភៃនាក់ហើយ នៅក្នុងឃុំខ្ញុំដែលបានផ្តិតមេដៃ ហើយការផ្តិតមេដៃគាំទ្រ គឺត្រូវប្រមូលឲ្យបានយ៉ាងហោចណាស់ ៦០%នៃប្រជាជនដែលអាស្រ័យផលពីដីព្រៃនេះ ទើបអាចដំណើរការរៀបចំសហគមន៍ព្រៃឈើបាន--ខ្ញុំក៏បានផ្តិតមេដៃគាំទ្រដែរ ដោយសារតែខ្ញុំចង់ឲ្យមានដីព្រៃសហគមន៍។ ប៉ុន្តែខ្ញុំយល់ថា ការបង្កើតព្រៃសហគមន៍ គួរតែសំដៅលើដីព្រៃណា ដែលគ្មានទំនាស់។"*** (ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣)។

យើងសង្កេតឃើញថា ទំនាស់ដែលបានកើតឡើងនៅក្នុងអំឡុងពេល ឬក្រោយពេលដែលក្រុមនិស្សិតស្មគ្រចិត្តចុះទៅធ្វើការវាស់វែងដីធ្លី គឺភាគច្រើនណាស់ដែលមិនត្រូវបានដោះស្រាយទេ។ ទោះបីជាគណៈកម្មការជាតិដោះស្រាយទំនាស់ដីធ្លីត្រូវបានបង្កើតឡើងដើម្បីទទួលខុសត្រូវលើបញ្ហានេះក្តី ប្រសិទ្ធិភាពនៃគណៈកម្មការក្នុងការការឆ្លើយតបទៅនឹងទំនាស់ដីធ្លីដែលប្រជាជនជួបប្រទះ មិនថាករណីរបស់ប្រជាជន១១គ្រួសារក្នុងចំណុចដំណាក់ព្រីង ឬប្រជាជន៤៦គ្រួសារក្នុងឃុំក្បាលត្រាច ឬប្រជាជននៅក្នុងស្រុកផ្សេងទៀត ឬឃុំផ្សេងទៀតក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ ហាក់មិនត្រូវបានអាជ្ញាធរថ្នាក់ជាតិនេះអើពើដោះស្រាយឡើយ។ យុទ្ធនាការចុះវាស់វែងដីធ្លីរបស់សម្តេចតេជោ នាយករដ្ឋមន្ត្រីដែលមានគោលបំណងដើមដំបូងក្នុងការដោះស្រាយវិវាទដីធ្លីនៅតាមតំបន់ដែលមានសម្បទានដីសេដ្ឋកិច្ច ហាក់ដូចជាបង្កើនកំណើនករណីវិវាទដីធ្លីថែមទៀតដោយសារតែប្រជាជននៅក្នុងសហគមន៍មួយចំនួនមិនបានទទួលប័ណ្ណកម្មសិទ្ធិតាមរយៈការវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្តឡើយ។

[17] សកម្មភាពសំខាន់ៗ នៃគម្រោងរបស់អង្គការស្តារកម្ពុជា គឺសកម្មភាពរៀបចំព្រៃសហគមន៍ និងផ្តល់វគ្គបណ្តុះបណ្តាលចំណេះដឹងដល់ប្រជាជនដែលជាសមាជិកសហគមន៍ព្រៃឈើ។

## ករណីសិក្សាទី៣៖ ទំនាស់ព្រំប្រទល់ដីនៅភូមិរំចេក ខេត្តឧត្តរមានជ័យ

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣ និស្សិតក្រុមទី១០៨ បានចុះទៅធ្វើការវាស់វែងដីធ្លីនៅក្នុងភូមិរំចេក ក្នុងខេត្តឧត្តរមានជ័យ។ យោងតាមប្រធានភូមិរំចេក ការវាស់វែងរបស់ក្រុមនិស្សិតស្ម័គ្រចិត្តសម្រេចបានក្បាលដីសរុបចំនួន ១,០៤៨ក្បាលដី លើផ្ទៃដីសរុប ២,៦២៧ហិកតា។ មានក្បាលដីប្រមាណជាង៥០០ក្បាលដីទៀត ដែលនៅមិនទាន់បានធ្វើការវាស់វែង។ មេភូមិរំចេក រំលឹកថា មូលហេតុនៃការមិនទាន់វាស់ក្បាលដីគ្រប់ចំនួន គឺដោយសារការវាស់វែងដំណាក់កាលទីមួយ (កាលពីខែមករា ឆ្នាំ២០១៣) ទើបនឹងបិទប្រកាសសាលាកប័ត្រកាលពីថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៣ កន្លងមកនេះ ហើយប្រជាជនកំពុងតែរង់ចាំទទួលប័ណ្ណកម្មសិទ្ធិពេញលេញ។

អ្នកមានអំណាចមួយចំនួនដែលមានព្រំប្រទល់ដីជាប់នឹងដីរបស់ប្រជាពលរដ្ឋ ឆ្លៀតយកឱកាសដែលក្រុមនិស្សិតស្ម័គ្រចិត្តចុះមកធ្វើការវាស់វែងដីធ្លី គាបសង្កត់យកដីរបស់ប្រជាជនបន្ថែមដោយគំរាមប្រជាជនថា ប្រសិនបើប្រជាជនមិនព្រមផ្តិតមេដៃប្រគល់ដីខ្លះឲ្យគេទេ គេក៏នឹងមិនផ្តិតមេដៃធ្វើជាសាក្សីឲ្យវិញដែរ។ កត្តានេះ បានធ្វើឲ្យប្រជាជនតូចតាចគ្មានជម្រើស ម្លោះហើយត្រូវយល់ព្រមតាមការគំរាមទាមទារនេះ។

ប្រជាជនមួយចំនួនដែលបានទទួលការវាស់វែងដីធ្លីដោយក្រុមនិស្សិតរួចហើយ ពេញចិត្តនឹងសកម្មភាពនេះ ពីព្រោះក្រុមនិស្សិតបានវាស់វែងតាមចំនួនដីដែលពួកគាត់មាន ហើយប្រជាជនយល់ព្រម។ ចំណែកឯដីមានជម្លោះរវាងប្រជាជន និងប្រជាជននៅភូមិរំចេក និងភូមិស្រឡៅស្រោង (ក្នុងឃុំលំទង់) គឺក្រុមនិស្សិតមិនធ្វើការវាស់វែងទេ។

បើយោងតាមមេភូមិរំចេក៖ ដីទំនាស់នៅភូមិរំចេក ជាដីរបស់ភូមិស្រឡៅស្រោង ហើយគាត់បានធ្វើការដោះស្រាយម្តងរួចហើយនៅនឹងកន្លែងដី តែប្រជាជនមិនយល់ព្រម។ ការដោះស្រាយនៅលើកទីពីរ គឺប្រើវិធីបូកសរុបចំនួនគ្រួសារដែលមានបញ្ហា (១០០គ្រួសារនៅភូមិរំចេក និង៣៦គ្រួសារនៅភូមិស្រឡៅស្រោង) និងបែងចែកចំនួនផ្ទៃដីនេះ (២០០ហិកតា)ក្នុងទំហំស្មើៗគ្នា។ ដូច្នេះ គ្រួសារនីមួយៗ និងបានទទួលដីទំហំ ១.៤៥ ហិកតា។ ប្រជាជនភាគច្រើនយល់ព្រម តែមានគ្រួសារមួយចំនួនទៀតក្នុងចំណោមនោះ មិនយល់ព្រម ដោយសារតែពួកគាត់មានដីតែមួយកន្លែងជាដីផ្ទះ និងដីស្រែ(ដីតំបន់ជម្លោះ) ហើយពួកគាត់ជាអ្នកកាប់ឆ្ការព្រៃនោះពីដំបូងមក។ បើបែងចែកស្មើៗគ្នា គឺគាត់ទទួលបានទំហំតូច។ ចំណែគ្រួសារដែលយល់ព្រមភាគច្រើនគឺមានដីច្រើនជាងមួយកន្លែង។ យន្តការនៃការដោះស្រាយវិវាទដីធ្លីរបស់មេភូមិរំចេកមិនបានសម្រេចទេ ហើយជាចុងក្រោយ លោកមានប្រសាសន៍ថា បើសិនជាប្រជាជនមិនចុះសម្រុងគ្នា ទទួលតាមការដោះស្រាយរបស់គាត់ គាត់នឹងត្រូវដកហូតដីទាំងអស់នោះទុកជាសម្បត្តិសហគមន៍។

ប្រជាពលរដ្ឋមួយចំនួនទៀតលើកឡើងថា ការវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត គឺមានការរើសអើងលើប្រជាជនមួយចំនួន។ *"បើប្រជាពលរដ្ឋទៅអញ្ជើញក្រុមនិស្សិតឲ្យមកធ្វើការវាស់វែងដីរបស់ពួកខ្ញុំ គឺមិនសូវហ៊ីសហ្វេនទេ ស្ទើរចង់ទៅ ស្ទើរមិនចង់ទៅ។ តែបើអ្នកមានលុយវិញ គ្រាន់តែចេញផុតពីឡាន មកសុំឲ្យក្រុមនិស្សិតទៅវាស់ពួកគេក៏ទៅវាស់ភ្លាម។ ឯចំណែកប្រជាពលរដ្ឋវិញ "**អង្គុយចាំមួយព្រឹកហើយ អត់វាស់ឲ្យ**"។*

ទោះជាស្ថិតក្នុងស្ថានភាព ដែលការវាស់វែងដំណាក់កាលទីមួយមិនទាន់បានសម្រេចចប់សព្វគ្រប់ទាំងស្រុងនៅឡើយក៏ដោយ តាមប្រសាសន៍របស់ប្រធានភូមិរំចេក ការវាស់វែងដំណាក់កាលទីពីរក្នុងភូមិនេះ នឹងប្រព្រឹត្តិទៅនៅក្នុងខែមិថុនា (មុនការបោះឆ្នោតជាតិខែកក្កដា ឆ្នាំ២០១៣)។

*(ផ្តល់ព័ត៌មានដោយប្រជាជននៅក្នុងភូមិរំចេក ខេត្តឧត្តរមានជ័យ ខែឧសភា ឆ្នាំ២០១៣)*

## ករណីសិក្សាទី៤៖ ចំណាកស្រុកខ្ពស់ រារាំងគ្រួសារជាច្រើនពីការវាស់វែងដីធ្លី

ភូមិស្រឡៅស្រោងជាភូមិមួយស្ថិតក្នុងឃុំលំទង់ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ភូមិនេះមានប្រជាជនសរុបចំនួន៥៩គ្រួសារ។ ក្នុងបេសកម្មចុះបំពេញការងារវាស់វែងដីធ្លីដល់ប្រជាជនរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត និងមន្ត្រីជំនាញសុរិយោដីស្រុក ក្នុងដំណាក់កាលទីមួយនៃការអនុវត្តបេសកម្មចុះវាស់វែងដីធ្លី នាពាក់កណ្តាលឆ្នាំ២០១២ សម្រេចបានការវាស់ដីត្រឹម១០គ្រួសារប៉ុណ្ណោះ។ គ្រួសារមួយចំនួនធំដែលមិនបានទទួលការវាស់វែងដីធ្លីដោយសារមូលហេតុចំបងៗដូចជា៖

- ខ្វះសាក្សីព្រំប្រទល់ដី
- អត្រាចំណាកស្រុកនៅក្នុងភូមិនេះមានកម្រិតខ្ពស់ ដែលជាហេតុធ្វើឲ្យគ្រួសារដែលមានប្តី-ប្រពន្ធ តែងមានការខ្វះស្នាមមេដៃបញ្ជាក់ពីអេតាស៊ីវិលរបស់ពួកគាត់។ មានគ្រួសារមួយចំនួនតូចដែលមានស្ត្រីជាមេគ្រួសារបានរាយការណ៍ថា ប្តីគាត់បានចាក់ចេញពីគាត់ ឬខ្លះថាប្តីស្លាប់។ (មួយថ្ងៃពីរក្រោយមក ប្តីខ្លះបានត្រឡប់មករកគ្រួសារវិញ។ នេះវាបញ្ជាក់សេចក្តីថា ការរាយការណ៍ថាប្តីចាក់ចេញពីគាត់ ឬប្តីស្លាប់នោះវាជារឿងមិនពិត។)
- ដីដែលមានទំនាស់រវាងម្ចាស់ដី ហើយការសម្របសម្រួលមិនត្រូវគ្នា
- ដីមួយចំនួនរបស់ប្រជាជនស្ថិតនៅក្រៅតំបន់ទទួលខុសត្រូវវាស់វែងដោយក្រុមនិស្សិតដែលចុះមកធ្វើវាស់វែងក្នុងជំហាននេះ។

ទោះបីជាការវាស់វែងបានប្រព្រឹត្តិទៅអស់រយៈពេលជាងដប់ខែហើយក៏ដោយ រហូតមកទល់នឹងចុងខែឧសភា ឆ្នាំ២០១៣ នៅមិនទាន់មានការបិទប្រកាសសាលាកប័ត្របឋមនៃការវាស់វែងវគ្គទី១ផង។ អាជ្ញាធរភូមិក៏មិនដឹងច្បាស់ថា ពេលណានឹងមានការបិទប្រកាសកើតឡើង ដោយសារតែជិតដល់ពេលបោះឆ្នោត ហើយអាជ្ញាធរថ្នាក់មូលដ្ឋានរវល់មមាញឹកក្នុងការរៀបចំការឃោសនារកសន្លឹកឆ្នោត។

ប្រជាជនភាគច្រើននៅក្នុងភូមិមិនពេញចិត្តនឹងការចុះវាស់វែងដីធ្លីនេះទេ។ ពួកគាត់បានយល់ថា ដំណើរការវាស់វែងដីនេះមានភាពតឹងតែង និងត្រូវការលិខិតបទដ្ឋានច្រើន (សាក្សីផ្តិតមេដៃ លិខិតបញ្ជាក់ភាពនៅលីវ ឬលែងលះ) ដែលនេះជាផ្នែកមួយនៃមូលហេតុធ្វើឲ្យគ្រួសារជាច្រើន មិនបានទទួលការវាស់វែងដីធ្លី។ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៣ មេឃុំ (លំទង់) បានប្រកាសដល់ប្រជាពលរដ្ឋ១០គ្រួសារដែលបានវាស់វែងដីរួចហើយថា អាជ្ញាធរនឹងដកយកដី៥០% ពីគ្រួសារដែលបានទទួលដីវាស់ចាប់ពីប្រាំហិកតាឡើងទៅ។ ចំពោះអ្នកដែលមានដីក្រោម៥ហិកតាមិនមានការដកហូតទេ។

ប្រជាជនក្នុងមូលដ្ឋានសង្ឃឹមថា នឹងមានការបិទប្រកាសព័ត៌មាននៃដីប្រជាជន១០គ្រួសារដែលបានទទួលការវាស់វែងរួចហើយនោះ និងសំណូមពរឲ្យមដំណាក់កាលបន្តបន្ទាប់នៃការចុះវាស់វែងដីធ្លីដែលនៅសល់ប្រព្រឹត្តិទៅអោយបានឆាប់រហ័ស។

*(ព័ត៌មានប្រមូលពីមូលដ្ឋាន ក្នុងខែឧសភា ឆ្នាំ២០១៣)*

## ករណីសិក្សាទី៥៖ សិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីមិនបានពេញលេញក្រោយពីទទួលបណ្ណ័កម្មសិទ្ធិ

នៅក្នុងឱកាសនៃការចុះចែកបណ្ណ័កម្មសិទ្ធិដីធ្លី ជូនដល់ប្រជាពលរដ្ឋ ក្នុងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣ អភិបាលខេត្តកំពង់ឆ្នាំង ក្នុងឱកាសចែកបណ្ណ័កម្មសិទ្ធិដីធ្លី បានប្រកាសឲ្យប្រជាពលរដ្ឋដឹងថា កម្មវិធីវាស់វែងដីធ្លីរបស់ក្រុមនិស្សិតសម្រេចបានការវាស់វែងផ្ទៃដី និងចេញបណ្ណ័កម្មសិទ្ធិចំនួន២,៨១៥បណ្ណ័ ស្មើនឹងចំនួន១,៨០០គ្រួសារ។ ដោយឡែកភូមិអញ្ចាញ ក្នុងឃុំក្រាំងស្គារ ស្រុកបរិបូណ៌ វាស់បាន២,៨២០ក្បាលដី ស្មើនឹងចំនួន៦១០គ្រួសារ និងភូមិអូរល្ពៅ ឃុំក្រាំងស្គារ វាស់បាន១,២៤០ក្បាលដី ស្មើនឹង៥៥៦គ្រួសារ។ ផ្ទៃដីមួយចំនួនទៀតដែលមិនទាន់បានធ្វើការវាស់វែង គឺបណ្ដាលមកពីប្រជាជនមានទំនាស់ព្រំប្រទល់ដី ដីត្រួតគ្នា ដីភ្នំ ដីត្រពាំង អូរ ស្ទឹង សាលាបុណ្យ សាលាឃុំ ផ្លូវរថភ្លើង ជាដើម។

សកម្មភាពចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិតបានចាប់ផ្ដើមលើកទីមួយនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២។ ក្នុងខេត្តកំពង់ឆ្នាំង មាននិស្សិតស្ម័គ្រចិត្តចំនួនសរុបប្រាំបួនក្រុមដែលក្នុងនោះ មួយក្រុមបានចុះមកធ្វើការវាស់វែងនៅក្នុងឃុំក្រាំងស្គារ (ក្រុមទី៨៥)។ នៅក្នុងបេសកម្មរបស់ខ្លួន និស្សិតមានតួនាទីត្រឹមតែធ្វើការវាស់វែង ចេញបង្កាន់ដៃ និងចេញសាលាកបត្រដល់ប្រជាជន។ ប្រសិនបើប្រជាជនមានបញ្ហាដោយសារទទួលព័ត៌មានខុស ឬបញ្ហាផ្សេងៗទៀត គឺអាចស្វែងរកជំនួយពីក្រុមនិស្សិត នឹងមន្ត្រីសុរិយោដីបាន ក្នុងរយៈពេល៣០ថ្ងៃ រួមទាំងថ្ងៃឈប់សំរាក ក្រោយពីការបិទប្រកាសព័ត៌មាន។

បើតាមការផ្ដល់ព័ត៌មានរបស់ប្រជាជន ការវាស់វែងរបស់ក្រុមនិស្សិត គឺមិនបានកំណត់ទំហំផ្ទៃដី (ចំនួនហិកតា) នោះទេ គឺក្នុងមួយគ្រួសារអាចទទួលបានដីពីទៅប្រាំហិកតា ឬហូតដល់៣០ហិកតាក៏មាន ដូចជាករណីក្នុងឃុំក្រាំងស្គារ ស្រុកទឹកផុស ជាដើម។ ប៉ុន្តែប្រសិនបើប្រជាជនមានដីរហូតដល់៥០ហិកតា ក្រុមនិស្សិតតម្រូវឲ្យធ្វើការបែងចែក ដោយត្រូវយកកូនដែលគ្រប់អាយុមកចុះឈ្មោះនឹងបែកចែកដីចេញជាប្លង់ៗ។ ក្នុងដីមួយប្លង់ៗ មានទំហំច្រើនបំផុតត្រឹមដប់ហិកតា។

ប្រជាជននៅក្នុងឃុំក្រាំងស្គារបានប្រាប់ថា នៅក្នុងការវាស់វែងរបស់ក្រុមនិស្សិត គឺគ្មានការប្រកាន់ទេ ដីព្រៃក៏វាស់ឲ្យដែរ ឲ្យតែដីដែលពាក់ព័ន្ធនឹងក្រុមហ៊ុនភាពីម៉ិច គឺវាស់ឲ្យប្រជាជនទាំងអស់។ កន្លងមកការវាស់វែង គឺសម្រេចបានប្រមាណត្រឹមពីរម៉ឺន (២០,០០០) ហិកតា ដែលគ្របដណ្ដប់លើទឹកដីស្រុកបរិបូណ៌ និងស្រុកសាមគ្គីមានជ័យ។ នេះជាទំហំដីដែលកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនភាពីម៉ិច។

ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋដែលទទួលបានបណ្ណ័កម្មសិទ្ធិដីធ្លីរបស់ខ្លួន ត្រូវបានអាជ្ញាធរឃុំ-ស្រុក និងមន្ត្រីប៉ូលីសឃុំក្រាំងស្គារ ហាមប្រាមពួកគាត់ មិនឲ្យប្រើប្រាស់គ្រឿងចក្រ ដើម្បីការកាប់ឆ្ការដីព្រៃរបស់ពួកគាត់ដែលបានទទួលការវាស់វែង និងបានទទួលបណ្ណ័កម្មសិទ្ធិហើយនោះទេ ក្នុងអំឡុងខែមិថុនា និងខែកក្កដា (ឆ្នាំ២០១៣) និងត្រូវរង់ចាំរហូតដល់ការបោះឆ្នោតជាតិរួចទើបអាចធ្វើការងារនៅលើដីនោះបាន។ ប៉ុន្តែបើកាប់ឆ្ការដោយឧបករណ៍ប្រើដោយដៃ អាចធ្វើបាន។ ប្រជាពលរដ្ឋដែលជាម្ចាស់ដី មានការងឿងឆ្ងល់ជាខ្លាំងថា ប្រសិនបើបែងចែកដី និងផ្ដល់កម្មសិទ្ធិស្របច្បាប់ដល់ពួកគាត់ហើយ ហេតុអ្វីក៏មិនផ្ដល់សិទ្ធិក្នុងការប្រើប្រាស់ដីដល់គាត់ ហើយបែរជាឲ្យពួកគាត់រង់ចាំទៅវិញ? ឬមួយក៏ត្រូវរង់ចាំលទ្ធផលនៃការបោះឆ្នោត នឹងសម្រេចលើសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះ?

*(ផ្ដល់ព័ត៌មានដោយប្រជាជនក្នុងភូមិអញ្ចាញរូង ខេត្តកំពង់ឆ្នាំង ខែឧសភា ឆ្នាំ២០១៣)*

## ករណីសិក្សាទី៦៖ ក្តីបារម្ភរបស់ប្រជាពលរដ្ឋពីសុពលភាពនៃប័ណ្ណកម្មសិទ្ធិដី

ភូមិទំនុបតាគួន ស្ថិតក្នុងឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង។ ភូមិនេះមានប្រជាជនរស់នៅសរុបទាំងអស់ចំនួន២៥៧គ្រួសារ។ ភូមិទំនប់តាគួនមានទីតាំងភូមិសាស្រ្តពិសេស ដោយស្ថិតនៅលើចំណុចព្រំប្រទល់រវាងស្រុកបី គឺស្រុកបវេល ស្រុកបាណន់ និងស្រុករតនៈមណ្ឌលក្នុងខេត្តបាត់ដំបង។ ការគ្រប់គ្រងរដ្ឋបាលរបស់ភូមិទំនុបតាគួន គឺស្ថិតក្នុងស្រុកបវេល។ បេសកកម្មចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្តសម្តេចតេជោ បានចុះវាស់វែងដីនៅក្នុងស្រុកបាណន់កាលពីខែតុលា ឆ្នាំ២០១២ ដោយមាននិស្សិតស្ម័គ្រចិត្តបីក្រុម។ ដោយសារទីតាំងភូមិទំនុបតាគួនមានលក្ខណៈពិសេស ក្រុមនិស្សិតបានវាស់វែងដីលំនៅស្ថានមួយភាគធំក្នុងភូមិ ដើម្បីបញ្ចប់ផែនការតាមទីតាំងខ្សែស្រប ។

តាមការផ្តល់ព័ត៌មានរបស់ប្រជាជនក្នុងភូមិ ក្រុមនិស្សិតស្ម័គ្រចិត្ត និងមន្រ្តីជំនាញសុរិយោដី បានធ្វើការវាស់វែងដីលំនៅស្ថាន និងដីស្រែក្រោយផ្ទះរបស់ប្រជាជនមួយចំនួន និងផ្តល់បណ្ណ័កម្មសិទ្ធិដល់ប្រជាពលរដ្ឋបានចំនួន២១០ គ្រួសារ។ នៅសល់៦៣គ្រួសារទៀតមិនទាន់បានទទួលការវាស់វែង(ដីលំនៅស្ថាន និងដីស្រែ)។

មូលហេតុសំខាន់ពីរនៃការខកខានមិនទាន់បានវាស់វែងដីចប់សព្វគ្រប់គឺដោយសារ៖

១) ដំលោះព្រំ(ដីស្រែ)ដែល ដោះស្រាយមិនទាន់ដាច់ស្រេចនៅឡើយ

២) ផែនការក្រុមនិស្សិតស្ម័គ្រចិត្តគឺចុះមកវាស់វែងដីនៅក្នុងស្រុកបាណន់។ចំណែក ស្រុកបវេលគឺមិនទាន់ចុះអនុវត្តក្នុងជំហ៊ាននេះទេ។ មួយវិញទៀត ដីលំនៅស្ថានរបស់ប្រជាជន៦៣គ្រួសារ ដែលនៅសល់ស្ថិតនៅខាងជើងផ្លូវ គឺផុតទីតាំងខ្សែស្របស្រុកបាណន់ដែលត្រូវវាស់វែង ដូច្នេះត្រូវរង់ចាំវាស់ដីជាមួយស្រុកបវេល។

ទាក់ទងនឹងសកម្មភាពចូលរួមរបស់ប្រជាពលរដ្ឋក្នុងភូមិទំនុបតាគួនក្នុងការចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិត ប្រជាជនមានការពេញចិត្ត និងរីករាយក្នុងការទទួលបានប្លង់រឹងបានគ្រប់ៗគ្នា ជាពិសេសចំពោះការវាស់ដីលំនៅស្ថាន។ ការផ្តល់ប្លង់កម្មសិទ្ធិដីធ្លីស្របច្បាប់(ប្លង់រឹង)នេះ បង្កើនការជឿជាក់របស់ប្រជាពលរដ្ឋ ដោយពួកគាត់មិនសូវខ្លាចបាត់បង់ដីដូចកាលពីមុនទៀតទេ។ ប្រជាជនមួយចំនួនបន្ថែមថា ពួកគាត់អាចយកប្លង់ដីនេះទៅដាក់បញ្ចាំ(នៅធនាគារ)យកលុយមកធ្វើដើមទុនរកស៊ីបានទៀតផង។ ប៉ុន្តែ *"ប្រជាពលរដ្ឋមានក្តីបារម្ភ ខ្លាចទៅថ្ងៃក្រោយទៅ ផុតពីអណត្តិរបស់សម្តេចហ៊ុន សែន មានការកែប្រែស្ថានភាព ប្លង់នេះអស់ប្រសិទ្ធិភាពលែងប្រើការវាបាន"*។

ការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋតាមរយៈការចុះវាស់វែងដីធ្លី របស់ក្រុមនិស្សិតស្ម័គ្រចិត្ត និងមន្រ្តីជំនាញ ធ្វើឲ្យប្រជាពលរដ្ឋនៅក្នុងភូមិទំនប់តាគួនមានភាពកក់ក្តៅ និងជឿជាក់ថា ពេលក្រោយគ្មានអ្នកណាហ៊ានមកយកដីរបស់គាត់ទៀត។ ប្រជាពលរដ្ឋមួយចំនួនធំ លែងព្រួយបារម្ភពីរឿងបាត់បង់ដីលំនៅស្ថានទៀតហើយ។ កន្លងមក នៅភូមិទំនុបតាគួនមានបញ្ហាដីធ្លី(ដីស្រែ)ជាមួយភូមិផ្សេងយ៉ាងក្តៅគគុក។ អាជ្ញាធរដោះស្រាយមិនចេញរហូតមកដល់ពេលនេះ នៅតែមិនទាន់ដោះស្រាយរួច។ ប្រជាជន ១៨១គ្រួសារ នៅក្នុងភូមិនេះ រងផលប៉ះពាល់ដោយសារវិវាទដីស្រែនោះ នឹងគ្មានសង្ឃឹមថានឹងបានដីស្រែសម្រាប់ប្រើប្រាស់ទេ។ តែតាមរយៈក្រុមនិស្សិត និងមន្រ្តីសុរិយោដីវាស់វែងដីដែលបានចេញប្លង់រឹងសំរាប់ដីលំនៅស្ថាន និងដីស្រែរបស់ប្រជាជនមួយចំនួន ធ្វើឲ្យពួកគាត់បានកាន់កាប់ស្របច្បាប់ ហើយលែងមានជំលោះពីដីធ្លីទៀត។

ប្រជាជនបានចូលរួមនៅក្នុងការប្រជុំផ្សព្វផ្សាយ និងការបិទប្រកាសផ្សព្វផ្សាយព័ត៌មានក្នុងមូលដ្ឋាន ធ្វើឡើងដោយអាជ្ញាធរ ដើម្បីអោយគាត់បានយល់ដឹងអំពីដំណើរការវាស់វែងដី។ ដំណើរការនេះ ធ្វើឲ្យប្រជាជនមានអារម្មណ៍ថា មានការគោរព ផ្តល់សិទ្ធិអំណាច ពីសំណាក់ក្រុមការងារ។

(ព័ត៌មានប្រមូលនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣)

# ការពិភាក្សា ប័ណ្ណកម្មសិទ្ធិដីធ្លីថ្មី នៃបទបញ្ជា០១(បប)៖ ការអនុវត្តជាក់ស្តែង

## ៤.១ ទំហំដីក្នុងប័ណ្ណនិមួយៗ និងប្រភេទដីដែលត្រូវបានវាស់វែង

ព័ត៌មានដែលប្រមូលបានពីបណ្តាភូមិមួយចំនួននៅក្នុងខេត្តគោលដៅនៃការសិក្សានេះបង្ហាញថា ការចេញប័ណ្ណកម្មសិទ្ធិលើទំហំដីរបស់ប្រជាជនក្នុងតំបន់នីមួយៗ មានភាពខុសៗគ្នា។ ក្នុងភូមិឃុំខ្លះក្នុងខេត្តកំពង់ឆ្នាំង ទំហំដីក្នុងប័ណ្ណកម្មសិទ្ធិមួយអាចមានរហូតដល់ដប់(១០)ហិកតាក្នុងមួយប័ណ្ណកម្មសិទ្ធិ។ មិនតែប៉ុណ្ណោះ គ្រួសារខ្លះអាចធ្វើប័ណ្ណកម្មសិទ្ធិ ចំនួនជាច្រើនប័ណ្ណដោយមានដាក់ឈ្មោះ ប្តី ប្រពន្ធ កូន ចៅ ឬសាច់ញាតិ ដើម្បីឲ្យគ្របដណ្តប់លើទំហំដីដែលគ្រួសារនោះមាន។ តាមការសង្កេតរបស់ប្រជាជននៅក្នុងភូមិមួយក្នុងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង គ្រួសារខ្លះធ្វើបណ្ណ័កម្មសិទ្ធិដីសរុបទំហំ៥០ហិកតាក៏មាន (ខែឧសភា ឆ្នាំ២០១៣)។ នៅក្នុងភូមិខ្លះទៀតនៅក្នុងខេត្តឧត្តរមានជ័យ ក្រុមនិស្សិតស្ម័គ្រចិត្ត និងមន្ត្រីជំនាញបានចេញ បណ្ណ័កម្មសិទ្ធិក្នុងទំហំដីក្រោមដប់ហិកតា (អាចច្រើនជាងប្រាំហិកតា តែតិចជាងដប់ហិកតា)។ ប៉ុន្តែក្រោយមក អាជ្ញាធរឃុំបែរជាប្រកាសប្រាប់ប្រជាជនថា អាជ្ញាធរនឹងដកហូតមកវិញនូវដីដែលមានទំហំលើសពីប្រាំហិកតា ដោយមិនបានប្រាប់ពីមូលហេតុនៃការដកហូត។

> ***"នៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០១៣ មេឃុំលំទង់ បានប្រកាសដល់ប្រជាពលរដ្ឋ១០គ្រួសារដែលបានវាស់វែងដីរួចថា អាជ្ញាធរនឹងដកយកដី៥០% ចំពោះគ្រួសារដែលបានទទួលប័ណ្ណដែលមានដីទំហំចាប់ពីប្រាំហិកតាឡើងទៅ។ ចំពោះអ្នកដែលមានដីក្រោម៥ហិកតាមិនមានការដកហូតទេ។"*** ករណីសិក្សាភូមិស្រឡៅស្រោង ខេត្តឧត្តរមានជ័យ ខែមិថុនា ឆ្នាំ២០១៣។

នៅក្នុងសេចក្តីណែនាំនៃការចុះអនុវត្តបទបញ្ជា០១(បប) ក្នុងប័ណ្ណកម្មសិទ្ធិមួយ គឺផ្តល់ឲ្យលើផ្ទៃដីកសិកម្មសម្រាប់ផលិត ដែលមិនលើសពីទំហំប្រាំហិកតា (ទីស្តីការគណៈរដ្ឋមន្ត្រី, ២០១២) ដោយអនុលោមទៅតាមច្បាប់ភូមិបាល ឆ្នាំ២០០១។ ប៉ុន្តែ ការអនុវត្តបទបញ្ជា០១(បប) ដែលមានដំណើរការ និងការកំណត់ទំហំដីមិនដូចគ្នាបែបនេះ គឺមិនយុត្តិធម៌ទេ ជាពិសេសសម្រាប់ប្រជាជនក្រីក្រដែលមានតិចទំហំតូច ឬអ្នកដែលដីរបស់គាត់ត្រូវបានរំលោភបំពានយកពីសំណាក់ឈ្មួញ ឬក្រុមហ៊ុន។ អ្នកភូមិមួយចំនួននៅក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ ដែលចូលរួមផ្តល់ព័ត៌មានសម្រាប់ការចងក្រងឯកសារនេះលើកឡើងថា តាមការសង្កេតរបស់ពួកគាត់ ក្រុមនិស្សិតដែលចុះមកវាស់វែងដីនៅក្នុងមូលដ្ឋានភូមិឃុំ តែងវាស់ដីឲ្យអ្នកដែលមានលុយច្រើនដែលជាម្ចាស់ដីធំ ហើយមានលុយសូកប៉ាន់អាជ្ញាធរមូលដ្ឋាន។ ប្រជាជននៅក្នុងភូមិមួយក្នុងស្រុកក្រគរអះអាងថា អ្នកមានលុយ តែងលួចសូកប៉ាន់លុយសមាជិកក្រុមប្រឹក្សាឃុំក្នុងឃុំគាត់ ដែលតែងដើរកៀកជាមួយក្រុមនិស្សិត និងជាអ្នកសម្រេចថា ត្រូវវាស់ដីឲ្យឬមិនវាស់ នៅតាមកន្លែងមួយៗ។ ប្រជាជនរូបនេះបញ្ជាក់ថា អាជ្ញាធរមូលដ្ឋានក្នុងឃុំនេះមានអំណាចច្រើននៅក្នុងការសម្រេចលើការវាស់វែងដីធ្លី ហើយក្រុមនិស្សិតចាំតែស្តាប់អាជ្ញាធរមូលដ្ឋានទេ។ (ការសម្ភាសន៍ ១៩ ខែមិថុនា ២០១៣)។

## ៤.២ ការជួលឈ្មោះមនុស្ស ដាក់លើប័ណ្ណកម្មសិទ្ធិ

នៅភូមិខ្លះទៀត នៅស្រុកក្រគរ ខេត្តពោធិ៍សាត់ ទំហំដីក្នុងប័ណ្ណនិមួយៗ គឺមិនលើសពីប្រាំ(៥) ហិកតាទេ។ ក៏ប៉ុន្តែ មានករណីដែលម្ចាស់ដីដែលជាអ្នកមានដី និងលុយច្រើនបានជួលឈ្មោះកម្មករ ឬអ្នកភូមិក្នុងភូមិឲ្យដាក់ឈ្មោះនៅលើប្លង់ដីរបស់ខ្លួន។ តាមការផ្តល់ព័ត៌មានរបស់ប្រជាជនម្នាក់នៅក្នុងភូមិខ្លាក្រពើ៖

> *"ក្នុងភូមិនេះ មានការជួលអ្នកភូមិ និងកម្មករឲ្យដាក់ឈ្មោះនៅលើក្បាលដីឲ្យម្ចាស់ដីដែលមានដីច្រើន នៅពេលដែលក្រុមនិស្សិតស្ម័គ្រចិត្តចុះមកវាស់វែងដីធ្លី កាលពីដំណាក់កាលទីមួយ។ មុនតំបូង ម្ចាស់ដីដាក់ឈ្មោះម៉ីង មា ក្មួយ ឬកូនរបស់ខ្លួនសិន។ ក្រោយពីដាក់ឈ្មោះសាច់ញាតិអស់ហើយ នៅសល់ដីទៀត គេជួលមនុស្សក្នុងភូមិ ឲ្យដាក់ឈ្មោះនៅលើក្បាលដី។ នៅលើប័ណ្ណកម្មសិទ្ធិនោះ មានបិទរូបថត និងដាក់ឈ្មោះរបស់អ្នកដែលត្រូវគេជួល។ ក្រោយពេលដែលបានប្លង់រឹងហើយ ម្ចាស់ដីប្រមូលយកប្លង់នោះរក្សាទុក ហើយក្នុងមួយឈ្មោះ គឺបានឈ្នួល១៥ម៉ឺនរៀល។ អ្នកជិតខាងម្នាក់ នៅខាងត្បូងផ្ទះខ្ញុំ ក៏ស៊ីឈ្នួលដាក់ឈ្មោះនៅលើក្បាលដីរបស់គេដែរ។"* ព័ត៌មានផ្តល់នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣។

តាមការផ្តល់ព័ត៌មានពីប្រជាជនតាមភូមិ ករណីនៃការជួលឈ្មោះមនុស្ស ដាក់លើប័ណ្ណកម្មសិទ្ធិដីរបស់ម្ចាស់ដីដែលមានដីច្រើន គឺមិនមែនកើតមានឡើងតែនៅក្នុងតំបន់មួយចំនួននៃក្នុងខេត្តពោធិ៍សាត់ទេ។ ករណីនេះ ក៏កើតមាននៅក្នុងខេត្តឧត្តរមានជ័យផងដែរ។ ករណីបែបនេះ បណ្តាលឲ្យមានសំណួរចោទឡើងថា តើយុទ្ធនាការចុះវាស់វែងដីធ្លីនេះ មានគោលដៅសំខាន់ក្នុងការផ្តល់សិទ្ធិគ្រប់គ្រង និងកាន់កាប់ទៅលើដីស្របច្បាប់ដល់ប្រជាជនក្រីក្រ (ប្រទានកម្មដីធ្លី) ឬក៏មានចេតនាផ្តល់ឱកាស និងភាពស្របច្បាប់ដល់អ្នកដែលមានអំណាច និងមានដីធ្លីច្រើន។

## ៤.៣ ការផ្សព្វផ្សាយពីយុទ្ធនាការចុះវាស់វែងដីធ្លីដល់សហាគមន៍នៅមានកម្រិត

ជំហានក្នុងការអនុវត្តបទបញ្ជា០១(បប) លើកឡើងថា អាជ្ញាធរថ្នាក់ខេត្ត ស្រុក និងថ្នាក់មូលដ្ឋាន (មេភូមិ សមាជិកក្រុមប្រឹក្សាឃុំ) និងក្រុមការងារថ្នាក់ខេត្ត ត្រូវធ្វើការរៀបចំនៅមូលដ្ឋាន និងផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយដល់ប្រជាជនក្នុងសហគមន៍ ដែលមានដីត្រូវធ្វើការវាស់វែង ពីពេលវេលាដាក់លាក់ដែលក្រុមនិស្សិត និងមន្ត្រីជំនាញចុះមកដល់ ឯកសារដែលម្ចាស់ដីត្រូវរៀបចំការបោះបង្គោលព្រំប្រទល់ដីជាដើម។ ជាក់ស្តែង ព័ត៌មានដែលប្រមូលបានពីភូមិគោលដៅនៃការចងក្រងឯកសារនេះ ដំណើរការនៃការផ្សព្វផ្សាយព័ត៌មានដល់ប្រជាជន មិនមានលក្ខណៈទូលំទូលាយនៅគ្រប់ភូមិនោះទេ។ ក្នុងភូមិមួយចំនួននៅស្រុកក្រគរ ខេត្តពោធិ៍សាត់ ការផ្សព្វផ្សាយគឺដោយអន្លើៗ ដោយអាជ្ញាធរភូមិ ដាក់រទេះដឹកមេក្រូ ធ្វើការផ្សព្វផ្សាយតែនៅភូមិចំនួនដែលនៅតាមផ្លូវជាតិ ខណៈដែលភូមិជាច្រើនទៀត មិនស្ថិតនៅជាប់នឹងថ្នល់ជាតិ ការទទួលបានដំណឹងពីដំណើរការ និងបេសកកម្មរបស់ក្រុមនិស្សិត គឺមានកម្រិត។

ម្យ៉ាងវិញទៀត បេសកម្មរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត និងមន្ត្រីជំនាញក្នុងមូលដ្ឋាននីមួយៗ មានរយៈពេលខ្លី និងមានកំណត់។ កត្តានេះ ទាមទារឲ្យមានការត្រៀមរៀបចំជាមុន និងធ្វើការផ្សព្វផ្សាយព័ត៌មានដល់ប្រជាជនក្នុងមូលដ្ឋានឲ្យបានទូលំទូលាយមុនពេលក្រុមការងារចុះដល់។ តាមរយៈការប្រមូលព័ត៌មានពីបទពិសោធន៍របស់ប្រជាជននៅក្នុងភូមិមួយចំនួន គឺពួកគាត់មិនបានដឹងពីពេលវេលាច្បាស់លាស់ដែលក្រុមនិស្សិតចុះមកវាស់វែងដីធ្លីទេ តែឃើញវត្តមានរបស់ពួកគេនៅក្នុងភូមិរបស់ខ្លួនតែម្តង។ ក្នុងភូមិខ្លះទៀត ដែលប្រជាជនរស់នៅពឹងអាស្រ័យផលជាមួយនឹងអនុផលព្រៃឈើ(ចូលព្រៃយូរថ្ងៃ) និងភូមិដែលប្រជាជនធ្វើចំណាកស្រុកការផ្តល់ដំណឹងក្នុងរយៈពេលខ្លី ធ្វើឲ្យសមាជិកគ្រួសារ មិនអាចត្រឡប់មកទាន់ពេលដែលក្រុមនិស្សិតចុះធ្វើការវាស់វែងទេ។ កត្តានេះ ធ្វើឲ្យគ្រួសារទាំងនេះខកខាន មិនបានចូលរួមក្នុងការវាស់វែងដី។ ករណីសិក្សានៅក្នុងភូមិស្រឡៅស្រោង ដែលបង្ហាញនៅផ្នែកបន្ទាប់ គឺជាឧទាហរណ៍នៃការសម្រេចបានលទ្ធផលកម្រិតទាបនៃការវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត ដោយសារតែអត្រាចំណាកស្រុកខ្ពស់របស់ប្រជាជនក្នុងភូមិនេះ។ ដូច្នេះការចុះបំពេញបេសកម្មក្នុងការវាស់វែងក្នុងមួយលើកៗ មានផែនការដែលត្រូវសម្រេចឲ្យបាន ប៉ុន្តែប្រសិនបើក្រុមការងារ វាស់វែងដីក្នុងភូមិបានចំនួនតិចគ្រួសារពេក គឺមិនត្រឹមតែធ្វើឲ្យការងារសម្រេចមិនបានតាមផែនការតែប្រជាជននឹងមិនទទួលបានប្លង់កម្មសិទ្ធិដីទៀតផងដោយសារតែមិនបានចូលរួម និងតម្រូវឲ្យមានការចុះមកធ្វើការវាស់វែងជាថ្មីម្តងទៀត។

> ***"ប្រជាពលរដ្ឋមានការព្រួយបារម្ភពីការវាស់វែងនេះ ដោយសារតែការវាស់វែងនេះ មានរយៈពេលខ្លី និងប្រព្រឹត្តិទៅឆាប់រហ័សពេក តែចំពោះប្រជាពលរដ្ឋវិញ ដីធ្លីគឺជំផេងខ្លាំងណាស់ (សម្រាប់ជីវិតរបស់គាត់)។"*** ប្រជាពលរដ្ឋស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ខែមិថុនា ឆ្នាំ២០១៣។

# ៤.៤ ការវិវត្តន៍ឆាប់រហ័សនៃការអនុវត្តបទបញ្ជា០១(បប)

យុទ្ធនាការនៃការអនុវត្តបទបញ្ជា០១(បប) ត្រូវបានអនុវត្តយ៉ាងឆាប់រហ័ស ក្នុងរយៈពេលមួយខែក្រោយពីការប្រកាសបទបញ្ជានេះជាសាធារណៈ។ ជាក់ស្តែង ការអនុវត្តបទបញ្ជា០១(បប) មានការវិវត្តន៍ ប្រែប្រួលខុសគ្នា រវាងជំហានទីមួយ និងជំហានទីពីរ។ ជាករណីជាក់ស្តែង ការផ្លាស់ប្តូរពាក់ព័ន្ធនឹងការចេញលិខិតបទដ្ឋានគតិយុត្តនានា គឺតែងតែចេញប្រកាសក្រោយពេលដែលមានការផ្តល់យោបល់ពីនាយករដ្ឋមន្ត្រី។ តួយ៉ាងដូចជា ការសម្រេចលុបចោលដំណាក់កាលអន្តរកាល ពីការផ្តល់ប័ណ្ណកម្មសិទ្ធិបឋម មកផ្តល់ជាប័ណ្ណកម្មសិទ្ធិពេញលេញតែម្តង ក្រោយពីមានការចុះវាស់វែងដោយក្រុមនិស្សិតស្មគ្រចិត្តរួចហើយ គឺកើតឡើងក្រោយពេលដែលនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ចេញសេចក្តីប្រកាសនៅក្នុងសន្ទរកថាមួយរបស់លោកតែបណ្តោះ។ ដោយហេតុថានាយករដ្ឋមន្ត្រីមិនចង់ឲ្យមានការរង់ចាំយូររហូតដល់ប្រាំមួយខែ ហើយការងាររបស់ក្រុមនិស្សិតកន្លងមក បង្ហាញពីភាពម៉ត់ចត់ និងអាចទុកចិត្តបាន។ (វិទ្យុអាស៊ីសេរី ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២, លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១២ )។

ប្រភេទដីដែលត្រូវវាស់វែងក៏មានការផ្លាស់ប្តូរដែរ។ នៅពេលអនុវត្តយុទ្ធនាការជំណាក់កាលទី១ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ **អ៊ឹម ឈុនលឹម** ប្រកាសថា *"និស្សិតនឹងត្រូវបញ្ជូនទៅធ្វើការវាស់វែងដី នៅតំបន់ដែលមានជម្លោះដីធ្លីច្រើន"* ប៉ុន្តែក្រោយមក នាយករដ្ឋមន្ត្រីហ៊ុនសែន បានធ្វើការកែប្រែដំណើរការអនុវត្តការងារនេះ។ ដូច្នេះ និស្សិត នឹងមិនវាស់វែងដីដែលមានជម្លោះទៀតទេ (May, ២០១២)។ មូលហេតុឫសគល់ នៃការការកែប្រែការអនុវត្តបទបញ្ជា០១(បប) គឺដូចគ្នា នឹងការដាក់ចេញការអនុវត្តបទបញ្ជា គឺមិនមានការប្រឹក្សាយោបល់ជាមួយនឹងប្រជាពលរដ្ឋទេ។ មានក្តីកង្វល់ជាច្រើនដែលត្រូវបានលើកឡើងពាក់ព័ន្ធនឹងការបណ្តុះបណ្តាលនិស្សិតស្ម័គ្រចិត្តឲ្យបានគ្រប់គ្រាន់ ដើម្បីអាចចុះអនុវត្តការងាររបស់ខ្លួន។ ប៉ុន្តែអ្វីដែលសំខាន់ផងដែរ គឺការចូលរួមអនុវត្តការងាររបស់អាជ្ញាធរពាក់ព័ន្ធនៅគ្រប់ជាន់ថ្នាក់ ជាពិសេសនៅថ្នាក់មូលដ្ឋានដែលនៅជាប់នឹងប្រជាពលរដ្ឋ ថាតើពួកគាត់បានយល់ច្បាស់ពីយុទ្ធនាការនេះ និងបានធ្វើការផ្សព្វផ្សាយ និងពន្យល់ដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាននបានកម្រិតណា។ គួររំលឹកថា នាយករដ្ឋមន្ត្រីបានប្រកាសជាសាធារណៈមិនឲ្យម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ លូកដៃនៅក្នុងបេសកកម្មនេះទេ គឺទុកភារកិច្ចនេះដល់ក្រុមយុវជនស្ម័គ្រចិត្តនិងមន្ត្រីជំនាញ ក្រោមកិច្ចសហការពីសំណាក់អាជ្ញាធរមូលដ្ឋាន ឲ្យអនុវត្តបទបញ្ជានេះ។ ដូច្នេះ តួនាទីរបស់អាជ្ញាធរមូលដ្ឋាន ក្នុងការផ្សព្វផ្សាយព័ត៌មានដល់ប្រជាជន មានសារៈសំខាន់ខ្លាំងណាស់។ សំណួរចំបងគឺថា តើការផ្លាស់ប្តូរ និងការបត់បែនទាំងឡាយក្នុងការអនុវត្តបទបញ្ជា០១(បប) ក្នុងសភាពលឿនបែបនេះ មានការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានដែរឬទេ? តើពួកគាត់បានទទួលព័ត៌មានជាក់លាក់ និងទាន់ពេលវេលាពីក្រុមការងារដែរឬទេ?

## ៤.៥ បញ្ហាកំហុសបច្ចេកទេសក្នុងការចុះវាស់វែងដីធ្លី

តាមរយៈព័ត៌មានដែលប្រមូលផ្តុំនៅក្នុងការចងក្រងឯកសារនេះ បង្ហាញឲ្យឃើញថា យុទ្ធនាការចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្តសម្តេចតេជោបង្កឲ្យមានជម្លោះ និងវិវាទដីធ្លីបន្ថែមទៀត ដូចជាករណីប័ណ្ណកម្មសិទ្ធិដីត្រួតស៊ីគ្នា ការដកហូតប័ណ្ណកម្មសិទ្ធិដោយសារតែការវាស់វែងរបស់ក្រុមនិស្សិតមានកំហុសបច្ចេកទេស។ នេះជាការអះអាងរបស់មន្ត្រីទទួលបន្ទុកកន្លងមក។ ក៏ប៉ុន្តែយើងដឹងថា នៅក្នុងក្រុមការងារចុះវាស់វែងដីធ្លីមួយក្រុមៗ តែងតែមានក្រុមការងារបច្ចេកទេសមកពីគ្រប់ស្ថាប័នពាក់ពន្ធ័ ដូចជាមន្ត្រីសុរិយោដី កសិកម្ម ខណ្ឌរដ្ឋបាលព្រៃឈើ មន្ត្រីបរិស្ថាន សមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន (ថ្នាក់ស្រុក ឃុំ ភូមិ) រួមជាមួយនឹងប្រជាពលរដ្ឋម្ចាស់ដី។ ចុះហេតុអ្វីបានជាមានបញ្ហាបច្ចេកទេស ដែលទាក់ទងនឹងផែនទីដី និងភូមិសាស្ត្រដីធ្លីនៅតែកើតមានឡើង នៅពេលដែលមានវត្តមានរបស់មន្ត្រីបច្ចេកទេសទៅជាមួយ? នៅស្ទើរតែគ្រប់ករណីនៃជម្លោះដីធ្លីដែលកើតឡើងក្រោយពីការវាស់វែងបណ្តាលមកពីកំហុសខាងបច្ចេកទេសទាំងនេះ ប្រជាជនក្រីក្រដែលជាម្ចាស់ដី តែងតែជាអ្នកត្រូវរងការបាត់បង់ដោយសារតែកំហុសឆ្គងខាងបច្ចេកទេសទាំងនេះ ដែលធ្វើឲ្យពួកគាត់មិនត្រឹមតែបាត់បង់ដីធ្លីទេ ថែមទាំងបាត់បង់ជីវភាពរស់នៅរបស់គាត់ និងក្រុមគ្រួសារទៀតផង។ មិនមានរបាយការណ៍ដែលលើកឡើងពីកំហុសបច្ចេកទេសស្រដៀងគ្នានេះកើតឡើងនៅពេលវាស់វែងដីរបស់អ្នកមានអំណាច ឬក្រុមហ៊ុននោះទេ។

# ៤.៦ ការរង់ចាំទទួលបានប័ណ្ណកម្មសិទ្ធិពេញលេញមានរយៈពេលយូរពេក

កិច្ចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិពេញលេញ ដល់ប្រជាពលរដ្ឋនៅតាមបណ្តាលខេត្តមួយចំនួនដែលរស់នៅដាច់ស្រយ៉ាល ហាក់ដូចជាមានសភាពយឺតយ៉ាវខ្លាំងខុសពីធម្មតាទោះបីជាការវាស់វែងបាន ធ្វើឡើងតាំងពីដំហានទីមួយនៃផែនការ (ពាក់កណ្តាលឆ្នាំ២០១២)។ ជាក់ស្តែង ប្រជាជននៅតាមភូមិមួយចំនួនក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលក្រុមនិស្សិតបានចុះធ្វើការវាស់វែងតាំងពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ (ក្នុងជំហានទី១) រហូតមកទល់នឹងចុងខែឧសភា ឆ្នាំ២០១៣នេះ គឺមានរយៈពេលដប់ខែកន្លងមកហើយ ប៉ុន្តែប្រជាជននៅតែមិនទាន់បានទទួលប័ណ្ណកម្មសិទ្ធិពេញលេញនៅឡើយ។ ក្នុងនិតិវិធីនៃការអនុវត្តបទបញ្ជា០១ (បប) ប័ណ្ណកម្មសិទ្ធិពេញលេញ នឹងត្រូវធ្វើការផ្តល់ដល់ម្ចាស់ដីក្នុងរយៈពេលមិនលើសពីប្រាំមួយខែ ចាប់តាំងពីពេលដែលធ្វើការវាស់វែងរួច។ មិនមានការពន្យល់ និងលើកមូលហេតុជាក់លាក់ណាមួយមកជម្រាបដល់ប្រជាជនក្នុងមូលដ្ឋានពីការយឺតយ៉ាវនេះទេ ហើយអាជ្ញាធរភូមិឃុំ ក៏ហាក់ដូចជាគ្មានព័ត៌មានអ្វីជាក់លាក់ដែរក្រៅពីត្រូវ *"រង់ចាំដំណឹងពីខាងលើ"*។

នៅក្នុងពេលចុះប្រមូលព័ត៌មាន ប្រជាជនភាគច្រើន ដែលដីរបស់គាត់បានទទួលការវាស់វែងដីរួចកំពុងរង់ចាំការទទួលបានប័ណ្ណកម្មសិទ្ធិពេញលេញដោយក្តីអន្ទះសារ។ ពួកគាត់ភាគច្រើនមានចង្ងល់ដោយមិនដឹងថាពេលណាទើបគាត់នឹងទទួលបានប័ណ្ណកម្មសិទ្ធិ។ មានមូលហេតុមួយចំនួននៃការបារម្ភក្នុងពេលរង់ចាំ និងការភ័យខ្លាចមិនបានទទួលប័ណ្ណកម្មសិទ្ធិពេញលេញនេះ។ មូលហេតុទីមួយ ហាក់ដូចជាសរបញ្ជាក់ថា ការផ្តល់ព័ត៌មានពីសំណាក់អាជ្ញាធរមូលដ្ឋាន មន្ត្រីជំនាញ និងក្រុមនិស្សិតដែលចុះអនុវត្តការងារ ដល់ប្រជាជនពីរយៈពេលរង់ចាំ និងដំណើរការនៃការធ្វើការងារមុនពេលដែលអាចផ្តល់ប័ណ្ណកម្មសិទ្ធិពេញលេញដល់ពួកគាត់ ហាក់ដូចជាមិនច្បាស់លាស់។ មូលហេតុទីពីរ អាចបណ្តាលមកពីប្រជាជនមានការខ្លាចអោរ ដោយសារតែឯកសារគាំទ្រនានាសម្រាប់ការវាស់វែងដែលគ្រួសារគាត់មាន ត្រូវបានក្រុមការងារចុះវាស់វែងដីធ្លីប្រមូលយកទៅជាមួយអស់ទៅហើយដើម្បីដំណើរការចុះបញ្ជី និងផ្តល់ប័ណ្ណកម្មសិទ្ធិពេញលេញ។ ប្រសិនបើប្រជាជនមិនបានដឹងច្បាស់ពីនិតិវិធីក្នុងការធ្វើការរបស់ស្ថាប័នជំនាញ ពួកគាត់នឹងមានការព្រួយបារម្ភ។ ត្រឡប់មកវិញ សំណួរដែលនៅតែចោទសួរ គឺជុំវិញភាពច្បាស់លាស់ និងកម្រិតនៃការផ្សព្វផ្សាយព័ត៌មានពីសំណាក់អាជ្ញាធរមូលដ្ឋាន និងមន្ត្រីជំនាញដល់ប្រជាជននៅមុនពេល និងក្នុងពេលចុះបំពេញបេសកម្ម។

***"ប័ណ្ណកម្មសិទ្ធិ ជាកំណប់ទ្រព្យរបស់អ្នក ជាសុវត្ថិភាពរបស់អ្នក"*** ពាក្យស្លោកនេះ តែងតែត្រូវបានបិទផ្សាយ នៅរៀងរាល់ពេលដែលមានការចុះចែកប័ណ្ណកម្មសិទ្ធិពេញលេញម្តងៗ។ នេះជាការឆ្លុះបញ្ចាំងពីភាពសំខាន់របស់ប័ណ្ណកម្មសិទ្ធិដីធ្លីចំពោះម្ចាស់កម្មសិទ្ធិ។ ករណីសិក្សា របស់ប្រជាជន១០គ្រួសារ ក្នុងស្រុកក្រគរខេត្តពោធិ៍សាត់ និងក្តីព្រួយបារម្ភរបស់ប្រជាជនមួយចំនួនក្នុងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ពីប្រសិទ្ធិភាពនៃប័ណ្ណកម្មសិទ្ធិដីធ្លីថ្មី គឺជាសំណួរសំខាន់ដែលគួរត្រូវលើកយកមកពិចារណា និងស្វែងរកដំណោះស្រាយសម្រាប់ប្រជាជន។ ខណៈដែលបញ្ហារំលោភបំពានដីធ្លី បន្តកើតឡើងចំពោះប្រជាជន នៅតាមបណ្តាលខេត្តមួយចំនួនស្ទើរមិនលោះថ្ងៃ ប្រសិនបើប័ណ្ណកម្មសិទ្ធិថ្មីមិនបានផ្តល់សន្តិសុខ សុវត្ថិភាព និងសិទ្ធិក្នុងការទទួលបានការគ្រប់គ្រងទៅលើដីធ្លីរបស់ប្រជាពលរដ្ឋដែលជាម្ចាស់កម្មសិទ្ធិទេ ដូច្នេះបេសកម្មស្នូលក្នុងការដោះស្រាយជំលោះដីធ្លី

របស់ប្រជាជន តាមរយៈកម្មវិធីចុះវាស់វែងដីធ្លីនៃបទបញ្ជា០១(បប)នេះ មិនត្រូវបានឆ្លើយតបបានពេញលេញឡើយ។

ប្រជាពលរដ្ឋដែលរស់នៅជនបទ ជាពិសេសអ្នកដែលរស់នៅតំបន់ដាច់ស្រយ៉ាល មិនបានដឹងច្បាស់ពីគោលការណ៍នៃការចុះវាស់វែងដីធ្លីរបស់ក្រុមនិស្សិតស្ម័គ្រចិត្តនោះទេ។ ប្រជាជនភាគច្រើនដែលពឹងអាស្រ័យលើអនុផលព្រៃឈើ ឬការនេសាទសម្រាប់ការចិញ្ចឹមជីវិត ឥឡូវនេះតម្រូវឲ្យគាត់ធ្វើដំណើរចូលព្រៃម្តងៗមានរយៈពេលយូរដែលធ្វើឲ្យគាត់ខកខានមិនបានទទួលព័ត៌មាន ឬចូលរួមក្នុងការប្រជុំនៅក្នុងភូមិ។ ម្យ៉ាងវិញទៀត ចំណេះដឹងផ្នែកច្បាប់ និងនិតិវិធីនានាក្នុងការធ្វើការរបស់ប្រជាជនដែលរស់នៅតំបន់ជនបទនៅមានកម្រិត។ ស្ថានភាពនេះ ទាមទារឲ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់ ជាពិសេសនៅថ្នាក់មូលដ្ឋាន ធ្វើការទំនាក់ទំនងឲ្យបានជិតដល់ និងផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយ ពីដំណាក់កាលនៃការចុះវាស់វែងដីធ្លីរហូតដល់ពួកគាត់បានទទួលប័ណ្ណកម្មសិទ្ធិពេញលេញដើម្បីឲ្យប្រជាជនបានជ្រាបច្បាស់ និងការចូលរួមរបស់គាត់បានពេញលេញ និងប្រកបដោយអត្ថន័យ។

# សន្និដ្ឋាន

យុទ្ធនាការ *"នយោបាយចាស់ សកម្មភាពថ្មី លើវិស័យដីធ្លី"* អនុវត្តបទបញ្ជា០១(បប) របស់នាយករដ្ឋមន្ត្រី **ហ៊ុន សែន** តាមរយៈការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចុះធ្វើការវាស់វែងដីធ្លី គឺជាយុទ្ធនាការនយោបាយមួយដែលត្រូវបានអនុវត្តនៅក្នុងពេលវេលាមួយដ៏សមស្រប ដើម្បីឆ្លើយតបទៅនឹងបញ្ហាដីធ្លីដែលកាន់តែរីករាលដាលក្នុងទសវត្សន៍ចុងក្រោយនេះ។ យុទ្ធនាការនេះ ប្រើប្រាស់ថវិកាផ្ទាល់ខ្លួនរបស់នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា និងសមាជិកសំខាន់ៗរបស់គណបក្សប្រជាជនកម្ពុជាដើម្បីអនុវត្តការងារដែលដឹកនាំផ្ទាល់ដោយកូនប្រុសរបស់សម្តេច**ហ៊ុន សែន** ផ្ទាល់ គឺលោក**ហ៊ុន ម៉ានិត**។ លើសពីនេះទៀត យុទ្ធនាការអនុវត្តបទបញ្ជា០១(បប) មិនបានប្រើប្រាស់ទាំងស្រុងនូវយន្តការរបស់រដ្ឋាភិបាលដែលមានស្រាប់ គឺក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីអនុវត្តការងារទេ តែបានជ្រើសរើសនិស្សិតស្ម័គ្រចិត្ត មកពីតាមបណ្តាសមាគមសិស្ស និស្សិតសាកលវិទ្យាល័យនានាដែលមានឆន្ទៈនយោបាយស្មោះត្រង់ជាមួយគណបក្សប្រជាជនកម្ពុជា ដើម្បីចុះអនុវត្តយុទ្ធនាការងារវាស់វែងដីធ្លីនេះ។

តាមរយៈកម្មវិធីនៃការចុះវាស់វែងដីធ្លីនេះ ប្រជាជនមួយភាគទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីដែលសំគាល់ពីសិទ្ធិស្របច្បាប់ ក្នុងការកាន់កាប់លើដីធ្លីរបស់ពួកគាត់។ ទោះយ៉ាងនេះក្តី ប្រជាជននៅតាមបណ្តាខេត្តមួយចំនួន កំពុងតែជួបប្រទះនឹងបញ្ហាដែលជារួមមាន៖ ត្រូវមន្ត្រីអាជ្ញាធរ ដកហូតប័ណ្ណកម្មសិទ្ធិរបស់ខ្លួន ខ្លះមិនបានទទួលប័ណ្ណកម្មសិទ្ធិ ខ្លះត្រូវក្រុមហ៊ុនរាំងមិនអោយប្រើប្រាស់ដីធ្លីរបស់ខ្លួន ខ្លះប្រឈមមុខនឹងអ្នកមានអំណាច និងអ្នកមានលុយ រំលោភយកដីរបស់គាត់ ក្នុងពេលដែលក្រុមនិស្សិតស្ម័គ្រចិត្តចុះមកធ្វើការវាស់វែងដីធ្លី។ ប្រជាជនតាមសហគមន៍មួយចំនួនជាពិសេសនៅក្នុងខេត្តពោធិ៍សាត់បានប្រឈមនឹងការឈូសឆាយរំលើងផ្ទះរបស់ពួកគាត់ដោយក្រុមហ៊ុនភាពីម៉ិច និងកងកម្លាំងប្រដាប់អាវុធយោងតាមការរាយការណ៍របស់កាសែតក្នុងស្រុកខ្លះ ប្រជាពលរដ្ឋត្រូវរងនូវការគំរាមកំហែងពីសំណាក់អាជ្ញាធរ មន្ត្រីជំនាញ ហើយយ៉ាងហោចណាស់ក៏សកម្មជនម្នាក់ត្រូវបានចាប់ឃុំខ្លួនដោយសមត្ថកិច្ច។

បញ្ហាប្រឈមសំខាន់បំផុតនៅក្នុងជំហានទីមួយនៃការអនុវត្តបទបញ្ជា០១(បប) គឺថា ការអនុវត្តការយុទ្ធនាការចុះវាស់វែងដីធ្លី គឺជាបេសកកម្មដែលថ្មីស្រឡាង សម្រាប់ទាំងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ជាពិសេសនៅថ្នាក់មូលដ្ឋាន។ ដូច្នេះ នៅពេលដែលមានសេចក្តីបង្គាប់មកពីខាងលើថាមានការចុះមកដល់នៃក្រុមនីស្សិតស្ម័គ្រ និងមន្ត្រីជំនាញមកធ្វើការវាស់វែងដីធ្លី អាជ្ញាធរមូលដ្ឋាន និងប្រជាជនមិនបានដឹងច្បាស់ថា តើកិច្ចការនោះ នឹងត្រូវដំណើរការដោយរបៀបណា? បន្ថែមលើនេះទៀត យុទ្ធនាការនេះប្រើប្រាស់ពេលវេលាខ្លី និងតម្រូវអោយសម្រេចបានលទ្ធផលដែលមានទំហំធំ តែពឹងពាក់លើនិស្សិតស្ម័គ្រចិត្តដើម្បីអនុវត្តការងារ តែក្រុមនិស្សិតទាំងនេះទទួលបានការបណ្តុះបណ្តាលបច្ចេកទេសរយៈពេលខ្លីបំផុតមុនពេលចុះបំពេញការងារ។

ទោះបីជា គណៈកម្មាការជាតិដោះស្រាយវិវាទដីធ្លី ត្រូវបានបង្កើតឡើងដើម្បីទទួលខុសត្រូវក្នុងការដោះស្រាយវិវាទដីធ្លីក៏ដោយ ប្រជាជនដែលជួបប្រទះនឹងភាពអយុត្តិធម៌នៅក្នុងពេលដែលក្រុមនិស្សិតចុះអនុវត្តការវាស់វែង និងក្រោយពេលដែលពួកគាត់ទទួលបានប័ណ្ណកម្មសិទ្ធិហើយតែត្រូវប្រឈមមុខនឹងបញ្ហានោះ គឺហាក់មិនបានទទួលការដោះស្រាយសមរម្យណាមួយពីសំណាក់គណៈកម្មាធិការនេះដល់ពួកគាត់ឡើយ។ ផលប៉ះពាល់មកលើប្រជាជនក្រីក្រតូចតាច គឺការបាត់បង់មិនត្រឹមតែដីធ្លីសម្រាប់ប្រកបរបរចិញ្ចឹមជីវិតប៉ុណ្ណោះទេ តែ

ត្រូវខាតបង់ពេលវេលា និងជីវភាពរស់នៅរបស់គាត់និងក្រុមគ្រួសារ ដោយសារតែទំនាស់ដីធ្លីដែលបន្តរ៉ាំរ៉ៃ និងគ្មានដំណោះស្រាយជាក់លាក់ ។

ដំណើរការនៃការវាស់វែងដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធិ ក្នុងទម្រង់ដែលបានអនុវត្តកន្លងមក ហាក់ដូចជាមិនបានពង្រឹងភាពម្ចាស់ការ និងបង្កើនចំណេះដឹងដល់ប្រជាពលរដ្ឋទេនៅពេលដែលពួកគេចូលរួមក្នុងដំណើរការនេះ។ លើសពីនេះទៀត យុទ្ធនាការនេះក៏មិនបានពង្រឹងយន្តការរបស់រាជរដ្ឋាភិបាលដែលមានស្រាប់ និងដែលទទួលបន្ទុកលើការងារវាស់វែងដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធិដល់ប្រជាជនដែរ។ ការឃោសនានានាតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានស្តីពីយុទ្ធនាការចុះវាស់វែងដីធ្លី ជាពិសេសសកម្មភាពសង្គមនានារបស់ក្រុមនិស្សិតស្ម័គ្រចិត្តក្រៅពីការបំពេញភារកិច្ចរបស់ពួកគេ ហាក់ដូចជាសបញ្ជាក់ឲ្យឃើញថា ប្រជាពលរដ្ឋត្រូវបានរដ្ឋាភិ-បាលចាត់ទុកត្រឹមតែជាក្រុមអ្នកទទួលផលប្រយោជន៍ពីការវាស់វែងដីធ្លី និងការបានប័ណ្ណកម្មសិទ្ធិដែលចេញដោយក្រុមនិស្សិតស្មគ្រ័ចិត្តសម្តេចតេជោដោយមិនអស់ថវិកាផ្ទាល់ខ្លួនតែបណ្តោះ។ ដូច្នេះ ប្រជាជនត្រូវតែចូលរួមនៅក្នុងការវាស់វែងដីធ្លីនេះ។ ប្រជាជននៅតាមមូលដ្ឋាននានា សូម្បីតែជនជាតិដើមភាគតិច ត្រូវបានក្រុមនិស្សិតស្ម័គ្រចិត្តក៏ដូចជាអាជ្ញាធរមូលដ្ឋានប្រាប់ថា ប្រសិនបើពួកគេមិនទទួលយកការវាស់វែងដីនៅពេលនេះទេ នៅពេលដែលប្រជាជនចង់ធ្វើប័ណ្ណកម្មសិទ្ធិដីនៅពេលក្រោយទៀតនឹងប្រើរយៈពេលយូរ ហើយត្រូវចំណាយថវិកាផ្ទាល់ខ្លួនច្រើន។ ស្ថិតក្នុងស្ថានភាពបែបនេះ មិនមានជម្រើសច្រើនសម្រាប់ឲ្យប្រជាជនគិតគូរពិចារណាថ្លឹងថ្លែងមុននឹងធ្វើការសម្រេចចិត្តនោះទេ។

ប្រជាជនរស់នៅទីក្រុង និងតាមទីជនបទក្នុងប្រទេសកម្ពុជាកំពុងប្រឈមមុខនឹងបញ្ហាដីធ្លីដ៏ក្តៅគគុកក្រោមរូបភាពនៃការរំលោភបំពាន ការបណ្តេញចេញ និងការរឹបអូសយកដី ព្រៃ និងធនធានធម្មជាតិក្នុងទម្រង់ប្រកបដោយអំពើហិង្សា និងអយុត្តិធម៌ពីសំណាក់អ្នកមានអំណាច និងក្រុមហ៊ុននានា។ មូលហេតុសំខាន់មួយក្នុងចំណោមមូលហេតុនានានៃវិវាទដីធ្លីនេះ គឺដោយសារតែប្រជាជនគ្មានប័ណ្ណកម្មសិទ្ធិសំគាល់ម្ចាស់ទ្រព្យសម្បត្តិរបស់ខ្លួនស្របច្បាប់។ ឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកំណត់ព្រំប្រទល់ដីធ្លីច្បាស់លាស់ និងផ្តល់ប័ណ្ណកម្មសិទ្ធិស្របច្បាប់ដល់ប្រជាជនមានសារៈសំខាន់ និងគួរតែបានធ្វើឡើងក្នុងពេលវេលាមួយដ៏ត្រឹមត្រូវ។ យុទ្ធនាការចុះវាស់វែងដីធ្លីដែលផ្តួចផ្តើម និងប្រើថវិកាផ្ទាល់របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីមួយក្រុមតូចក្នុងជួរគណបក្សប្រជាជនកម្ពុជា ដែលកំពុងអនុវត្តដោយប្រើប្រាស់កម្លាំងនិស្សិតស្ម័គ្រចិត្តនេះជាយុទ្ធនាការដែលមានគោលដៅចំបងក្នុងការស្វែងរកការគាំទ្រផ្នែកខាងនយោបាយដល់បក្ស និងមិនមានិរន្តរ-ភាពក្នុងរយៈពេលយូរអង្វែង។ ឆន្ទៈនយោបាយក្នុងការផ្តល់បណ្ណ័កម្មសិទ្ធិស្របច្បាប់ដល់ប្រជាជន ដើម្បីការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីរបស់ខ្លួន គួរតែត្រូវបានអនុវត្តមួរយៈយន្តការរបស់រដ្ឋាភិបាលដែលមានស្រាប់ និងបន្តព្រងឹងយន្តការនេះឲ្យមានប្រសិទ្ធិភាព ប្រសិទ្ធិពលភាព តម្លាភាព គណនេយ្យភាពខ្ពស់ និងប្រកបដោយនិរន្តភាពសម្រាប់ប្រទេសកម្ពុជាដើម្បីធានាថាប្រជាជនកម្ពុជាទទួលបានផលប្រយោជន៍ពិតប្រាកដពីយុទ្ធនាការនេះប្រកបដោយសមធម៌។

# ឯកសារយោង


1. ADHOC. 2013. A TUNRING POINT? Land, Housing and Natural Resources Rights in Cambodia in 2012. ADHOC. February 2013.
2. Aun, P., 2012. "Nearly 200 More Families' Homes Razed in Pursat", *The Cambodia Daily,* August 1, 2012
3. Bopha, P., 2013. 'Hun Sen Fetes Student Volunteers With Lavish Party,' *The Cambodia Daily*, January 7, 2013, p.1-2
4. Boyle, D. & May, T., 2012. "PM Calls for Land Reform: Critics dismiss Hun Sen's Pledge as Empty Promises," *The Phnom Penh Post*, June 15, 2012, p.1-6
5. Cambodia Democratic Student Intellectual Federation 2009, Gift from Samdech Akka Momar Sena Pakdey Decho Hun Sen for 22 student associations, Cambodia Democratic Student Intellectual Federation, viewed April 1, 2013, <http://cambodiastudentfederation.blogspot.com/2009/07/budget-gife-of-samdach-akerk-momar-sana.html>.
6. Cambodia Grassroots People's Assembly (CGPA). People's Statement for the Northwest Siem Reap, 24 June 2013. Accessed at http://cambodiangrassroots.wordpress.com/category/statements/
7. Cambodia New Vision 2013, *Selected Impromptu Comments to the Party to Wrap Up Phase I Land Measurement and Titling Mission of the Youth-Student Volunteers of Samdech Techo,* Cambodia New Vision, viewed April 3, 2013, http://cnv.org.kh/en/?p=3441
8. Cambodia New Vision. 2012a, *Youth Volunteers to Measure Land for People*, Cambodia New Vision, viewed April 6, 2013, <http://cnv.org.kh/cnv_html_pdf/cnv_172_jun_12.pdf>.
9. Cambodia New Vision. 2012b. "1,178 Families Receive Land Title in Siem Reap", *Cambodian New Vision*, viewed April 7, 2013, http://cnv.org.kh/en/?p=1907
10. Certo, B De & Meas, S., 2012. "Conceding a Problem: Premier calls time out on land concession", *The Phnom Penh Post* May 8, 2012 p.1-5
11. Council of Ministers, 2012. Letter from the Council of Ministers to Senior Minister, Minister of Ministry of Land Management, Urban Planning and Construction. Phnom Penh. September 7th, 2012.
12. Council of Ministers, 2012. Letter of Deputy Prime Minister, Minister in Charge of the Council of Ministers to the Ministry of Land Management, Urban Planning and Construction. June 26, 2012.
13. Fitzpatrick, M., 2012, 'Controversy over Cambodia PM's Land Titling Plan', *Jakarta Globe*, October 7, 2012, viewed March 28, 2013, <http://www.thejakartaglobe.com/international/controversy-over-cambodia-pms-land-titling-plan/548714>
14. Heinrich Boll Foundation, Phnom Penh, Cambodia, viewed 5 April 2013,<https://www.conftool.com/landandpoverty2013/index.php?page=browseSessions&print=head&presentations=show&downloads=show&mode=list&form_session=51>
15. Khmerlivetv 2013, *TVK PM Hun Sen Speech: Dinner with Student Volunteers of Land Titling Program,* viewed April 1, 2013, <http://www.khmerlive.tv/

archive/20130106_TVK_PM_Hun_Sen_Speech_-_Dinner_with_Student_Volunteers_of_Land_Titling_Program.php>
16. Khuon, N., 2013. 'Hun Sen Thanks Student Land Titling Volunteers', *The Cambodia Daily*, April 8, 2013 p.19
17. Kolbot Khmer 2012d, *More than 2000 student volunteers paid respect to the late king,* Kolbot Khmer, viewed April 30, http://kolbotkhmer.com.kh/kh/archives/1031.
18. Kolbot Khmer 2012e, *Students return to their mission after Water Festival Holiday*, Kolbot Khmer, viewed April 30, <http://kolbotkhmer.com.kh/kh/archives/1241>.
19. Kolbot Khmer 2012f, *Student Volunteers returned home after the First phase of Land Measurement Finished,* Kolbot Khmer, viewed April 30, <http://kolbotkhmer.com.kh/kh/archives/1334>
20. Kolbot Khmer 2013a, *Kep, Group 118th,* Kolbot Khmer, viewed May 1, <http://kolbotkhmer.com.kh/kh/archives/1860>
21. Kolbot Khmer 2013b, *Student volunteers met, and listen before next departure,* Kolbot Khmer, viewed April 19, 2013, http://kolbotkhmer.com.kh/kh/archives/1938
22. Kolbot Khmer 2013c, *The Result of Ministry of Land Management, Urban Planning and Construction's Entrance Exam*, Kolbot Khmer, viewed May 1, http://kolbotkhmer.com.kh/kh/archives/1390.
23. Kuch Naren. 2013. "Families in Pursat accuse officials who denied giving land titles to them." *The Cambodia Daily.* March 8, 2013.
24. Kuch, N., & Seiff, A., 2012. 'Land Concessions Signed After Hun Sen Ordered Moratorium', *The Cambodia Daily*, June 15, 2012, p.1-2
25. Le Meng Hour. Radio Free Asia. "*First land titles will be handed out in Kratie on 21 September.*" Broadcast on September 4, 2012.
26. LICADHO 2013, *Human Right in 2012: A Year in Review,* LICADHO, viewed March 30, 2013, <http://www.licadho-cambodia.org/collection/17/human_rights__2012_review>.
27. LICADHO, 2012. *2012 in Review: Land Grabbing, the Roots of Strife*, LICADHO, viewed April 11, 2013 (http://www.licadho-cambodia.org/printnews.php?id=133)
28. May, T., 2012a. "PM Calls for Land Reform", *The Phnom Penh Post*, June 15, 2012, p.1-4
29. May, T., 2012b. "Hun Sen Grants Four ELCs", *The Phnom Penh Post*, June 25, 2012, p.1-4
30. May, T., 2012c. "Hun Manet Appointed on Land Dispute", *The Phnom Penh Post*, June 28, 2012, p.1-7
31. May. T., 2013d. "Land titles denied, villagers in Pursat claim", *The Phnom Penh Post,* February 20, 2013
32. May, T., 2012e. "More Students for Land Measurement'", *The Phnom Penh Post*, July 6, 2012, p.1-3
33. May, T., 2012f. "Student Volunteers allows to break for Pchum Ben", *The Phnom Penh Post,* October 12, 2012, p.8
34. May. T., 2013g. "Villagers may get land titles", *The Phnom Penh Post,* February 26, 2013
35. May. T., 2013h. "Old soldiers won't fade away", *The Phnom Penh Post,* May 7, 2013

36. Mesa, S., 2013, ‘Volunteers Begin Phase 2 of Land Titling Program’, *The Cambodia Daily,* January 16, 2013 p.19
37. MLMUPC, 2012. Guiding documents on the implementation of Order 01BB dated May 7, 2012 on The Measure to Strengthen and Enhance the Effectiveness of the management of Economic Land Concessions.
38. MLMUPC, 2013. Report on the State and Results of the Implementation of Order 01BB nationwide (from the commencement until June 20, 2013). Official website of Ministry of Land Management, Urban Planning and Construction, http://www.mlmupc.gov.kh/mlm/imgs/20130620_Daily%20Result-web.pdf (retrieved on June 27, 2013)
39. MLMUPC. 2013, *The Implementation of Order 001 up to 30 March 2012: progressive report, Ministry of Land Management, Urban Planning and Construction*, N0. DNS/HSDK, Phnom Penh
40. Muller, FV & Zulsdorf, G 2013, *‘Old Policies-New Action: A Surprising Political Initiative to Recognize Human Rights in the Cambodia Land Reform’*, Paper prepared for presentation at the Annual World Bank Conference on Land and Poverty, Washington DC, April 8-11, 2013
41. Penh Pal 2012, *Cambodia’s Vexed Land Title Dilemma,* Penh Pal, viewed March 29, 2013, <http://penhpal.com/2012/06/cambodias-vexed-problem-with-land-titles/>
42. Phak, S., 2012. “Families plead for help to stop Pursat evictions”, *The Phnom Penh Post,* August 9, 2012
43. Phak, S., 2013. “Families say land was taken”, *The Phnom Penh Post*, May 24, 2013
44. Phorn. B., 2012. “Hun Sen tells people to help with land title”, *The Cambodia Daily*, October 1, 2012
45. Rabe, A., 2012. Student Volunteers to Register Land, Land of the Blind, viewed March 30, 2013, <http://alicambo.wordpress.com/2012/09/03/student-volunteers-to-register-land-2/>
46. RFA 2012, ‘Soldiers Help Register Land’, *Radio Free Asia*, August 3; viewed April 7, 2013, <http://www.rfa.org/english/news/cambodia/land-registration-08032012175511.html>.
47. Royal Government of Cambodia, 2012. Order 01BB on The Measure to Strengthen and Enhance the Effectiveness of the Management of Economic Land Concessions. May 7, 2012.
48. Strangio, S 2012, ‘Cambodia Carve-up under the Spotlight’, *Asia Time*, July 9; viewed March 29, 2013, <http://www.sebastianstrangio.com/2012/07/09/cambodia-carve-up-under-the-spotlight/>
49. Vize, J., & Hornung, M., 2013, *‘Indigenous People and Land Titling in Cambodia: A Study of Six Villages’*, Paper prepared for presentation at the Annual World Bank Conference on Land and Poverty, Washington DC, April 8-11, 2013, Heinrich Boll Foundation, Phnom Penh, Cambodia, viewed April 5, 2013, https://www.conftool.com/landandpoverty2013/index.php?page=browseSessions&presentations=show&mode=list&print=yes&form_date=2013-04-11
50. Youtube 2013, *Cambodian news Prime Minister Hun Sen spoke at Koh Pich Resort 06 01 2013*, http://www.youtube.com/watch?v=h8wJzRcaSQo&list=PL494AFB7F89951BD6, (viewed April 3, 2013)

51. Youtube 2013, *General mobilization of the Trust Young Volunteers to help formalize the rights of possession of land deep in the countryside*, <http://www.youtube.com/watch?v=b0DDhOJ7nWU> (viewed April 6, 2013)
52. Youtube2012, *General mobilization of the Trust Young Volunteers to help formalize the rights of possession of land deep in the countryside*, Youtube, viewed April 6, 2013, <http://www.youtube.com/watch?v=b0DDhOJ7nWU>